# ការត្រួសត្រាយផ្លូវ
# សម្រាប់ដំណឹងល្អ

*ការជួយឱ្យក្រុមជំនុំរីកចម្រើន*
*និងដាំក្រុមជំនុំថ្មី ដែលគាំទ្រខ្លួនឯង*
*ដោយប្រើវិធីសាស្ត្រគម្ពីរសញ្ញាថ្មី*

**ដោយលោក ថូម៉ាស វេឌ និង បាបារ៉ា អ៊ែឃីន**
By Thomas Wade and Barbara Akins

| | | |
|---|---|---|
| First Printing | 2,000 copies | February 2004 |
| Second Printing | 2,000 copies | September 2009 |
| Third Printing | 1,000 copies | September 2010 |


© រក្សាសិទ្ធិដោយ*ព្រះបន្ទូលនៃជីវិត*, ឆ្នាំ ២០០៤, ២០០៩, ២០១០

A Training Book of
***Words of Life Ministries and***
***Antioch Institute***

យើងខ្ញុំទទួលស្វាគមន៍មតិរិះគន់ស្ថាបនា និងយោបល់ផ្សេងៗពីលោកអ្នក។ ប្រសិនបើ
លោកអ្នកឃើញមានកំហុសណាមួយក្នុងសៀវភៅ សូមទំនាក់ទំនងយើងខ្ញុំតាមរយៈប្រអប់
សំបុត្រ ២៥៨១ ភ្នំពេញ ៣ ឬតាមអ៊ីមែលៈ info@asiaforjesus.com សូមអរគុណ!

# មាតិកា

Table of Contents


ផ្នែកទី១

គោលការណ៍នៅព្រះគម្ពីរសម្រាប់ការផ្សាយដំណឹងល្អ ការបង្កើតសិស្ស និងការដាំក្រុមជំនុំ ៥

ផ្នែកទី២

ចំណុចអនុវត្តិន៍ជាក់ស្តែងៈ អ្វីដែលត្រូវបង្រៀនក្រុមរបស់លោកអ្នក ៣៣

ផ្នែកទី៣

ផែនការៈ ជំហានក្នុងការបង្កើតក្រុមជំនុំថ្មី ៥៩

ផ្នែកទី៤

សេចក្តីពិតប្រាំមួយយ៉ាងសម្រាប់អ្នកជឿថ្មី ៦៥

១ ការធានាអះអាងនៃសេចក្តីសង្គ្រោះ និងជីវិតដ៏នៅអស់កល្ប ៦៧

២ ការជ្រមុជទឹក ៧០

៣ ចូរអានព្រះគម្ពីររបស់លោកអ្នក ៧១

៤ សេចក្តីអធិស្ឋាន ៧១

៥ ក្លាយទៅជាសមាជិកនៃក្រុមជំនុំផ្សាយដំណឹងល្អ ៧២

៦ ការធ្វើបន្ទាល់ ៧៤

ផ្នែកទី៥

ការសិក្សាគម្ពីរដំណឹងល្អយ៉ូហាន ៧៧

១ គម្រោងការដ៏អស្ចារ្យសម្រាប់ជីវិតរបស់អ្នក ៧៩

២ អំណាចនៃការរស់នៅដ៏អស់កល្បជានិច្ច ៨៤

៣ សោកនាដ្ឋកម្មនៃអំពើបាប ៨៨

៤ សកម្មភាព និងលទ្ធផល ៩៣

៥ ដំណោះស្រាយរបស់ព្រះចំពោះអំពើបាបរបស់យើង ៩៨

៦ អំណោយដ៏អស្ចារ្យបំផុត ១០២

៧ អំណោយរបស់ព្រះដែលទ្រង់នៅតែប្រទានឱ្យ ១០៧

# ផ្នែកទី១

# គោលការណ៍នៅក្នុងព្រះគម្ពីរសម្រាប់
# ការផ្សាយដំណឹងល្អ
# បង្កើតសិស្ស
# និងការដាំក្រុមជំនុំ

BIBLICAL PRINCIPLES

for Evangelism

Discipleship

and Church Planting

# គោលការណ៍នៅក្នុងព្រះគម្ពីរសម្រាប់ការផ្សាយដំណឹងល្អ ការបង្កើតសិស្ស និងការបង្កើតក្រុមជំនុំ

## I.តើការត្រួសត្រាយផ្លូវសម្រាប់ការផ្សាយដំណឹងល្អជាអ្វី?

វិធីត្រួសត្រាយផ្លូវសម្រាប់ការផ្សាយដំណឹងល្អរួមមានការបង្វឹកអ្នកផ្សាយដំណឹងល្អ ឱ្យ ចេញ ទៅក្នុង តំបន់ ដែល គ្មាន ក្រុមជំនុំ (តំបន់ ដែល ទើប នឹងបង្កើត ថ្មី) ដើម្បី នាំព្រលឹងវិញ្ញាណថ្វាយដល់ព្រះគ្រិស្ត ហើយចាប់ផ្តើមកិច្ចការថ្មីៗជាច្រើន។

ក.នៅក្នុង ជីវិតរបស់លោកអ្នក តើផលវិបាកអ្វីខ្លះដែលលោកអ្នកជួបប្រទះក្នុងការបង្កើតក្រុមជំនុំថ្មីមួយទៀត?

______________________________

______________________________

______________________________

______________________________

______________________________

______________________________

២.គំរូ ៤ នៃការបង្កើតក្រុមជំនុំថ្មីៈ

១. គំរូដែលជាទំនៀមទម្លាប់ក្នុងការបង្កើតជាមួយនឹងក្រុមនៃអ្នកជឿ

- ក្រុមជំនុំកំណត់ទីតាំងនៃការងារ ។
- ក្រុមជំនុំអញ្ជើញអ្នកធ្វើការម្នាក់មកដែលមិនចាំបាច់ជាគ្រូគង្វាលនោះទេ ដើម្បីឱ្យចាប់ផ្តើមបង្កើតក្រុមជំនុំថ្មី។
- អ្នកធ្វើការត្រូវស្វែងរកទីកន្លែងប្រជុំសម្រាប់ក្រុមថ្មីដើម្បីជួបជុំគ្នា ហើយចាប់ផ្តើមអញ្ជើញប្រជាជនមករៀនព្រះគម្ពីរ និងថ្វាយបង្គំ។

- ក្រុមជំនុំត្រូវផ្គត់ផ្គង់ដល់គ្រិស្តបរិស័ទ៥ទៅ១០នាក់ ឬក៏ច្រើនជាងនេះដែលរស់នៅក្នុងតំបន់នោះ។
- អ្នកជឿទាំងនេះ និងអ្នកធ្វើការចាប់ផ្ដើមនូវការប្រជុំមួយជាមួយនឹងការផ្គត់ផ្គង់ខាងហិរញ្ញវត្ថុនៃក្រុមជំនុំ។
- ក្រុមជំនុំជាធម្មតាធ្វើការសម្រេចចិត្តរាល់បញ្ហាសំខាន់ទាំងអស់ និងប៉ាន់ប្រមាណមើលពីការចំណាយនៃក្រុមជំនុំថ្មីដូចជា៖ របស់របរប្រើប្រាស់ ការសាងសង់អាគារ និងប្រាក់ខែ។

## ២. គំរូដែលជាទំនៀមទម្លាប់ក្នុងការបង្កើតក្រុមជំនុំថ្មីមួយដោយគ្មានក្រុមអ្នកជឿ

ក្រុមជំនុំត្រូវទទួលបន្ទុកអ្វីៗទាំងអស់ដូចដែលបានធ្វើនៅក្នុងគំរូដំបូងរហូតដល់ការងារថ្មីត្រូវបានរៀបចំឱ្យបានជាក្រុមជំនុំថ្មីជាផ្លូវការសិន។ មានការខុសប្លែកតែមួយគត់ គឺការអវត្តមាននៃក្រុមគាំទ្រដំបូងដែលត្រូវបានធ្វើឡើងដោយអ្នកជឿនៅក្នុងតំបន់នោះ។

## ៣.គំរូគម្រោងពិសេស

ក្រុមជំនុំត្រូវស្វែងរកតំបន់ និងបង្កើតគម្រោងមួយដែលនឹងធ្វើឱ្យមានឥទ្ធិពលដ៏ធំធេង។ ឧទាហរណ៍ដ៏សាមញ្ញខ្លះនៃគម្រោងសង្គមដូចជា ការសិក្សាព្រះគម្ពីរ ឬព័ន្ធកិច្ចដើម្បីឈានទៅដល់សហគមន៍ដែលនៅដាច់ស្រយាល។ គ្រោងការទាំងនេះត្រូវបានជ្រើសរើសឡើងដោយប្រភពនៃហិរញ្ញវត្ថុ និងធនធានមនុស្សរបស់អង្គការផ្ទាល់។ ឧទាហរណ៍ នៅឆ្នាំ ១៩៩២ មានទឹកជំនន់មួយយ៉ាងធំនៅក្នុងរដ្ឋ *មីណាសជើរ៉េស* (Minas Gerias) នៅក្នុង ប្រទេស *ប្រេស៊ីល* មនុស្ស រាប់ពាន់ នាក់ បានបាត់បង់ផ្ទះសម្បែងរបស់ពួកគេ។ *បាបា៉អ៊ែឃីន* មានលទ្ធភាពនឹងអាចយកថវិកាពីអង្គការបេសកកម្មរបស់គាត់ដើម្បីជួយប្រជាជនទាំងនោះក្នុងការកសាងផ្ទះរបស់ពួកគេឡើងវិញ រដ្ឋអំណាចបានផ្ដល់ជំនួយជាដីធ្លី ហើយពួកគេបានចាប់ផ្ដើមបង្កើតនូវសហគមន៍ថ្មីមួយដែលពួកគេបានដាក់ឈ្មោះថា *ទីក្រុងនៃព្រះអម្ចាស់*។ ពួកគេសង់ផ្ទះ៧០ខ្នងនៅក្នុងរយៈពេល១ឆ្នាំ ហើយរៀនព្រះគម្ពីរនៅតាមផ្ទះ។ មនុស្សជាច្រើនត្រូវបានសង្គ្រោះ ហើយក្រុមជំនុំក៏ត្រូវបានចាប់ផ្ដើមឡើងដែរ នេះបន្សំឡើងនៃការប្រើគម្រោងពិសេស និងការត្រួសត្រាយផ្លូវសម្រាប់ការផ្សាយដំណឹងល្អ ពីព្រោះជាធម្មតាការសិក្សាព្រះគម្ពីរត្រូវបានធ្វើឡើងនៅក្នុងផ្ទះនៃអ្នកដែលមិនជឿ។ ការប្រើវិធីនៃគម្រោងពិសេសនេះ ត្រូវមានអ្នកបម្រើការម្នាក់ជួយចាត់ចែងនូវគ្រោងការនេះហើយអង្គការ ឬក្រុមជំនុំត្រូវផ្គត់ផ្គង់អគារប្រជុំ និងបើកនូវជួរមុខនៃបេសកកម្មជាផ្លូវការ។

៤.គំរូនៃការត្រួសត្រាយផ្លូវសម្រាប់ការផ្សាយដំណឹងល្អ

ក)- ក្រុមជំនុំត្រូវស្វែងរកតំបន់ដែលយើងនឹងអាចទៅដល់។

ខ)- គ្រូគង្វាល ឬអ្នកដឹកនាំត្រូវជ្រើសរើស «សមាជិកដែលលូតលាស់ខាងឯព្រលឹងវិញ្ញាណ» ដើម្បីឱ្យធ្វើការងារ។

គ)- គ្រូគង្វាល ឬអ្នកដឹកនាំត្រូវបង្វឹក និងបង្រៀនសមាជិកក្រុមជំនុំរូបនោះអំពីគោលបំណងក្នុងកិច្ចការនេះ គឺដើម្បីបង្ហាញពីរបៀបបង្វឹកពួកគេ។

ឃ)- សមាជិកក្រុមជំនុំរូបនោះនឹងចាប់ផ្តើមនូវការងារថ្មីដោយធ្វើការបង្រៀនព្រះគម្ពីរនៅក្នុងផ្ទះនៃអ្នកមិនជឿ។

ង)- អ្នកជឿថ្មីដោយការរៀនព្រះគម្ពីរនឹងត្រូវបាននាំមកឱ្យមានការស្រុសស្រួលគ្នាមួយពីទីកន្លែង និងចាប់ផ្តើមបង្កើតនូវព្រះវិហារថ្មីមួយដែលចាត់ចែងដោយខ្លួនឯង ទំនុកបម្រុងខ្លួនឯង បណ្តុះបណ្តាលខ្លួនឯងនៅក្រោមការដឹកនាំរបស់ព្រះជាម្ចាស់។

ច)- អ្នកផ្សាយដំណឹងល្អ ណែនាំក្រុមថ្មីឱ្យធ្វើការសម្រេចចិត្តដោយខ្លួនគេផ្ទាល់ ហើយប៉ាន់ស្មាននូវការចំណាយរបស់ខ្លួនតាំងពីមុនដំបូង តាំងពីពេលដែលពួកគេបានធ្វើ ដោយមានជំនួយពីព្រះវិហារនោះ។

## II. ព្រះគម្ពីរ និង វប្បធម៌

**ចំណុចសំខាន់:** ប្រទេសនីមួយៗមានវប្បធម៌រៀងៗខ្លួន។ វាជាការសំខាន់ណាស់ដែលថា កិច្ចការនៃអ្នកផ្សាយដំណឹងល្អគួតែយល់ពីកាលៈទេសៈនៅជុំវិញវប្បធម៌ និងមិនត្រូវធ្វើឱ្យមានឥទ្ធិពលដោយវប្បធម៌នៃប្រទេសផ្សេងនោះឡើយ។ អ្នកផ្សាយដំណឹងល្អត្រូវតែបង្រៀនពីដំណឹងល្អមួយមុខប៉ុណ្ណោះសម្រាប់ដំណឹងល្អនិងផ្លាស់ប្តូរនូវទិដ្ឋភាពនៃវប្បធម៌ដែលមិនស្របទៅតាមព្រះគម្ពីរ។

## III. ព្រះគម្ពីរ និង អំណាចរបស់ព្រះគម្ពីរ

មនុស្សម្នាក់ៗនៅផែនដីនេះមានប្រភពនៃអំណាចរៀងៗខ្លួន។ លោកបណ្ឌិត RALPH NEIGHBOR, JR នៅក្នុងសៀវភៅរបស់គាត់ **Survival Kit** *«សារពត៌មានប្រតត៌មេន»* និយាយពីប្រភពនៃអំណាចដើម្បីបញ្ជាក់នូវអ្វីដែលត្រឹមត្រូវ និងអ្វីដែលមិនត្រឹមត្រូវ។

**១. បញ្ញា:** នេះគឺនៅពេលមនុស្សបញ្ជាក់នូវអ្វីដែលពិតជាក់ស្តែងទៅតាមសមត្ថភាពផ្ទាល់ខ្លួនរបស់ពួកគេ ដើម្បីឱ្យឃើញថា សមហេតុផលរវាងអ្វីនោះដែលត្រូវឬមិនត្រូវ ល្អឬអាក្រក់ អាចឬមិនអាច និងអ្វីផ្សេងៗទៀត។ ឧ.មនុស្សម្នាក់ពឹងផ្អែកលើបញ្ញារបស់ខ្លួនបានបដិសេធនូវការអស្ចារ្យនៃព្រះយេស៊ូគ្រិស្ត ពីព្រោះគាត់មិនអាចបង្ហាញនូវការណាមួយឱ្យបានច្បាស់តាមរយៈរបៀបវិទ្យាសាស្ត្រនោះឡើយ។

**អេសាយ ៥៥:៨** *« ព្រះអម្ចាស់មានព្រះបន្ទូលថា គំនិតយើងខុសប្លែកពីគំនិតអ្នករាល់គ្នា រីឯរបៀបដែលយើងប្រព្រឹត្តក៏ខុសប្លែកពីរបៀបដែលអ្នករាល់គ្នាប្រព្រឹត្តដែរ»*

**២. បទពិសោធន៍:** នេះគឺនៅពេលមនុស្សម្នាក់បញ្ជាក់ថាអ្វីដែលត្រឹមត្រូវឬក៏ខុសដោយអារម្មណ៍ការយល់ដឹងដោយការស្ទាប និងដោយអារម្មណ៍របស់គាត់។ ឧ.មានថ្ងៃមួយ *ថមវេដ* បានជិះឡានតាក់ស៊ីទៅទីក្រុង RIO DE JANEIRO នៃប្រទេស *ប្រេស៊ីល* និងចាប់ផ្តើមផ្សាយដំណឹងល្អទៅកាន់អ្នកបើកបរ។ អ្នកបើកបរបានប្រាប់ដល់ *ថូម៉ាស់* ថា នៅក្នុងការថ្វាយបង្គំក្នុងពិធីនៃសាសនារបស់គាត់ មានមនុស្សខ្វាក់ម្នាក់ត្រូវបានជាសះស្បើយ និងអាចមើលឃើញឡើងវិញ។ នៅពេល *ថូម៉ាស់* សួរឈ្មោះក្រុមជំនុំរបស់អ្នកបើកបរនោះ គាត់និយាយថាគាត់មិនមែនជាគ្រិស្តបរិស័ទទេ និងថាការពិតសាសនារបស់គាត់មិនមានការទាក់ទងនឹងគ្រិស្តបរិស័ទឡើយ សូម្បីតែបន្តិចក៏គ្មានដែរ។

អារក្សមានអំណាចនឹងធ្វើការអស្ចារ្យជាច្រើន ប៉ុន្តែវាមិនអាចសង្គ្រោះឬក៏ឱ្យសន្តិភាពដ៏ពិតប្រាកដ និងការអត់ទោសដល់គេបានឡើយ។ ពេលខ្លះវាប្រើការអស្ចារ្យដើម្បីបំភាន់មនុស្សលោក។ ព្រះគម្ពីរ ២ ថែស្សាឡូនីច ២:៩-១២បានចែងថា *«រីឯមេប្រឆាំងសាសនានោះវិញ វាមកដល់ដោយអំណាចមារសាតាំង គឺវាសម្តែងការអស្ចារ្យ ទីសំគាល់ និងឫទ្ធិបដិហារ្យបោកប្រាស់សព្វបែបយ៉ាង។ វានឹងប្រើអំពើទុច្ចរិតគ្រប់យ៉ាង ដើម្បីបោកបញ្ឆោតអស់អ្នកដែលត្រូវវិនាសអន្តរាយ ព្រោះគេពុំព្រមទទួល ពុំព្រមស្រឡាញ់សេចក្តីពិត ដែលអាចសង្គ្រោះគេទេ។ ហេតុនេះហើយបានជាព្រះជាម្ចាស់ចាត់ឥទ្ធិពលមួយមកធ្វើឱ្យគេវង្វេង និង ឱ្យគេជឿលើពាក្យភូតភរ ដើម្បីឱ្យអ្នកដែលមិនព្រមជឿសេចក្តីពិត ហើយចូលចិត្តអំពើទុច្ចរិតត្រូវទទួលទោស» ។*

អ្នកខ្លះនិយាយដូចខាងក្រោមថា: *«ខ្ញុំជឿលើថ្នាំ និងគ្រឿងស្រវឹង ពីព្រោះខ្ញុំមានអារម្មណ៍ល្អនៅពេលខ្ញុំប្រើវា»*។ ប្រភពនៃអំណាចសម្រាប់មនុស្សម្នាក់នេះគឺ

អារម្មណ៍របស់គាត់។ នេះជាផ្លូវមួយដែលគ្រោះថ្នាក់បំផុតដើម្បីបង្កើតការរកមើលប្រព័ន្ធនៃសេចក្តីជំនឿរបស់លោកអ្នក។ អ្នកផ្សេងទៀតនិយាយថាៈ *«ខ្ញុំជឿលើអ្នកព្យាបាលដ៏ពិសេសឬគ្រូពេទ្យថ្មីនេះ ពីព្រោះគាត់អាចព្យាបាលជំងឺនេះបាន»* ប៉ុន្តែមនុស្សអស្ចារ្យ គឺជាអ្នកដែលអាចធ្វើការដ៏គួរឱ្យអស្ចារ្យជាច្រើន កំពុងស្វែងរកលាភសាការៈ និងភាពល្បីល្បាញដែលមិនមែនមកពីព្រះទាល់តែសោះ។

យើងមិនអាចដាក់សេចក្តីជំនឿរបស់យើងនៅលើការអស្ចារ្យ អារម្មណ៍ ឬសូម្បីតែបទពិសោធរបស់យើងបានឡើយ។ តែត្រូវពឹងផ្អែកទៅលើអង្គព្រះយេស៊ូគ្រិស្តថាព្រះអង្គជានរណា និងព្រះបន្ទូលសន្យារបស់ព្រះអង្គមាននៅក្នុងព្រះបន្ទូលនៃព្រះ។

**៣. ទំនៀមទម្លាប់ៈ** នេះជាបញ្ហាមួយក្នុងចំណោមបញ្ហាដ៏ធំបំផុតដែលព្រះគ្រិស្តបានប្រឈមមុខ។ ព្រះអង្គបានប្រឆាំងនឹងទំលៀមទំលាប់របស់សាសនាយូដា ពីព្រោះពួកគេតែងតែយកទំនៀមទន្លាប់ដាក់នៅលើសេចក្តីត្រូវការរបស់មនុស្សជាតិ។ នៅក្នុងព្រះគម្ពីរម៉ាកុស៣ៈ១-៦ យើងឃើញពីការដែលពួកអាចារ្យផារិស៊ីសាកល្បងព្រះយេស៊ូគ្រិស្ត។

**នៅក្នុង១១ៈ** នៅទីនេះយើងឃើញមានអ្វីកើតឡើងនៅពេលព្រះយេស៊ូគ្រិស្តយាងចូលទៅក្នុងសាលាប្រជុំសាសនា ។ ព្រះវិហារនៅក្នុងសាលាប្រជុំ ព្រះវិហារពេញទៅដោយមនុស្ស និងនៅចំកណ្តាលនៃហ្វូងមនុស្សមានបុរសម្នាក់ស្វិតដៃម្ខាង។

**នៅក្នុង១២ៈ** មនុស្សម្នាចាប់ផ្តើមខ្សិបគ្នាដូចនេះ «តើអ្នកឃើញទេ តើអ្នកណាទើបនឹងដើរចូលមក» «ព្រះយេស៊ូគ្រិស្ត» «តើអ្នកឃើញទេថា តើនរណាកំពុងអង្គុយនៅទីនោះ?» «បុរសស្វិតដៃម្ខាងម្នាក់» «តើអ្នកគិតថាព្រះយេស៊ូនឹងព្យាបាលគាត់ដែរឬទេ?» «ខ្ញុំមិនដឹងទេថ្ងៃនេះជាថ្ងៃសៅរ៍»។

**នៅក្នុង១៣ៈ** ព្រះយេស៊ូឱ្យបុរសម្នាក់នោះក្រោកឈរឡើង ចូលមកកាន់ព្រះអង្គ ហើយបន្ទាប់មកព្រះអង្គសួរទៅកាន់ហ្វូងមនុស្សថា«តើវាជាការធ្វើអំពើបាបឬក្នុងការព្យាបាលបុរសម្នាក់នេះ?»

**នៅក្នុង១៤ៈ** មនុស្សម្នានៅស្ងៀម ហើយព្រះយេស៊ូទតទៅកាន់ពួកគេដោយសេចក្តីកំហឹង ព្រោះតែចិត្តរឹងរូសរបស់ពួកគេ។

**នៅក្នុង១៥ៈ** ព្រះយេស៊ូមានបន្ទូលទៅកាន់បុរសម្នាក់នោះថា «ចូរលាតដៃទៅ» បុរសម្នាក់នោះក៏លាត ហើយដៃគាត់ជាមួយរំពេចដូចដៃម្ខាងទៀតដែរ។

**នៅក្នុង២៦:** ពួកហេរ៉ូដ និងពួកអាចារ្យផារិស៊ីបានចាកចេញទៅទាំងមានគម្រោងលបធ្វើឃាតព្រះយេស៊ូ។ ពួកគេបានរៀបចំគម្រោងដើម្បីធ្វើឃាតព្រះយេស៊ូតាំងពីមុនដំបូងនៃកិច្ចការព្រះអង្គមកម្ល៉េះ មិនត្រឹមតែនៅថ្ងៃចុងក្រោយនៃការសោយទិវង្គតរបស់ព្រះអង្គនោះទេ។ ហេតុអ្វី?

១. តើមានបញ្ហាអ្វីនៅទីនេះ? (វាជាថ្ងៃឈប់សំរាក)
២. តើមានបញ្ហាអ្វីក្នុងការព្យាបាលមនុស្សនៅថ្ងៃឈប់សម្រាក? (ប្រឆាំងនឹងទំនៀមទម្លាប់សាសនា)
៣. តើលោកអ្នកជឿថា ព្រះយេស៊ូគ្រិស្តជាផ្នែកនៃព្រះត្រៃឯក ហើយជាព្រះរាជបុត្រានៃព្រះដែរឬទេ?
៤. តើលោកអ្នកជឿថា ព្រះយេស៊ូគ្រិស្តជាព្រះនៃថ្ងៃឈប់សម្រាកដែរឬទេ?
៥. តើលោកអ្នកជឿទេ ថានៅពេលព្រះយេស៊ូគ្រិស្តព្យាបាលបុរសម្នាក់នោះនៅថ្ងៃឈប់សម្រាក គឺព្រះអង្គមិនស្តាប់បង្គាប់ព្រះវរបិតារបស់ព្រះអង្គដែរឬទេ?
៦. បើដូច្នោះ! តើអ្វីជាបញ្ហា?

*ពួកអ្នកដឹកនាំសាសនាបានបង្កើតច្បាប់និងទំនៀមទម្លាប់បន្ថែម ដែលព្រះជាម្ចាស់មិនបានបង្កើតទាល់តែសោះ។*

តើមានអ្វីដែលទាក់ទងនឹងការត្រួសត្រាយផ្លូវសម្រាប់ការផ្សាយដំណឹងល្អនិងការបង្កើតក្រុមជំនុំ? **គឺទាក់ទងទាំងអស់!**

នៅពេលគ្រូគង្វាល *ថូម៉ាស់ វេដ អាយីនស៍* ទៅប្រទេស *ប្រេស៊ីល* គាត់បានបង្កើតក្រុមអ្នកបង្កើតក្រុមជំនុំមួយក្រុម។ ភាគច្រើននៃពួកគេ គឺជាសមាជិកក្រុមជំនុំធម្មតា។ គាត់បានបង្រៀនពួកគេពីរបៀបផ្សាយដំណឹងល្អ និងបង្កើតក្រុមជំនុំ។ ពួកគេចេញទៅក្រៅទីក្រុង និងនាំព្រលឹងមនុស្សសម្រាប់ព្រះគ្រិស្ត ហើយចាប់ផ្តើមមានការប្រជុំ និងរៀនព្រះគម្ពីរ។ ពួកគេបានបង្កើតនូវ ៦៣ គម្រោងការងារថ្មីៗនៅក្នុងរយៈពេល២ឆ្នាំ។

ទោះបីជាយ៉ាងណាក៏ដោយ ក៏*ថូម៉ាស់ អាយីនស៍* បានប្រឈមមុខទៅនឹងប្រពៃណីដ៏រឹងមាំបីដែលមនុស្សបានបង្កើត ទំនៀមទន្លាប់ទាំងបីនោះវាមានអំណាចណាស់ ពួកវាកំពុងទប់ស្កាត់នូវការរីកដុះដាលនៃការបង្កើតក្រុមជំនុំ។

**ប្រពៃណីទី១:** ក្រោយពីពេលដែលសមាជិកក្រុមជំនុំបាននាំមនុស្សឱ្យទទួលជឿព្រះយេស៊ូហើយ គ្រូគង្វាល*ថូម៉ាស់* បាននិយាយថា «យើងត្រូវអនុញ្ញាតអ្នកផ្សាយ

ដំណឹងល្អនេះធ្វើពិធី ជ្រមុជទឹកឱ្យអ្នកដែលទើបនឹងជឿថ្មីនេះ និងពិធីលាងព្រះអម្ចាស់»។ ទោះជាយ៉ាងណាក៏ដោយក៏មានគ្រូគង្វាលខ្លះ (មិនមែនទាំងអស់នោះទេ) និយាយថា «ពួកគេមិនអាចធ្វើដូច្នេះបានទេ ពីព្រោះពួកគេមិនបានត្រូវរើសតាំង»។

*ថូម៉ាស់* ឆ្លើយតបដោយសួរថា «តើនៅកន្លែងណាដែលព្រះគម្ពីរបង្រៀនពីការនេះ?» គេបានឆ្លើយតបថា«ព្រះគម្ពីរមិនបានបង្រៀនដូច្នេះទេ ប៉ុន្តែនេះជាទំលៀមទំលាប់របស់យើងឬក៏ច្បាប់នៅទីនេះ»។

ប្រព័ន្ធនៃការរើសតាំងទំនើបមិនមាននៅក្នុងព្រះគម្ពីរនោះទេ។ ការរើសតាំងនៅក្នុងព្រះគម្ពីរមិនមែនជាសេវាកម្ម ឬកម្មវិធីជាផ្លូវការទេ។ គ្មានការអនុម័តជាផ្លូវការអំពីសេវាកម្មនោះទេ។ ពាក្យថា«រើសតាំង»មានន័យថា តែងតាំង សេចក្តីបង្គាប់ ឬសេចក្តីបញ្ជា។ គម្ពីរយ៉ូហាន១៥:១៦ព្រះយេស៊ូ រើសសាវ័ករបស់ព្រះអង្គ*«មិនមែនអ្នករាល់គ្នាដែលបានជ្រើសរើសខ្ញុំទេ គឺខ្ញុំទេតើដែលបានជ្រើសរើសអ្នករាល់គ្នាហើយបានតែងតាំងអ្នករាល់ឱ្យទៅ និងបង្កើតផលព្រមទាំងឱ្យផលរបស់អ្នករាល់គ្នាបាននៅស្ថិតស្ថេរ។ ដូច្នេះអ្វីៗដែលអ្នករាល់គ្នាបានសុំពីព្រះវរបិតាក្នុងនាមខ្ញុំ ព្រះអង្គនឹងប្រទានឱ្យអ្នករាល់គ្នាជាពុំខាន»* ។

កិច្ចការ១៤:២៣ និយាយថាប៉ុលបានរើសចាស់ទុំ *«លោកបានតែងតាំងពួកព្រឹទ្ធាចារ្យ នៅតាមក្រុមជំនុំ ព្រះសហគមន៍នីមួយៗ។ លុះបាន អធិស្ឋាន និង តមអាហារ ហើយលោកទាំងពីរក៏ផ្ញើពួកសាវ័កទុកនៅនឹងព្រះអម្ចាស់ដែលគេបានជឿ។*

ចាស់ទុំទាំងនេះជាពួកអ្នកដឹកនាំនៃក្រុមជុំនុំជាច្រើន ដែលប៉ុលបានបង្កើត។

នៅក្នុងព្រះគម្ពីរ ការរើសតាំងជាកិច្ចការរបស់ព្រះជាម្ចាស់ មិនមែនជារបស់មនុស្សនោះទេ។ ព្រះជាម្ចាស់រើសតាំង និងជ្រើសរើសអ្នកដឹកនាំទាំងអស់។ នៅក្នុងប្រព័ន្ធរើសតាំងសម័យថ្មីរបស់យើងនេះ ក្នុងប្រទេសជាតិខ្លះបានក្លាយទៅជាហួសពីអ្វីដែលមានចែងនៅក្នុងព្រះគម្ពីរ។

នៅក្នុងប្រទេសខ្លះមនុស្សម្នាក់ត្រូវបានរើសតាំងលុះត្រាតែគាត់បានបញ្ចប់នូវសាលាគម្ពីរជាមុនសិន។ តើសាលារៀនរបៀបណាដែលព្រះយេស៊ូ បាន ចូលរួមនោះ? តើសាលាគម្ពីរបែបយ៉ាងទៅដែលប៉ុល ពេត្រុស យ៉ូហានបានចូលរួម?

សូមឱ្យខ្ញុំសួរលោកអ្នក តើអ្នកណាជ្រមុជទឹកឱ្យសាវ័កប៉ុល?តើជាគ្រូគង្វាលឬក៏ជាមនុស្សធម្មតា?តើមានមនុស្សប៉ុន្មានអ្នកដែលព្រះយេស៊ូជ្រមុជទឹកឱ្យ? តើនៅ

កន្លែងណាដែលយើងរកឃើញនូវគំនិតថា មានតែគ្រូគង្វាលមួយប៉ុណ្ណោះដែលអាចធ្វើពិធីជ្រមុជទឹក និងពិធីលៀងព្រះអង្គម្ចាស់បាន?

នៅក្នុងប្រវត្តិនៃតំបន់ជីវិតជាក្រុមជំនុំ យើងអនុវត្តនូវក្រុមជំនុំបែបប្រព័ន្ធព្រះគម្ពីរសញ្ញាចាស់ ដែលនៅក្នុងនោះពួកសង្ឃបានធ្វើអ្វីៗទាំងអស់សម្រាប់មនុស្ស។ ក្រុមជំនុំមានឥទ្ធិពលជាច្រើនផ្សេងទៀតមកពីព្រះវិហាររ៉ូម៉ាំង កាតូលីក។

**ប្រពៃណីទី២:** បន្ទាប់មក ថូម៉ាស់ មកបាននិយាយថា «យើងត្រូវការរៀបចំក្រុមដែលជួបជុំគ្នាទាំងនេះ ឱ្យទៅជាក្រុមជំនុំ»។ អ្នកខ្លះនិយាយថា «យើងមិនអាចធ្វើដូច្នេះបានទេ លុះត្រាណាតែពួកគេមានដី និងអគារខ្លួនរបស់គេផ្ទាល់ខ្លួនសិន»។ លោក*ថូម៉ាស់* បានឆ្លើយតបដោយនិយាយថា «ព្រះគម្ពីរមិនបានបង្រៀនដូច្នោះទេ» ហើយគេបានឆ្លើយទៀតថា «ព្រះគម្ពីរមិនបាននិយាយមែន ប៉ុន្តែនេះជាទំនៀមទម្លាប់របស់យើង»

**ប្រពៃណីទី៣:** នៅក្នុងប្រទេសផ្សេងៗទៀត គ្រូគង្វាលបាននិយាយថា «លក្ខន្តិកៈសហព័ន្ធក្រុមជំនុំរបស់យើងនិយាយថា យើងបង្កើតជាក្រុមជំនុំនៅទីនេះមិនបានទេ លុះត្រាតែក្រុមជំនុំនោះមានយ៉ាងហោចណាស់សមាជិក៥០នាក់ដែរ»។ លោក*ថូម៉ាស់* បានឆ្លើយតបដោយនិយាយថា «ព្រះគម្ពីរមិនបានបង្រៀនដូច្នោះទេ» ហើយគេបានឆ្លើយទៀតថា «ព្រះគម្ពីរមិនបាននិយាយបែបនេះមែនប៉ុន្តែ នេះជាទំនៀមទម្លាប់របស់យើង» ។ ចម្លើយ«វាមិនមែនទេ ប៉ុន្តែវាគ្រាន់តែជាប្រពៃណី ទំនៀមទម្លាប់របស់យើងតែប៉ុណ្ណោះ»។ មានករណីជាច្រើនដែលប្រពៃណីទំនៀមទម្លាប់របស់យើងមានឥទ្ធិពលជាងព្រះបន្ទូលរបស់ព្រះជាម្ចាស់ ហើយនោះពិតជាអ្វីដែលព្រះគ្រិស្តរាប់ពីការនោះផងដែរ។ ប្រសិនជាពួកយើងនឹងទៅមើលពីការរីកដុះដាលនៅក្នុងអាណាចក្ររបស់ព្រះជាម្ចាស់ និងព្រះវិហារថ្មីជាច្រើនបានបង្កើតឡើងយើងត្រូវត្រលប់ទៅឯព្រះគម្ពីរវិញ និងធ្វើតាមព្រះបន្ទូលរបស់ព្រះជាម្ចាស់ និងដាក់ព្រះគម្ពីរនៅលើមនុស្សដែលជាអ្នកបង្កើតច្បាប់ និងទំនៀមទម្លាប់។

ប្រសិនជាយើងចង់មើលឃើញនូវចលនាបង្កើតក្រុមជំនុំដ៏ពិតនៅក្នុងពិភពលោករបស់យើង ដូច្នេះយើងត្រូវបង្កើននូវអំណាចអ្នកផ្សាយដំណឹងល្អរបស់យើងឱ្យធ្វើព័ន្ធកិច្ចដែលព្រះជាម្ចាស់បានត្រាស់ហៅពួកគេឱ្យធ្វើ និងដើរតាមការបង្រៀនរបស់ព្រះគម្ពីរថាតើអ្វីទៅជាក្រុមជំនុំនោះ។

នៅពេលយើងដាក់ប្រពៃណីនៅលើព្រះបន្ទូលនៃព្រះ នោះយើងលប់បំបាត់ព្រះបន្ទូលរបស់ព្រះហើយ ព្រះយេស៊ូមានព្រះបន្ទូលនៅក្នុងម៉ាថាយ១៥:៦-៩ ថា

*គ្រប់មនុស្សទាំងអស់សុទ្ធតែកំពុត «អ្នករាល់គ្នាបានបំបាត់តម្លៃព្រះបន្ទូលរបស់ព្រះជាម្ចាស់ទៅប្រព្រឹត្តតាមទំនៀមទំលាប់របស់អ្នករាល់គ្នាវិញ។ មនុស្សមានពុតអើយ ពាក្យដែលព្យាការីអេសាយថ្លែងទុកអំពីអ្នករាល់គ្នាត្រូវណាស់គឺ៖ ប្រជារាស្ត្រនេះគោរពយើងតែបបូរមាត់ រីឯចិត្តគេនៅឆ្ងាយពីយើង។ គេថ្វាយបង្គំយើងឥតបានការអ្វីសោះ ព្រោះគេបង្រៀនតែក្បួនច្បាប់របស់មនុស្សប៉ុណ្ណោះ។*

**៤.បទគម្ពីរៈ** ព្រះបន្ទូលរបស់ព្រះគឺជាប្រភពតែមួយគត់នៃអំណាចដ៏ពិតរបស់យើង។ ព្រះជាម្ចាស់បើកសម្តែងនូវសេចក្តីពិតទៅតាមព្រះបន្ទូលដែលបានកត់ត្រារបស់ពួកគេមិនកែប្រែ និងបំពេញចំណេះដឹងនោះបានទេ។ ព្រះយេស៊ូមានព្រះបន្ទូលនៅក្នុងយ៉ូហាន ៨:៣២ថា *«អ្នករាល់គ្នានឹងស្គាល់សេចក្តីពិត ហើយសេចក្តីពិតនឹងរំដោះអ្នករាល់គ្នាឱ្យមានសេរីភាព»។*

អេសាយ ៤០:៨ចែងថា *«ស្មៅតែងតែក្រៀម ហើយផ្កាក៏ស្រពោន ប៉ុន្តែព្រះបន្ទូលរបស់ព្រះនៃយើងស្ថិតស្ថេរនៅអស់កល្បជានិច្ច»។*

ទំនុកដំកើង ១១៩:១០៥ចែងថា *«ច្បាប់របស់ព្រះអង្គបានធ្វើឱ្យទូលបង្គំដឹងខុសត្រូវ»។*

ទំនុកដំកើង *១១៩:១៤០ ចែងថា «ព្រះបន្ទូលសន្យារបស់ព្រះអង្គសម្រេចជាក់ស្តែងហើយ ទូលបង្គំជាអ្នកបម្រើរបស់ព្រះអង្គស្រឡាញ់ព្រះបន្ទូលនេះណាស់»។*

ទំនុកដំកើង *១១៩:១៦០ ចែងថា «គោលការណ៍នៃព្រះបន្ទូលរបស់ព្រះអង្គជាសេចក្តីពិត ហើយការទាំងប៉ុន្មានដែលព្រះអង្គសម្រេចដោយសុចរិត នៅស្ថិតស្ថេររហូតទៅ»។*

យ៉ូហាន១៤:៦ ចែងថា *«ព្រះយេស៊ូមានព្រះបន្ទូលទៅគាត់ថា៖ ខ្ញុំនឹងហើយ ជាផ្លូវ ជាសេចក្តី និងជាជីវិត។ គ្មាននរណាអាចទៅកាន់ព្រះវរបិតាបានឡើយលើកលែងតែទៅតាមខ្ញុំ»។*

**តើអ្វីទៅជាសេចក្តីពិត?**

ក. ព្រះយេស៊ូគ្រិស្ត
ខ. ព្រះបន្ទូលរបស់ព្រះ

## IV. តើអ្នកណាអាចធ្វើជាអ្នកត្រួសត្រាយផ្លូវសម្រាប់ការផ្សាយដំណឹងល្អ

មានមុខងារបីនៅក្នុងក្រុមជំនុំសម័យសញ្ញាថ្មី

ក. អ្នកត្រួតត្រា-១ ធីម៉ូថេ ៣

ខ. អ្នកជំនួយ (អ្នកបម្រើ)-១ ធីម៉ូថេ ៣:៨, ១០, ១២, ១៣, និងភីលីព ១:១

គ. ពួកចាស់ទុំ-កិច្ចការ ១៤:២៣ មានលើកឡើង៥៦ដងនៅក្នុងព្រះគម្ពីរសញ្ញាថ្មី។ តើពួកគេជានរណា? កិច្ចការ ១៥:២, ៤, ៦, ២២, ១៦:៤, ២១:៨។

**សាវកប៉ូលធ្វើតាមដំណាក់កាលបន្តបន្ទាប់នៅក្នុងការដាំក្រុមជំនុំ**

១. គាត់ចូលទៅក្នុងទីក្រុង:
   - ការធ្វើដំណើរលើកមួយ: កិច្ចការ ១៣:៥, ៦, ១៤:១, ៦, ២៤, ២៥
   - ការធ្វើដំណើរលើកទីពីរ: កិច្ចការ ១៦:១២, ១៧:១, ១០, ១៥, ១៨:១, ១៩
   - ការធ្វើដំណើរលើកទីបី: កិច្ចការ ១៩:១, ២០:២

២. គាត់ផ្សាយដំណឹងល្អ: កិច្ចការ ១៤:៣, ៧, ២១, ២៥

៣. គាត់នាំអ្នកដែលបាត់បង់ទៅកាន់ព្រះគ្រិស្ត: កិច្ចការ ១៤:១, ២១, ១៩:៨

៤. គាត់បង្រៀនដល់អ្នកជឿថ្មី: កិច្ចការ ១៤:២២, ១៨:២៣, ១៩:៩.១០

៥. គាត់បង្ហឹកអ្នកដឹកនាំនៅក្នុងតំបន់: កិច្ចការ ១៤:២៧, ១៥:៣៦, ១៦:៥, ២០:២០

៦. គាត់រៀបចំក្រុមជំនុំ និងជ្រើសរើសចាស់ទុំដើម្បីប៉ាន់ប្រមាណការដឹកនាំនៃក្រុមជំនុំនៅក្នុងតំបន់ កិច្ចការ ១៤:២៣, ២០:១៧, ២៨

៧. គាត់បានចាកចេញពីទីក្រុង ហើយធ្វើដំណើរទៅទីក្រុងមួយទៀត កិច្ចការ ២០:៣៦-៣៨
   - តើអ្នកណាដឹកនាំក្រុមជំនុំថ្មីដែលសាវកប៉ូលបានបង្កើត?

   ______________________________

   - តើអ្នកណាជាចាស់ទុំ? ______________________________

ដោយយោងទៅតាមព្រះគម្ពីរតើនរណាអាចជាអ្នកត្រួសត្រាយផ្លូវផ្សាយដំណឹងល្អបាន?______________________________

______________________________

**មុខងារ ៤ នៅក្នុងក្រុមជំនុំ: អេភេសូរ៤:១១**

ក. សាវក «ជាអ្នកដែលត្រូវបានបញ្ជូនឱ្យចេញទៅ»

ខ. **អ្នកថ្លែងព្រះបន្ទូល** ទុតិយកថា ១៨:១៨ «យើងនឹងធ្វើឱ្យមានព្យាការីម្នាក់ដូចអ្នកងើបឡើងពីក្នុងចំណោមលោកអ្នករបស់ខ្លួន យើងនឹងដាក់ព្រះបន្ទូលរបស់យើងនៅក្នុងមាត់របស់ព្យាការីនោះ លោកនឹងថ្លែងសេចក្តីទាំងប៉ុន្មាន ដែលយើងបង្គាប់»។

គ. **អ្នកផ្សាយដំណឹងល្អ**ត្រូវបានត្រាស់ហៅឱ្យផ្សាយដំណឹងល្អដើម្បីនាំព្រលឹងអ្នកដែលបាត់បង់ថ្វាយព្រះគ្រិស្ត។ នៅក្នុងសម័យនៃព្រះគម្ពីរសញ្ញាថ្មី ភីលីពជាមនុស្សធម្មតា អ្នកជំនួយ ជាអ្នក និងជាអ្នកផ្សាយដំណឹងល្អ។ *កិច្ចការ ២១:៨ចែងថា « នៅថ្ងៃបន្ទាប់យើងបន្តដំណើរទៅដល់ក្រុងសេសារា។ លោកបានចូលផ្ទះលោកភីលីពជាអ្នកផ្សាយដំណឹងល្អ និងជាម្នាក់នៅក្នុងចំណោមក្រុមប្រាំពីររូបហើយយើងក៏ស្នាក់នៅផ្ទះគាត់»* ។

គាត់ជាមនុស្សធម្មតាដែលផ្សាយដំណឹងល្អទៅដល់មនុស្សដែលបាត់បង់ និងធ្វើពិធីជ្រមុជទឹកដល់ពួកគេ កិច្ចការ៨:១២ ចែងថា « *កាលគេជឿដំណឹងល្អអំពីព្រះរាជ្យរបស់ព្រះជាម្ចាស់ និងអំពីព្រះនាមព្រះយេស៊ូគ្រិស្ត ដែលលោកភីលីពប្រកាសប្រាប់ គេក៏ទទួលពិធីជ្រមុជទឹកទាំងប្រុសទាំងស្រី* »។

- តើអ្នកណាជ្រមុជទឹកឱ្យសាវកប៉ូល-គ្រូគង្វាល ឬមនុស្សធម្មតា?

ឃ. **គ្រូគង្វាល-គ្រូបង្រៀន**-«បង្វឹកអ្នកជំនួយសម្រាប់ព័ន្ធកិច្ចនៅក្នុងក្រុមជំនុំ» (អេភេសូរ៤:១២)។

គម្រោងការរបស់ព្រះក្នុងការប្រទានអំណោយទានដល់អស់អ្នកដែលដើរតាមព្រះអង្គដើម្បីបម្រើព័ន្ធកិច្ចរបស់ព្រះអង្គ។

១ ពេត្រុស ៤:១០ ចែង ថា *« លោកអ្នកម្នាក់ៗ បាន ទទួល ព្រះអំណោយ ទានផ្សេងៗពីគ្នាហើយ ដូច្នេះ ចូរយកព្រះអំណោយទានទាំងនេះទៅបម្រើអ្នកឯទៀតៗ ឱ្យសមនឹងនាទីរបស់លោកអ្នក ជាអ្នកចាត់ចែងដ៏ល្អ ដែលចែកព្រះអំណោយទានគ្រប់បែបយ៉ាងរបស់ព្រះជាម្ចាស់»* ។

## លក្ខណៈសម្បត្តិនៃអ្នកត្រួសត្រាយផ្លូវដែលមានចែងនៅក្នុងព្រះគម្ពីរ

១. ជាអ្នកដែលត្រូវបានសង្គ្រោះ (កិច្ចការ៩)
២. ទទួលការត្រាស់ហៅ (កាឡាទី១:១៥-១៦)
៣. ពេញដោយព្រះវិញ្ញាណបរិសុទ្ធ (កាឡាទី ៥:១៦, អេភេសូរ ៥:១៨ និង កិច្ចការ១៣:៩)
៤. ស្គាល់ពីការប្រើព្រះបន្ទូលរបស់ព្រះ (២ ធីម៉ូថេ ២:១៥)
៥. ស្រឡាញ់ និងគោរពកោតខ្លាចដល់ព្រះ (១ ថែស្សាឡូនីច ២:៤)
៦. ស្រឡាញ់អ្នកដែលជឿថ្មី និងថែរក្សាពួកគេ (២ ថែស្សាឡូនីច ២:៧-១២, និង ទីតុស ១:៩)
៧. ចេះអធិស្ឋាន (១ ថែស្សាឡូនីច ១:២, កូល៉ុស ៤:២-៦)
៨. រស់នៅដោយមានជីវិតដែលបរិសុទ្ធ (១ ធីម៉ូថេ ៥:២២, ទីតុស ១:៧-៨)
៩. ឈរមាំនៅក្នុងសេចក្តីជំនឿ (ទីតុស ១:៩)

តើអ្នកណាអាចនឹងក្លាយទៅជាអ្នកត្រួសត្រាយផ្លូវសម្រាប់ការផ្សាយដំណឹងល្អបាន?________________________________________

________________________________________

## V. តួនាទីរបស់អ្នកដឹកនាំត្រួសត្រាយផ្លូវសម្រាប់ការផ្សាយដំណឹងល្អ

តើតួនាទីសំខាន់បំផុតរបស់គ្រូគង្វាលអ្នកផ្សាយដំណឹងល្អឬអ្នកដឹកនាំត្រួសត្រាយផ្លូវជាអ្វី? តើគាត់គួរតែធ្វើអ្វីៗគ្រប់យ៉ាងឬ? ទេ! គាត់ជាអ្នកដឹកនាំខាងវិញ្ញាណដែលបម្រើក្រុមជំនុំរបស់គាត់។

អេភេសូរ ៤:១១-១២ ពន្យល់យ៉ាងច្បាស់លាស់ពីអ្វីដែលជាតួនាទីដ៏សំខាន់របស់គ្រូគង្វាល។ ព្រះគម្ពីរចែងថា ព្រះជាម្ចាស់ប្រទានគ្រូគង្វាលទៅដល់ក្រុមជំនុំ *«ដើម្បីរៀបចំប្រជាជនដ៏វិសុទ្ធឱ្យបំពេញមុខងារបម្រើ និងកសាងព្រះកាយរបស់ព្រះគ្រិស្តឡើង»*។ ពាក្យ**កសាង**មានន័យថា បង្រៀនពួកគេឱ្យអនុវត្តនូវព័ន្ធកិច្ចរបស់ព្រះនៅក្នុងក្រុមជំនុំ មិនមែនគ្រាន់តែរៀនគោលលទ្ធិប៉ុណ្ណោះទេ។ ម្យ៉ាងវិញទៀត តួនាទីសំខាន់របស់គ្រូគង្វាល និងអ្នកដឹកនាំគឺសម្រាប់បង្វឹក និងបង្រៀនក្រុមជំនុំឱ្យបម្រើការងារដែលព្រះជាម្ចាស់ប្រទានមកដល់ពួកគេ។

ការចង្អុលបង្ហាញមួយដ៏ល្អពីមុខងាររបស់គ្រូគង្វាល គឺសូមគិតពីក្រុមបាល់ទាត់

មួយក្រុម។ ក្រុមបាល់ទាត់មួយមានអ្នកលេង និងគ្រូបង្វឹកម្នាក់។ តើគ្រូបង្វឹកត្រូវចូលទៅក្នុងតារាងហើយលេង ឬក៏គាត់បង្រៀនអ្នកលេងឱ្យចេះលេង? ចម្លើយគឺថា ហ្នឹងហើយ គឺគាត់ត្រូវបង្រៀនអ្នកលេងឱ្យចេះលេង។

គ្រូគង្វាលនៅក្នុងក្រុមជំនុំ ឬអ្នកដឹកនាំនៃពួកជំនុំ ឬបេសកកម្ម គឺមិនមែនធ្វើព័ន្ធកិច្ចសម្រាប់សមាជិកក្រុមជំនុំនោះទេ។ ប៉ុន្តែដើម្បីបង្រៀន និងបង្វឹកពួកគេពីរបៀបធ្វើកិច្ចការនោះវិញ។ គាត់ត្រូវបង្វឹកសមាជិករបស់គាត់ឱ្យចេះធ្វើនូវកិច្ចការដែលគាត់កំពុងតែធ្វើដែលរួមទាំងការបង្រៀនពួកគេពីរបៀបធ្វើបន្ទាល់ អធិប្បាយពិធីជ្រមុជទឹក ពិធីលៀងព្រះអម្ចាស់ និងការជាច្រើនទៀត។

មានពេលមួយ *ថូម៉ាស់វ៉េត* ធ្វើការជាអ្នកជំនួយការរបស់ជាងឈើម្នាក់សម្រាប់មុខជំនួញមួយ។ ជាងឈើទាំងអស់ធ្វើការជាក្រុម។ ថ្ងៃមួយជាងឈើ និង*ថូម៉ាស់* កំពុងធ្វើការនៅទីខ្ពស់នៃគម្រោងអាគារមួយ។ ជាងឈើដែល*ថូម៉ាស់*ធ្វើជាអ្នកជំនួយការឱ្យ ជាបុរសដែលមានមាឌធំហើយពីកន្លែងដែលនៅនោះវាខ្ពស់ ដូច្នេះគាត់មិនអាចកាត់ក្ដារដែលនៅលើគ្រោងនោះបានទេ។ ដូច្នេះ គាត់ក្រឡេកមើលជុំវិញប្រសិនជាមានអ្នកណាកំពុងតែមើល ហើយបន្ទាប់មកគាត់និយាយថា« *ថូម៉ាស់* ឯងកាត់ក្ដារនេះបានទេ!» *ថូម៉ាស់*និយាយថា «មិនអីទេ! តើមានបញ្ហាអ្វីបានជាលោកក្រឡេកមើលជុំវិញដូច្នេះ?»។ បន្ទាប់មកជាងឈើពន្យល់ថា បើលោកដូចដែល *ថូម៉ាស់* មិនមែនជាសមាជិកនៃក្រុមជាងឈើគាត់មិនអនុញ្ញាតឱ្យកាត់ក្ដារឬដំដែកគោលឡើយ។

នៅក្នុងប្រទេសជាច្រើនសព្វថ្ងៃនេះ ក្នុងកិច្ចការបម្រើព្រះទាល់តែគ្រូគង្វាលទើបអាចធ្វើទៅបាន ដូចជាការធ្វើពិធីជ្រមុជទឹក ពិធីលៀងព្រះអម្ចាស់ជាដើម ប៉ុន្តែសមាជិកធម្មតានៅក្នុងក្រុមជំនុំមិនអាចធ្វើទៅបានទេ។ ព្រះបន្ទូលរបស់ព្រះបានបង្រៀនយើងថា យើងទាំងអស់គ្នាជាអ្នកបម្រើព្រះទាំងអស់គ្នា *១ពេត្រុស ២:៥៤, ៥ «សូមបងប្អូនចូលមកជិតព្រះគ្រិស្ត ជាសិលាដ៏មានជីវិត ជាសិលាដែលមនុស្សលោកបានបោះបង់ចោល តែព្រះជាម្ចាស់បានរើសយក ព្រោះទ្រង់ឆ្វេងយល់ថាមានតម្លៃវិសេស។ រីឯបងប្អូនវិញ បងប្អូនប្រៀបបាននឹងថ្មដែលមានជីវិតដែរ ដូច្នេះចូរផ្គុំគ្នាឡើង កសាងព្រះដំណាក់របស់ព្រះវិញ្ញាណ ធ្វើជាក្រុមបូជាចារ្យដ៏វិសុទ្ធ ដើម្បីថ្វាយយញ្ញបូជាខាងវិញ្ញាណ ជាទីគាប់ព្រះហឫទ័យព្រះជាម្ចាស់ តាមរយៈព្រះយេស៊ូគ្រិស្ត»* ហើយនៅក្នុង *១ ពេត្រុស ២:៩ ចែងថា « រីឯលោកអ្នកវិញ ជាពូជដែលព្រះអង្គបានជ្រើសរើស ជា______________________________»*។

អ្នកជឿព្រះគ្រិស្ដនីមួយៗគឺជាសង្ឃ ជាអ្នកបម្រើព្រះជាម្ចាស់ និងគ្មានសហព័ន្ធការងារណា កិច្ចការជាក្រុមណាដែលមានឋានៈនៅឯនគរស្ថានសួគ៌នោះទេ។ គ្រូគង្វាលត្រូវបង្ហាញនូវតួនាទីរបស់គាត់ជាអ្នកបម្រើ អ្នកដឹកនាំខាងឯព្រលឹងវិញ្ញាណ ដែលជាអ្នកមានទំនាក់ទំនងគ្រប់ផ្នែកទាំងអស់នៃព័ន្ធកិច្ចបម្រើព្រះ។

ព្រះយេស៊ូគ្រិស្ដ បានចំណាយពេលបីឆ្នាំដើម្បីបង្វឹកបង្ហាត់សាវ័ករបស់ព្រះអង្គទាំង១២នាក់។ ព្រះអង្គជាគំរូមួយដ៏ឥតខ្ចោះពីការធ្វើឱ្យមានឥទ្ធិពលទៅលើពិភពលោក។ ព្រះអង្គបានប្រើគោលការណ៍ជាមូលដ្ឋានគ្រឹះមួយគឺ ការធ្វើពហុគុណ។ ទោះបីជាយ៉ាងណាក៏ដោយព្រះអង្គបានធ្វើនូវអ្វីដែលយើងគួរតែធ្វើ តើព្រះយេស៊ូបានធ្វើអ្វីខ្លះ?។

**ព្រះយេស៊ូមានកិច្ចការពីរយ៉ាង៖**

១. ព្រះអង្គមានកិច្ចការជាសាធារណៈព្រះអង្គបង្រៀនទៅកាន់ហ្វូងមនុស្ស។

២. ព្រះអង្គមានកិច្ចការផ្ទាល់ខ្លួន វាជាកិច្ចការផ្ទាល់ខ្លួនរបស់ព្រះអង្គដែលបានធ្វើឱ្យមានឥទ្ធិពលយ៉ាងអស្ចារ្យទៅលើពិភពលោក។

**នៅក្នុងកិច្ចការផ្ទាល់ខ្លួនរបស់ព្រះអង្គ ព្រះអង្គបានធ្វើការបីយ៉ាង៖**

១. ព្រះអង្គបានបង្កើតក្រុមសាវ័ក។ តើមានប៉ុន្មាននាក់នៅក្នុងក្រុមនោះ? ១២នាក់ លោកអ្នកមិនចាំបាច់ចាប់ផ្ដើមជាមួយនឹង១២នាក់នោះទេ។ ចាប់ផ្ដើមជាមួយនឹងម្នាក់ ប្រសិនជាអ្នកអាចធ្វើទៅបាន។ ប្រសិនបើលោកអ្នកមិនទាន់មានម្នាក់នៅឡើយ សូមឱ្យលោកអ្នករកម្នាក់ឱ្យបាន។

២. ព្រះអង្គបានបង្វឹកក្រុមរបស់ព្រះអង្គ។ ផ្នែកនៃការអនុវត្តមេរៀនអំពីអ្នកត្រួសត្រាយផ្លូវផ្សាយដំណឹងល្អនេះនឹងបង្រៀនលោកអ្នកពីរបៀបដែលលោកអ្នកអាចបង្វឹកបង្ហាត់ក្រុមរបស់លោកអ្នកបាន។

៣. ព្រះអង្គបានបញ្ជូនក្រុមឱ្យចេញ។ មានវិធីជាច្រើនក្នុងការដែលយើងនឹងបញ្ជូនសមាជិកក្រុមរបស់យើងចេញទៅ ដើម្បីធ្វើឱ្យក្រុមជុំនុំរបស់លោកអ្នករីកចម្រើននិងចាប់ផ្ដើមនូវក្រុមជំនុំថ្មីៗជាច្រើនទៀត។ នេះជាគំនិតសាមញ្ញៗពីរបៀបប្រើក្រុមដែលមានគ្នា១២នាក់៖

-ចែកទីក្រុង ឬសហគមន៍របស់អ្នកទៅជា១២ផ្នែក និងឱ្យមនុស្សពីសមាជិកក្រុមរបស់យើងធ្វើជាអ្នកគ្រប់គ្រងលើផ្នែកមួយនៃទីក្រុង ឬសហគមន៍នោះ។ ពួកគេ

នឹងទទួលខុសត្រូវសម្រាប់ការផ្សាយដំណឹងល្អនូវផ្នែកនៃទីក្រុង ឬសហគមន៍ដែលពួកគេកាន់កាប់នោះ។

-បញ្ជូនពួកគេឱ្យចេញទៅជាអ្នកគ្រប់គ្រងលើ១២ផ្នែកផ្សេងៗគ្នាជាមួយអ្នកជិតខាងនៅទីក្រុង ឬសហគមន៍ ដើម្បីចាប់ផ្ដើមនូវការងារថ្មីៗជាច្រើនទៀត។

-ឬក៏ការសម្រេចដែលមានតុល្យភាពច្រើនជាងនេះ គឺត្រូវបញ្ជូនក្រុមឱ្យទៅក្នុងសហគមន៍របស់អ្នកក្នុងការផ្សាយដំណឹងល្អ ដើម្បីឱ្យក្រុមជំនុំរបស់លោកអ្នកបានរីកចម្រើន និង បញ្ជូន ពាក់ កណ្ដាល ផ្សេង ទៀត ឱ្យ ចេញ ទៅ អ្នក ជិត ខាង ទីក្រុង ឬ ភូមិ ដើម្បី បង្កើត ការ ងារ ថ្មី ។ (ប្រធាន ក្រុម នីមួយៗ រាល់ ពេល ត្រូវ បង្កើន ក្រុម រង របស់ខ្លួន២នាក់ឬច្រើននាក់ឡើងទៅ ហើយចាប់ផ្ដើមបង្វឹកក្រុមរបស់ខ្លួននូវអ្វីដែលអ្នកបានរៀន ប្រធានក្រុមត្រូវ ទទួលខុសត្រូវក្នុងការផ្សាយដំណឹងល្អទៅដល់តំបន់ដែលបានគ្រោងទុករបស់ពួកគេ ឬចាប់ផ្ដើមនូវការងារថ្មី)។

អ្នក ត្រួស ត្រាយ ផ្លូវ សម្រាប់ ការ ផ្សាយ ដំណឹង ល្អ **នឹង <u>បង្កើត</u>** ក្រុម សិស្ស ផ្សាយ ដំណឹង ល្អមួយ នៃសមាជិកធម្មតារបស់នៃក្រុមជំនុំ ហើយ**<u>បង្វឹក</u>**ក្រុម នេះ ឱ្យផ្សាយ ដំណឹង ល្អ បង្កើត សិស្ស និង បង្កើត ក្រុម ជំ នុំ ព្រះវិហារ មេរៀន នេះ នឹង បង្រៀន លោកអ្នកពីរបៀបដូចនេះ ប៉ុន្តែជំហានដំបូងគឺត្រូវបង្កើនក្រុមរបស់អ្នកសិន។ប្រសិន ជា លោកអ្នក គ្មាន អ្នក ជឿ នឹង បង្វឹក បង្ហាត់ នោះ ទេ ។ ដូច្នេះ ដំបូង លោកអ្នក ត្រូវ ការ ផ្សាយដំណឹងល្អដើម្បីឱ្យពួកគេទទួលជឿព្រះជាមុនសិន។

ក្រោយពីលោកអ្នកបាននាំពួកគេបានទទួលជឿព្រះគ្រិស្តហើយ លោកអ្នកត្រូវ បង្រៀនពួកគេដោយយកចិត្តទុកដាក់ និង**បង្កើតជា ក្រុមសិស្សផ្សាយដំណឹងល្អ**។ គោលការរបស់លោកអ្នកគឺត្រូវបង្កើតក្រុមមួយនៃសិស្សរបស់អ្នកដែលអ្នកអាចបង្វឹក បង្ហាត់ពួកគេឱ្យក្លាយ ទៅជាអ្នក ត្រួស ត្រាយ ផ្លូវ សម្រាប់ ការ ផ្សាយ ដំណឹង ល្អ ហើយ បន្ទាប់មកត្រូវ **<u>បញ្ជូន</u>** ពួកគេឱ្យចេញទៅ។ ក្រុមសិស្សទាំងនេះ គឺជាអ្វីដែល យើង ហៅថា *អ្នកត្រួសត្រាយផ្លូវ* សម្រាប់មេរៀនបង្វឹកបង្ហាត់លើកនេះ។

គោលដៅគឺដើម្បីឱ្យអ្នកត្រួសត្រាយផ្លូវនីមួយៗបានក្លាយទៅជាអ្នកដឹកនាំត្រួសត្រាយផ្លូវសម្រាប់ការផ្សាយដំណឹងល្អ ហើយនឹងឱ្យគេបង្កើតនូវក្រុមសិស្ស ឬអ្នកត្រួសត្រាយផ្លូវដោយខ្លួនគេផ្ទាល់។ នេះគឺជាដំណាក់ទ្វេរធា។

**លោកអ្នកអាចនឹងបង្កើតក្រុមរបស់លោកអ្នកទៅតាមពីររបៀប៖**

១.ប្រកាសជាសាធារណៈពីវេទិកាថា៖ អ្នកត្រូវបង្កើតនូវក្រុមបង្កើតសិស្សមួយ និងអញ្ជើញឱ្យមនុស្សគ្រប់គ្នាបានចូលរួម។ ព្រះជាម្ចាស់នឹងរើសមនុស្សខ្លះដែលអ្នកមិនធ្លាប់គិតថា នឹងត្រូវរើសគេនោះ ។ ឧទាហរណ៍ៈ តើពលកអ្នកអាចជ្រើសរើសលោកម៉ាថាយដែលជាអ្នកទារពន្ធឱ្យធ្វើជាសិស្សរបស់លោកអ្នកដែរឬទេ?

២.ជាឯកជន៖ អធិស្ឋានទៅកាន់ព្រះ និងទូលសូមព្រះអង្គ ចំពោះអស់អ្នកដែលព្រះអង្គសព្វព្រះហឫទ័យនឹងចង់ឱ្យគេចូលមកក្នុងក្រុមរបស់លោកអ្នក។ បន្ទាប់មកចូលទៅកាន់ឯគេមួយទល់នឹងមួយ និងអញ្ជើញគេឱ្យមកចូលរួមនៅក្នុងក្រុមការងារបង្កើតសិស្ស។ ពន្យល់ថា យើងនឹងជួបគ្នាមួយសប្តាហ៍ម្តង។ លោកអ្នកនឹងបង្រៀន និងបង្វឹកពួកគេ បន្ទាប់មកបញ្ជូនពួកគេឱ្យទៅធ្វើការអនុវត្តកិច្ចការ ដើម្បីនាំមនុស្សឱ្យចូលទៅកាន់ព្រះយេស៊ូគ្រិស្ត។

**នៅក្នុងកិច្ចការអ្នកត្រួសត្រាយផ្លូវផ្សាយដំណឹងល្អអ្នកដឹកនាំត្រួសត្រាយផ្លូវសម្រាប់ការផ្សាយដំណឹងល្អត្រូវមានការទទួលខុសត្រូវ២យ៉ាងសំខាន់ៗ៖**

១. ការទទួលខុសត្រូវសំខាន់ដំបូងសម្រាប់អ្នកដឹកនាំត្រួសត្រាយផ្លូវសម្រាប់ការផ្សាយដំណឹងល្អគឺត្រូវបង្វឹកអ្នកត្រួសត្រាយផ្លូវពីម្នាក់ទៅម្នាក់ ឬជាក្រុមតូចៗ។ ការបង្វឹកបង្ហាត់នេះមិនមែនជាប្រភេទដែលអាចធ្វើទៅកើតជាមួយនឹងមនុស្សក្រុមធំនោះទេ។ គាត់គួរតែបង្វឹកបង្ហាត់ពួកគេជាក្រុមតូចៗ។

គ្រូគង្វាល និងអ្នកដឹកនាំទាំងអស់ត្រូវបង្កើតនូវក្រុមមួយ។ យើងសូមស្នើថាអ្នកមានមនុស្សចាប់ពី១ទៅដល់១២នាក់នៅក្នុងក្រុមរបស់អ្នក។ ក្រុមនេះនឹងក្លាយទៅជាសិស្សរបស់អ្នកដែលអ្នកនឹងត្រូវបង្វឹក។ ប្រសិនជាមិនទាន់មានអ្នកជឿក្នុងការបង្កើតក្រុមនោះទេ អ្នកគួរតែបង្កើតពីសូន្យឡើងទៅ។ ដំបូងនាំឱ្យពួកគេទទួលជឿព្រះ ហើយបង្វឹកក្រុមរបស់អ្នក។ ចំណុចគន្លឹះមួយគឺត្រូវមានជាទិសដៅ ដូចជាគម្រោងការរបស់អ្នកដើម្បីបង្កើតក្រុមនៃអ្នកត្រួសត្រាយ ឬសិស្ស។ អ្នកត្រូវជួបជាមួយក្រុមរបស់អ្នកជារៀងរាល់អាទិត្យសម្រាប់ការអធិស្ឋាន ផ្តល់ដំណឹង ការពិភាក្សា និងការបង្វឹកបង្ហាត់។

លោកបណ្ឌិត *វ៉េលិនម័រ* នៅក្នុងសៀវភៅរបស់គាត់ដែលមានចំណងជើងថា **ការបង្កើតសិស្សជាពហុគុណ** បានសរសេរដូចខាងក្រោម៖

ក. ការបង្កើតសិស្សជាវិធីមួយក្នុងចំណោមវិធីដ៏មានប្រសិទ្ធភាពបំផុតដើម្បីឱ្យមានកិច្ចការផ្ទាល់ខ្លួនដែលមិនកំណត់។

ខ. ការបង្កើតសិស្សជាកិច្ចការដែលងាយស្រួលបន់បែន ផ្លាស់ប្តូរបំផុត។

គ. ការបង្កើតសិស្សរហ័ស ហើយជារបៀបដែលមានសុវត្ថិភាពបំផុតដើម្បីរៀបចំរូបកាយនៃព្រះគ្រិស្តសម្រាប់ការផ្សាយដំណឹងល្អ។

ឃ. ការបង្កើតសិស្សមានឥទ្ធិពលយូរអង្វែងក្នុងការបង្កើតផលផ្លែជាងកិច្ចការផ្សេងដទៃទៀត។

ង. ការបង្កើតសិស្ស បង្កើតអ្នកដឹកនាំដែលមានជំនឿរឹងមាំសម្រាប់ក្រុមជំនុំដែលជាអ្នកទុកព្រះគ្រិស្តជាធំ ផ្តោតសំខាន់ និងរៀនអំពីព្រះគ្រិស្ត ហើយតម្រង់ទៅនៅក្នុងព្រះបន្ទូលនៃព្រះ។

២. ការទទួលខុសត្រូវទីពីរសម្រាប់អ្នកដឹកនាំត្រួសត្រាយផ្លូវសម្រាប់ការផ្សាយដំណឹងល្អ គឺត្រូវនៅតែទាក់ទងប្រចាំសប្តាហ៍ជាមួយនឹងអ្នកត្រួសត្រាយផ្លូវ។ អ្នកដឹកនាំត្រួសត្រាយផ្លូវសម្រាប់ការផ្សាយដំណឹងល្អគួរតែចំណាយពេលយ៉ាងហោចណាស់មួយម៉ោងក្នុងសប្តាហ៍នីមួយៗជាមួយនឹងក្រុមអ្នកត្រួសត្រាយផ្លូវរបស់គាត់។ យ៉ាងហោចណាស់អ្នកត្រូវជួបគ្នាម្តងក្នុងមួយសប្តាហ៍ដើម្បីឱ្យស្គាល់ពីការរស់នៅរបស់ពួកគេ។

**តើយើងនឹងត្រូវធ្វើអ្វីនៅក្នុងការប្រជុំទាំងនេះ៖**

ក. អ្នកដឹកនាំត្រួសត្រាយផ្លូវសម្រាប់ការផ្សាយដំណឹងល្អគួរតែចាប់ ផ្តើម ការប្រជុំដោយសេចក្តីអធិស្ឋាន។ យើងនៅក្នុងចន្លោះកណ្តាលរវាងសង្គ្រាមព្រលឹងវិញ្ញាណ ហើយអ្វីដែលអាចនឹងការពាររបស់យើងមានតែមួយគត់គឺសេចក្តីអធិស្ឋាន។

ខ. សុំឱ្យអ្នកត្រួសត្រាយផ្លូវសម្រាប់ការផ្សាយដំណឹងល្អនីមួយៗចែកចាយនូវជ័យជំនះរបស់ពួកគេនៅក្នុងសប្តាហ៍ដែលគេបានធ្វើ។

គ. សុំឱ្យអ្នកត្រួសត្រាយផ្លូវសម្រាប់ការផ្សាយដំណឹងល្អនិយាយភ្ជាប់ទៅនឹងបញ្ហាដែលពួកគេបានជួបប្រទះនៅក្នុងកំឡុងពេលមួយសប្តាហ៍ និងកត់សំគាល់សម្រាប់ពួកគេម្នាក់ៗ។

ឃ. ជួយឱ្យយោបល់ដោះស្រាយបញ្ហាមួយៗដែលពួកគេមានអំពីបញ្ហានីមួយៗ។

ង. បង្ហឹកឱ្យក្រុមចេះប្រើនូវផ្នែកអនុវត្តនៃមេរៀន *អ្នកត្រួសត្រាយផ្លូវសម្រាប់*

*ការផ្សាយដំណឹងល្អ* ។ ឧទាហរណ៍ៈ រៀនឡើងវិញនូវជំពូកដោយដាក់ចំណងជើងថា «របៀបនៃការចែកចាយទីបន្ទាល់របស់អ្នក » ឬ «ការផ្សាយដំណឹងល្អ»ដើម្បីធ្វើឱ្យប្រាកដថាអ្នកត្រួសត្រាយស្គាល់ពីរបៀបនាំព្រលឹងវិញ្ញាណដែលបាត់បង់ទៅកាន់ព្រះជាម្ចាស់។ ឬប្រហែលជាវានឹងមានសារៈសំខាន់ក្នុងការរំលឹកឡើងវិញនូវជំពូកមេរៀនដែលមានចំណងជើងថា «សេចក្តីអធិស្ឋាន» «វិធីមិនផ្ទាល់» ឬក៏ «ពីរបៀបបង្វឹកអ្នកដឹកនាំក្នុងតំបន់» ជាដើម។ សូមឱ្យប្រើពេលវេលានេះដើម្បីបង្វឹកពួកគេ។

ច. បង្រៀនពួកគេនូវដំណាក់កាលនៃការអនុវត្តព័ន្ធកិច្ចដូចជា របៀបសរសេរសេចក្តីអធិប្បាយ របៀបឱ្យចេះផ្តល់គំនិតជាដើម។ វាជាការទទួលខុសត្រូវនៃអ្នកដឹកនាំត្រួសត្រាយផ្លូវសម្រាប់ការផ្សាយដំណឹងល្អ ដើម្បីបង្វឹកអ្នកត្រួសត្រាយទាំងនោះឱ្យបានល្អប្រសើរ។

ឆ. សូមឱ្យទៅអ្នកត្រួសត្រាយផ្លូវនូវការបង្ហាញជាទូទៅមួយ និងបញ្ចប់ការប្រជុំដោយសេចក្តីអធិស្ឋាន។ (ចូរក្រឡេកទៅមើលនូវការស្នើសុំការអនុវត្តផ្សេងទៀតនៅក្នុងជំពូកដែលមានចំណងជើងថា «ការតាមដានប្រចាំសប្តាហ៍នៃអ្នកត្រួសត្រាយផ្លូវ ចំពោះអ្នកដែលគេផ្សាយដំណឹងល្អដល់») ។

ប្រសិនបើជាអ្នកត្រួសត្រាយផ្លូវសម្រាប់ការផ្សាយដំណឹងល្អរស់នៅឆ្ងាយពេក អ្នកដឹកនាំត្រួសត្រាយផ្លូវសម្រាប់ការផ្សាយដំណឹងល្អគួរតែមានការប្រជុំរយៈពេលមួយខែម្តងឬរៀងរាល់២ខែម្តង។ គាត់ក៏អាចនៅតែមានការទាក់ទងតាមរយៈការសរសេរសំបុត្រផងដែរ ។ នេះគឺជាអ្វីដែលសាវកប៉ុលបានធ្វើវាមានសារៈសំខាន់ណាស់ដែលអ្នកដឹកនាំត្រួសត្រាយផ្លូវសម្រាប់ការផ្សាយដំណឹងល្អសួរសុខទុក្ខឱ្យបានទៀងទាត់ពេលវេលាដល់អស់អ្នកត្រួសត្រាយផ្លូវសម្រាប់ការផ្សាយដំណឹងល្អហើយនឹងថែរក្សាក្រុមប្រជុំរបស់គាត់។

- តើមុខងារសំខាន់របស់អ្នកដឹកនាំ ឬ គ្រូគង្វាលជាអ្វី?

---

- តើលោកអ្នកនឹងប្តេជ្ញាចិត្តបង្កើតក្រុមសិស្ស និងបង្វឹកពួកគេ ហើយនឹងបញ្ជូនពួក

គេឱ្យចេញទៅដែរឬទេ?

---

## VI. ក្រុមបង្កើតសិស្សផ្សាយដំណឹងល្អ

មានគោលបំណង ៦៖

១. នាំព្រលឹងដែលបាត់បង់ឱ្យបានទទួលជឿព្រះយេស៊ូ
២. ធ្វើពិធីជ្រមុជទឹកឱ្យអ្នកដែលជឿថ្មី
៣. តាមដានអ្នកដែលគេបានផ្សាយដំណឹងល្អ និងបង្រៀនអ្នកជឿថ្មី
៤. បង្វឹកអ្នកដឹកនាំក្នុងតំបន់
៥. រៀបចំក្រុមជំនុំថ្មីឱ្យចេះផ្គត់ផ្គង់ខ្លួនឯង រៀបចំខ្លួនឯង និងជួយឱ្យខ្លួនឯងរីកចម្រើននឹងបង្កើតក្រុមជំនុំជាច្រើនទៀត។
៦. ចាប់ផ្តើមបង្កើននូវចំនួនអ្នកធ្វើការឱ្យកាន់តែច្រើនកាន់តែឆាប់កាន់តែល្អអ្នកត្រួសត្រាយផ្លូវនីមួយៗ និងបន្ទាប់មកបង្កើតក្រុមថ្មី និងបង្វឹកពួកគេឱ្យចាប់ផ្តើមនូវកិច្ចការថ្មី។

## VII. មូលដ្ឋានគ្រឹះ៩ចំណុចនៃជ័យជំនះក្នុងការបង្កើតក្រុមជំនុំ

ក. កំណត់ចំណាំមនុស្សដែលមានអំណោយទានក្នុងការបង្កើតសកិច្ចការថ្មី រ៉ូម ១២:៦-៨, ១ កូរិនថូស ១២:៤-១១។
ខ. បង្កើននូវអ្នកដឹកនាំដែលចេញមកពីសមាជិកក្រុមជំនុំធម្មតា។
គ. មានការយល់ដឹងព្រះគម្ពីរច្បាស់លាស់ពីគោលបំណងរបស់ក្រុមជំនុំ។ ក្រុមជំនុំគឺ

**គោលបំណងទាំង៥របស់ក្រុមជំនុំគឺ ៖កិច្ចការ ២:៤២-៤៧**

១. សរសើរដំកើង
២. ផ្សាយដំណឹងល្អ
៣. បង្កើតសិស្ស
៤. ព័ន្ធកិច្ចបម្រើ

៥. ប្រកបគ្នា

**និស្ស័យរបស់ក្រុមជំនុំគឺ៖**

១. ការចាត់ចែងដោយខ្លួនឯងនៅក្រោមការដឹកនាំរបស់ព្រះជាម្ចាស់។
២. ការផ្គត់ផ្គង់ដោយខ្លួនឯងនៅក្រោមការដឹកនាំរបស់ព្រះជាម្ចាស់។
៣. ការជួយឱ្យក្រុមជំនុំរីកចម្រើន និងបង្កើតក្រុមជំនុំជាច្រើនទៀត ដោយខ្លួនឯងនៅក្រោមការដឹកនាំរបស់ព្រះជាម្ចាស់។

**ឃ**.កំណត់សំគាល់តំបន់ដែលមានការចាប់អារម្មណ៍។

**ង**. ចែកចាយជំនឿរបស់លោកអ្នកនៅក្នុងព្រះគ្រិស្តឱ្យបានខ្លាំងក្លា (ទំនុកដំកើង ១២៦:៦)។

**ច**. សង្កត់ធ្ងន់ថាការចាប់ផ្ដើមនៃក្រុមជំនុំគឺនៅតាមផ្ទះ។

តើក្រុមជុំនុំទើបបង្កើតថ្មីជួបគ្នានៅកន្លែងណានៅក្នុងខទាំងនេះ?

កិច្ចការ ១៦:៤០________________________________

១៧:៥-៧________________________________

១៨:៧________________________________

១៩:៩________________________________

២០:២០________________________________

តើកិច្ចការរបស់សាវកប៉ូលមានលទ្ធផលអ្វីខ្លះ?

កិច្ចការ ១៩:១០________________________________

តើគាត់ធ្វើដោយរបៀបណា? ២ ធីម៉ូថេ ២:២ «សេចក្ដីទាំងអស់ដែលអ្នកបានឮពីខ្ញុំនៅមុខសាក្សីជាច្រើននាក់ ត្រូវប្រគល់ឱ្យលោកអ្នកណាដែលស្មោះត្រង់ និងមានសមត្ថភាពអាចបង្រៀនបន្តទៅអ្នកផ្សេងទៀតចុះ»។

**តើគន្លឹះអ្វីចំពោះជ័យជំនះរបស់គាត់?**

________________________________

**ឆ**. ផ្ដល់នូវកម្មវិធីថ្វាយបង្គំដែលមានអំណរនៅកន្លែងដែលអ្នកជឿនឹងបានសប្បាយ។

**ជ**. កុំដាក់បន្ទុកនៃទ្រព្យសម្បត្តិនៅលើមនុស្ស។

ឈ.មានជាឱកាសពីការចាប់ផ្តើម នៃការងារដែលការងារថ្មីនឹងកើនឡើងយ៉ាងឆាប់រហ័សដូចដែលអាចធ្វើទៅបានជាមួយនឹងគោលការណ៍ទាំងពីរនេះ៖

១. ចាប់ផ្តើមនូវកិច្ចការមួយចំនួន នៅពេលតែមួយទៅតាមការបង្វឹកសមាជិកក្រុមជំនុំ។

២. បង្វឹកអ្នកដែលមានជំនឿថ្មីនៅក្នុងកិច្ចការថ្មីដើម្បីទទួលនូវទស្សនៈក្នុងការចាប់ផ្តើមបង្កើនកិច្ចការថ្មីក្នុងពេលតែមួយ។

## VIII. គន្លឹះ៦យ៉ាងដើម្បីឈាននៅរកការរីកចម្រើននៃក្រុមជំនុំ ក្រោយពេលដែលក្រុមជំនុំទាំងនោះត្រូវបានបង្កើត

ក. ព័ន្ធកិច្ចអធិស្ឋាន

ខ. ព័ន្ធកិច្ចសរសើរដំកើង

១. ពិធីជ្រមុជទឹក
- បេក្ខជនត្រឹមត្រូវ (ស្ម័គ្រចិត្ត)
- អំណាចច្បាប់ដ៏ត្រឹមត្រូវ
- អ្នករៀបចំដ៏ត្រឹមត្រូវ
- វិធីដ៏ត្រឹមត្រូវ
- គោលបំណងដ៏ត្រឹមត្រូវ

២. ពិធីលៀងព្រះអម្ចាស់
- អ្នកចូលរួមត្រឹមត្រូវ
- ច្បាប់ដ៏ត្រឹមត្រូវ
- អ្នករៀបចំដ៏ត្រឹមត្រូវ
- គោលបំណងដ៏ត្រឹមត្រូវ

គ. ព័ន្ធកិច្ចផ្សាយដំណឹងល្អ

ឃ. ព័ន្ធកិច្ចបង្កើតសិស្ស

ង. ព័ន្ធកិច្ចក្នុងការចុះទៅប្រកបភាពស្និទស្នាលជាមួយនឹងក្រុមជំនុំ

ច. រដ្ឋបាលត្រឹមត្រូវ

## IX. ចរិតលក្ខណៈ៣យ៉ាងនៃក្រុមជំនុំនៅសម័យសញ្ញាថ្មី

## ក. ការចាត់ចែងដោយខ្លួនឯងនៅក្រោមការដឹកនាំរបស់ព្រះជាម្ចាស់

គោលការណ៍នៃការគ្រប់គ្រងចាត់ចែងដោយខ្លួនឯង គឺមានសារៈសំខាន់បំផុតសម្រាប់ អស់ អ្នក ដែល ជឿ លើ ការ ដើរ តាម លទ្ធិ ប្រជាធិបតេយ្យ ។ លទ្ធផល នៃគោលការណ៍នេះនៅក្នុងជីវិតខាងឯព្រលឹងវិញ្ញាណរបស់ក្រុមជំនុំគឺមានសារៈសំខាន់បំផុតដែលថា ប្រសិនជាមានការខកខានការបរាជ័យណាមួយនៅក្នុងផ្នែកនេះការខំប្រឹងប្រែងទាំងអស់នៃការបង្កើតក្រុមជំនុំថ្មី នោះក្រុមជំនុំដែលជួយខ្លួនឯងដែលមិនពឹងលើអ្នកអ្នកណាអាចត្រូវព្រមព្រៀងគ្នា។

លទ្ធផលនៃការគ្រប់គ្រងចាត់ចែងដោយខ្លួនឯងនាំឱ្យមានការទទួលខុសត្រូវខាងព្រលឹងវិញ្ញាណក្នុងតំបន់នៃការផ្គត់ផ្គង់ដោយខ្លួនឯង និងការធ្វើឱ្យខ្លួនឯងរីកចម្រើនឡើងដោយខ្លួនឯង។ ការបរាជ័យ ដើម្បីដាក់ការទទួលខុសត្រូវនៃការគ្រប់គ្រងដោយខ្លួនឯងនៅក្នុងជីវិតរបស់អ្នកជឿនាំឱ្យរាំងស្ទះដល់ការខិតខំប្រឹងប្រែងចាប់ផ្តើមក្រុមជំនុំថ្មី។

**យើងគួរតែសង្កេតមើលនូវជំហានអនុវត្តខ្លះៗ៖**

១. អ្នកត្រួសត្រាយផ្លូវសម្រាប់ការផ្សាយដំណឹងល្អនឹងចូលទៅក្នុងទីក្រុង ណរិងនាំព្រលឹងវិញ្ញាណដែលបាត់បង់សម្រាប់ព្រះគ្រិស្ត។
២. គាត់នឹងបង្រៀនព្រះគម្ពីរ និងគោលលទ្ធិមូលដ្ឋានដោយប្រើនូវវិធីមិនផ្ទាល់ដែលបង្កើតឡើងដោយលោក *ឆាលស៍ ប្រក់* ការនិទានរឿងឬក៏វិធីផ្សេងដទៃទៀត។
៣. អ្នកជឿថ្មីនឹងត្រូវបានបង្រៀន និងជ្រមុជទឹក។
៤. ព្រះវិញ្ញាណបរិសុទ្ធនឹងជ្រើសរើសអ្នកដឹកនាំនៅក្នុងតំបន់តាមរយៈមធ្យោបាយជាច្រើន ប្រសិនបើអ្នកត្រួសត្រាយផ្លូវព្រមនឹងអនុញ្ញាតឱ្យព្រះអង្គធ្វើការនេះ។ អ្នកទទួលជឿថ្មីនឹងរៀនពីគោលលទ្ធិនៅក្នុងព្រះគម្ពីរ។
៥. អ្នកជឿថ្មីដែលយល់ព្រមនឹងគោលលទ្ធិនឹងរៀបចំគម្រោងដើម្បីរៀបចំក្រុមជំនុំ។
៦. ក្រុមនៅក្នុងតំបន់នឹងជ្រើសរើសអ្នកដឹកនាំរបស់គេ។

## ខ. ការផ្គត់ផ្គង់ដោយខ្លួនឯងនៅក្រោមការដឹកនាំរបស់ព្រះជាម្ចាស់

នៅពេលក្រុមជំនុំថ្មីមានការតស៊ូ ហើយខំស្វះស្វែងវានឹងរីកចម្រើន។ បេសកជន *ឆាលស៍ ប្រក់* ពន្យល់នៅក្នុងសៀវភៅរបស់គាត់ *«ការបង្កើតក្រុមជំនុំនៃអ្នកផ្សាយដំណឹងល្អក្នុងតំបន់ជនជាតិភាគតិច»* អ្វីដែលជាលទ្ធផលនោះគឺដូចថា នៅ

ពេល មនុស្ស ម្នាក់ព្យាយាមជួយសត្វមេអំបៅមួយឱ្យរួចពីសំបុករបស់វាដូច្នោះដែរ ។ មេអំបៅតស៊ូចេញពីសំបុករបស់វា ហើយមនុស្សគ្រាន់តែអាចនឹងរងចាំមើលទៅបានហើយ ។ ប្រសិនជាមាននរណាម្នាក់បាត់បង់ការអត់ធ្មត់ ហើយនៅតែចង់ជួយដុកដឿរដោយកាត់សរសៃរសូត្រជាមួយនឹងកាំបិត នោះការតស៊ូរបស់សត្វនោះនឹងត្រូវចប់ ។ យ៉ាងណាមិញលទ្ធផលនៃមេអំបៅនោះនឹងត្រូវរស់នៅក្នុងពេលតែ២ឬ៣នាទីប៉ុណ្ណោះ ។ ការជួយរបស់អ្នកឈរមើលនោះបាននាំលងច្បាប់របស់ជីវិតមួយហើយ ។ ប្រសិនជាមនុស្សម្នាក់នោះគ្រាន់តែអនុញ្ញាតឱ្យមេអំបៅនោះតស៊ូនៅក្នុងសំបុករបស់វា នោះលទ្ធផលរបស់មេអំបៅនោះ វានឹងមានកម្លាំងខ្លាំងស្អាត និងធំធាត់បានល្អ ។

ដូចដែលបញ្ហាដែលអ្នកជឿក្នុងស្រុកបានជួបអ្នកជឿនៅក្នុងតំបន់មានការតស៊ូដើរនៅក្នុងសេចក្តីជំនឿ និងដើរតាមព្រះទុកចិត្តលើព្រះជាម្ចាស់នឹងផ្គត់ផ្គង់អស់ទាំងតម្រូវការគ្រប់យ៉ាងពួកគេនឹងរីកលូតលាស់រឹងមាំឡើងនៅក្នុងសេចក្តីជំនឿរបស់ពួកគេនឹងក្លាយទៅជាអ្វីដែលព្រះជាម្ចាស់សព្វព្រះហឫទ័យឱ្យពួកគេទៅជាយ៉ាងនោះ ។

ព្រះវិហារជាច្រើនមានសញ្ញានៅពីមុខអាគាររបស់ពួកគេជាមួយនឹងឈ្មោះនៃក្រុមជំនុំ ។ ឧទាហរណ៍ៈក្រុមជំនុំភ្លើងឆេះរទេះ ។ ប៉ុន្តែ វាអាចនិយាយបានថា «ក្រុមជំនុំភ្លើងឆេះរទេះជួបគ្នានៅទីនេះ» ។ តើវាខុសប្លែកគ្នាយ៉ាងដូចម្តេច? ស្លាកសញ្ញាទីមួយចង់មានន័យថា អគារគឺជាក្រុមជំនុំ ប៉ុន្តែស្លាកសញ្ញាទីពីរចង់បង្ហាញថា មនុស្សទាំងអស់នៅក្នុងក្រុមជំនុំគឺជាក្រុមជំនុំ ហើយថា ពួកគេអាចជួបគ្នានៅកន្លែងណាក៏បានដែរ ។

មើលមកទំរង់នេះដើម្បីបង្ហាញពីតម្លៃនៃការបង្កើតក្រុមជំនុំមួយដោយប្រើនូវវិធីដែលធ្វើទៅតាមទំនៀមទម្លាប់ៈ

- ប្រាក់ខែសម្រាប់អ្នកបង្កើតក្រុមជំនុំក្នុង១ខែ__________x ១២ខែ x ៧ឆ្នាំៈ______
__________________________________________ ។

- ការជួលផ្ទះរបស់អ្នកបង្កើតក្រុមជំនុំក្នុង១ខែ__________x ១២ ខែ x ៧ឆ្នាំៈ___
__________________________________________ ។

- សំភារៈ ឬ ទ្រព្យសម្បត្តិៈ______________________________________

អគារៈ______________________________________________

- ចំណាយសរុបសម្រាប់ក្រុមជំនុំមួយៈ__________________________________

### គ. ការធ្វើឱ្យរីកចម្រើនដោយខ្លួនឯង នៅក្រោមការដឹកនាំរបស់ព្រះជាម្ចាស់

ក្រុមជំនុំនៅសម័យសញ្ញាថ្មីគឺរីកចម្រើនដោយខ្លួនឯងដោយគ្មានទទួលការទំនុកបំរុងពីសំណាក់នរណាម្នាក់ឡើយ។ ទៅតាមលក្ខណធម្មជាតិរបស់ក្រុមជំនុំនៅសម័យនោះវាគួរតែចែកចាយនូវជីវិតរបស់ក្រុមជំនុំនោះជាមួយនឹងអ្នកដទៃទៀត។ ក្រុមជំនុំប្រភេទនេះគឺជាក្រុមជំនុំផ្សាយដំណឹងល្អ និងមានចិត្តឆេះឆួលក្នុងការបង្កើតព្រះវិហារថ្មី។

ជាមួយនឹងមនុស្សទាំងអស់បានបែកខ្ញែកគ្នាជុំវិញពិភពលោកយើងគួរបង្កើតក្រុមជំនុំដែលដូចគ្នានឹងក្រុមនៅសម័យសញ្ញាថ្មីដែលអាចនឹងបង្កើតក្រុមជំនុំផ្សេងទៀត។ ដូច្នេះយើងអាចឈោងទៅចាប់ហ្វូងមនុស្សនៅគ្រប់ទីក្រុង និងភូមិទាំងអស់។

នៅក្នុងការចាប់ផ្តើមអ្នកត្រួសត្រាយផ្លូវគឺជាអ្នកផ្សាយដំណឹងល្អ។ គាត់នាំព្រលឹងវិញ្ញាណដែលបាត់បង់ទៅឯព្រះគ្រិស្តបង្ហឹក និងបង្រៀនអ្នកជឿថ្មីទាំងនេះនូវគោលលទ្ធិមូលដ្ឋាននៃសេចក្តីជំនឿ។ ជំហ៊ានបន្ទាប់គឺត្រូវសួរទៅកាន់ព្រះជាម្ចាស់ដើម្បីឱ្យព្រះអង្គរើសអ្នកដឹកនាំនៅក្នុងតំបន់ និងបង្ហឹកពួកអ្នកជឿថ្មីទាំងនេះដើម្បីឱ្យពួកគេចាប់ផ្តើមបង្កើតការងារថ្មីផ្សេងទៀតនៅក្នុងទីកន្លែង និងទីក្រុងថ្មីៗជាច្រើន។

ដំណើរការនេះបន្តដូចជាក្រុមជំនុំជាច្រើន ហើយក្រុមជំនុំនោះទៅបង្កើតក្រុមជំនុំជាច្រើនទៀត គឺបង្កើតបន្តគ្នា។ អ្នកត្រួសត្រាយផ្លូវសម្រាប់ការផ្សាយដំណឹងល្អគួរតែបន្តបង្ហឹកអ្នកដឹកនាំនៅក្នុងតំបន់ទាំងនេះ និងរៀបចំក្រុមផ្សេងមួយទៀតទៅក្នុងក្រុមជំនុំ។ បន្ទាប់មកគាត់គួរតែទុកការងារឱ្យទៅអ្នកដឹកនាំក្នុងតំបន់នោះទៅ ប៉ុន្តែ នៅតែបន្តទៅសួរសុខទុក្ខពួកគេដើម្បីជួយ និងលើកទឹកចិត្តពួកគេ។

## X. សេចក្តីបញ្ចប់

អ្នកត្រួសត្រាយផ្លូវផ្សាយដំណឹងល្អដែលចង់បានទទួលជោគជ័យក្នុងការបង្កើតក្រុមជំនុំនោះអ្នកគួរតែ៖

ក). ត្រូវរីកចម្រើនខាងឯព្រលឹងវិញ្ញាណរៀបចំ និងបង្ហឹកឱ្យបានល្អ។
ខ). ដឹងពីរបៀបបង្កើត និងបង្រៀននូវក្រុមផ្សាយដំណឹងល្អ។
គ). ចេញទៅនាំអ្នកដែលបាត់បង់មកឯព្រះគ្រិស្ត កុំហៅគេឱ្យចូលមករក

អ្នកដើម្បីឱ្យអ្នកផ្សាយដំណឹងល្អឱ្យសោះ ព្រះយេស៊ូមានបន្ទូល
ថា(ចូរចេញទៅ)។

ឃ). ចាប់ផ្តើមនូវកម្មវិធីដែលសប្បាយ និងមានអំណរ។

ង). ដឹងពីរបៀបចុះទៅបង្រៀនផ្ទាល់ និងបង្កើតអ្នកជឿថ្មីៗ។

ច). ដឹងពីរបៀបបង្វឹកអ្នកដឹកនាំថ្មីៗ។

ឆ). ដឹងពីរបៀបធ្វើពិធីជ្រមុជទឹកដល់អ្នកជឿថ្មី និងធ្វើពីធីលៀងព្រះអម្ចាស់

ជ). បង្វឹកមនុស្សនៅក្នុងតំបន់ពីរបៀបនាំអ្នកដែលបាត់បង់ទៅឯព្រះ និងដឹក
នាំការសិក្សាព្រះគម្ពីរនៅតាមផ្ទះអ្នកដែលមិនទាន់ជឿ។

ឈ).បង្វឹកអ្នកដឹកនាំក្នុងតំបន់ដើម្បីដឹកនាំក្រុមជំនុំថ្មី។

ញ). ដឹកនាំក្រុមជំនុំឱ្យចេះមានការរៀបចំដោយខ្លួនឯងផ្គត់ផ្គង់ដោយខ្លួន
ឯង និងចេះធ្វើឱ្យរីកចម្រើនដោយខ្លួនឯង។

ដ). បង្វឹកអ្នកជឿថ្មីពីរបៀបបង្កើតនូវក្រុមផ្សាយដំណឹងល្អរបស់ខ្លួនគេផ្ទាល់
ដើម្បីចាប់ផ្តើមនូវការងារថ្មី។

# ផ្នែកទី២

## ចំណុចអនុវត្តន៍ជាក់ស្តែង

PRACTICAL ASPECTS

## អ្វីដែលត្រូវបង្រៀន
## ក្រុមរបស់លោកអ្នក

WHAT TO TEACH YOUR TEAM

# ចំណុចអនុវត្តន៍ជាក់ស្តែង

តើត្រូវបង្ហាត់ក្រុមរបស់អ្នកយ៉ាងដូចម្តេច?

នៅក្នុងផ្នែកនេះនៅក្នុងសៀវភៅក្បួនខ្នាតនេះ នឹងពន្យល់អំពីរបៀបដែលអ្នកត្រួសត្រាយផ្លូវផ្សាយដំណឹងល្អ នឹងបំពេញព័ន្ធកិច្ចរបស់ខ្លួនក្នុងរបៀបជាក់ស្តែង។ វិធីសាស្ត្រទាំងនេះនឹងមានប្រសិទ្ធភាព ប្រសិនបើត្រូវបានអនុវត្តនៅក្រោមការដឹកនាំរបស់ព្រះវិញ្ញាណបរិសុទ្ធ។ មូលហេតុដែលវិធីសាស្ត្រទាំងអស់នេះមានប្រសិទ្ធភាពគឺព្រោះតែត្រូវបានទទួលការបណ្តាលចិត្តពីព្រះវិញ្ញាណបរិសុទ្ធ និងត្រូវបានកត់ត្រានៅក្នុងគម្ពីរសញ្ញាថ្មី។ អ្នកត្រួសត្រាយផ្លូវផ្សាយដំណឹងល្អកំពុងតែអនុវត្តវិធីសាស្ត្រផ្សាយដំណឹងល្អនៃគម្ពីរសញ្ញាថ្មី នៅក្នុងបរិបទសម័យទំនើបរបស់យើង។

## ផ្នែកទី១: របៀបចាប់ផ្តើមក្រុមថ្មី ឬក្រុមជំនុំថ្មី

**I. របៀបស្វែងរកមនុស្សកំពុងស្វែងរកសេចក្តីសុខសាន្ត**

**II. របៀបបង្ហាញសេចក្តីស្រឡាញ់របស់ព្រះជាម្ចាស់ក្នុងវិធីជាក់ស្តែង**

**III. របៀបធ្វើតាមគោលការណ៍ អយខស** (OIKOS)

**IV. របៀបដឹកនាំការសិក្សាព្រះគម្ពីរ**

**ក. របៀបដឹកនាំការសិក្សាព្រះគម្ពីរបែបផ្សាយដំណឹងល្អ**

**១. ការនិទានរឿង** ***ដំណឹងល្អរបស់ព្រះយេស៊ូ***

**ដោយ គ្រីស្ទី ប្រូនើរ**

២. វិធីដោយប្រយោល ដោយ ឆាលស៍ ប្រក់

*ដំណឹងល្អមកពីព្រះជាម្ចាស់* ដោយ ទេឡូន មរ

ខ. របៀបដឹកនាំការសិក្សាព្រះគម្ពីរបែបថៃបំប៉ន

*ការចាប់ផ្តើមជីវិតថ្មីជាមួយព្រះយេស៊ូ*

ដោយ គ្រីស្ទី ប្រនើរ

ផ្នែកទី២: របៀបបង្ហាត់ក្រុមរបស់លោកអ្នក

I. អ្នកត្រួសត្រាយផ្លូវផ្សាយដំណឹងល្អ និងព្រះវិញ្ញាណបរិសុទ្ធ

II. អ្នកត្រួសត្រាយផ្លូវផ្សាយដំណឹងល្អ និងការអធិស្ឋាន

III. អ្នកត្រួសត្រាយផ្លូវផ្សាយដំណឹងល្អ និងការសង្គ្រោះ

IV. អ្នកត្រួសត្រាយផ្លូវផ្សាយដំណឹងល្អ និងទីបន្ទាល់ផ្ទាល់ខ្លួន

V. អ្នកត្រួសត្រាយផ្លូវផ្សាយដំណឹងល្អ និងការផ្សាយដំណឹងល្អផ្ទាល់ខ្លួន—ខគម្ពីរប្រាំមួយដែលពន្យល់អំពីដំណឹងល្អ

## ផ្នែកទី១: របៀបចាប់ផ្តើមក្រុមថ្មី ឬក្រុមជំនុំថ្មី

## I. របៀបស្វែងរកមនុស្សកំពុងស្វែងរកសេចក្តីសុខសាន្ត

អ្នកត្រួសត្រាយផ្លូវត្រូវមានជំនឿចិត្តថា ព្រះវិញ្ញាណបរិសុទ្ធកំពុងតែដឹកនាំខ្លួន ហើយថា ព្រះអង្គកំពុងតែរៀបចំចិត្តរបស់ពួកអ្នកដែលបាត់បង់។

លូកា ១០:៥-៦

<u>សំណួរសម្រាប់វប្បធម៌ដែលគ្មានប្រវត្តិគ្រិស្តបរិស័ទ</u>

១. តើអនុញ្ញាតឱ្យខ្ញុំសួរសំណួរខាងវិញ្ញាណមួយដល់អ្នកបានដែរឬទេ?
២. តើអ្នកយល់ដូចម្តេចចំពោះព្រះ?
៣. តើអ្នកចង់ដឹងអំពីព្រះអាទិករដោយផ្ទាល់ដែរឬទេ?
៣. តើខ្ញុំអាចចែកចាយកជាមួយអ្នក អំពីរឿងព្រះអាទិករបានដែរឬទេ?

<u>សំណួរសម្រាប់វប្បធម៌ដែលមានប្រវត្តិគ្រិស្តបរិស័ទ</u>

១. តើអ្នកបានចូលមកដល់នៃចំណុចមួយនៃជីវិតរបស់អ្នកដែលមានការទំនាក់ទំនងដោយផ្ទាល់ជាមួយនឹងព្រះយេស៊ូគ្រិស្តហើយឬនៅ ឬតើអ្នកកំពុងតែធ្វើដំណើរមកកាន់ចំណុចនេះ?
២. ប្រសិនបើអ្នកស្លាប់នៅក្នុងយប់នេះ តើអ្នកប្រាកដថាអ្នកបានទៅស្ថានសួគ៌ដែរឬទេ?
៣. តើអ្នកចាប់អារម្មណ៍ចង់រៀនព្រះគម្ពីរនៅក្នុងផ្ទះអ្នកដែរឬទេ?

## II. របៀបបង្ហាញសេចក្តីស្រឡាញ់របស់ព្រះជាម្ចាស់ក្នុងវិធីជាក់ស្តែង

នៅក្នុងគម្ពីរយ៉ូហាន១៣:៣៤-៣៥ ព្រះយេស៊ូបានប្រទានបញ្ញត្តិថ្មីមួយដល់យើងរាល់គ្នាគឺថា *«ចូរឱ្យស្រឡាញ់គ្នាទៅវិញទៅមក»* ។ ហើយព្រះអង្គបានបង្រៀនយើងអំពីរបៀបស្រឡាញ់នោះទៀត គឺថា «<u>**ត្រូវឱ្យស្រឡាញ់គ្នាដូចជាខ្ញុំបានស្រឡាញ់អ្នករាល់គ្នាដែរ**</u>» យើងត្រូវស្រឡាញ់គ្នាទៅវិញទៅមកដូចជាព្រះយេស៊ូស្រឡាញ់ យើងដែរ។ បន្ទាប់មកទៀតត្រូវសួរថា «**តើព្រះយេស៊ូស្រឡាញ់អ្នកយ៉ាងដូចម្តេច?**

តាមការពិតមានច្រើនយ៉ាង ប៉ុន្តែឥឡូវនេះយើងលើកយកមកធ្វើពិភាក្សាតែពីរចំណុចប៉ុណ្ណោះគឺ៖

១. <u>ដោយឥតលក្ខខណ្ឌ</u>: ម៉ាថាយ ៩:៩-១៣ ព្រះយេស៊ូបានមានបន្ទូលឱ្យលោកម៉ាថាយមកតាមទ្រង់។ លោកម៉ាថាយជា «មនុស្សមានបាប» ប៉ុន្តែ ព្រះយេស៊ូបានស្រឡាញ់គាត់។ ព្រះយេស៊ូបានឃើញ មនុស្សម្នាក់ដែលកំពុងតែឈឺចាប់ គេបដិសេធ និងកំពុងតែត្រូវបាត់បង់។ ដូច្នេះ ព្រះអង្គបានមានបន្ទូលឱ្យម៉ាថាយដើរតាមព្រះអង្គ។ ព្រះអង្គក៏បានបង្កើតនូវភាពជិតស្និទ្ធជាមួយនឹងលោកម៉ាថាយ។ ព្រះយេស៊ូបានទតឃើញមនុស្សម្នាក់ដែលព្រះអង្គសព្វព្រះហឫទ័យយ៉ាងខ្លាំង ហើយរហូតដល់ហ៊ានស្លាប់ជំនួសផង។ សេចក្តីស្រឡាញ់របស់ព្រះយេស៊ូមិនមែនសម្រេចនៅលើយើង ឬអ្វីដែលយើងធ្វើ ឬក៏យើងជាអ្នកណានោះទេ។ ព្រះអង្គស្រឡាញ់មនុស្សទាំងអស់ ទោះបីជាយើងដើរតាមទ្រង់ ឬបដិសេធព្រះអង្គយ៉ាងណាក៏ដោយ ក៏ព្រះអង្គនៅតែស្រឡាញ់យើងរាល់គ្នាដែរ។

២. <u>ដោយលះបង់</u>: ម៉ាថាយ ១៤:១៣-១៤ ទោះបីជាពេលខ្លះព្រះយេស៊ូសព្វព្រះហឫទ័យនៅម្នាក់ក៏ដោយ ក៏ព្រះអង្គនៅតែស្ម័គ្រព្រះទ័យជួយដល់អស់អ្នកមករកព្រះអង្គដែរ។ នៅពេលដែលអ្នកត្រូវការទ្រង់មកនោះព្រះអង្គមិនដែលយកព្រះទ័យទុកដាក់ចំពោះព្រះអង្គទ្រង់ឡើយ។ ព្រះអង្គបានលះបង់ពេលវេលា និងកម្លាំងរបស់ព្រះអង្គ។ ព្រះអង្គមានព្រះទ័យក្តួលអាណិត ហើយព្រះអង្គបានជួយដល់អស់អ្នកដែលមានការឈឺចាប់មនុស្សពិការ និងមនុស្សដែលបាត់បង់។ ព្រះអង្គមិនខាននឹងជួយដល់អ្នកណាឡើយ។

*យើងទាំងអស់គ្នាត្រូវស្រឡាញ់គ្នាទៅវិញទៅមកបែបយ៉ាងនោះដែរ:*

១.<u>ដោយឥតលក្ខខណ្ឌ</u> នៅក្នុងគម្ពីរ លេវីវិន័យ១៩:១៨ ព្រះបានប្រទានបញ្ញត្តិមួយឱ្យគឺ «ស្រឡាញ់អ្នកជិតខាងដូចខ្លួនឯង»។ នៅក្នុងគម្ពីរលូកា ១០:២៩ ពួកសិស្សនាំគ្នាទូលសួរព្រះអង្គថា «តើអ្នកណាជាអ្នកជិតខាងរបស់ខ្ញុំ?»។ ព្រះយេស៊ូបានមានបន្ទូលជាពាក្យប្រៀបប្រដូចដល់ពួកគេ គឺថាពួកដែលអ្នករាល់គិតថា ជាខ្មាំងសត្រូវ ហើយស្អប់យ៉ាងខ្លាំងដូចជាសាសន៍សាម៉ារីជាដើម។

ក្នុងនាមយើងជាអ្នកដើរតាមព្រះយេស៊ូ នោះយើងគ្មានផ្លូវជ្រើសរើសថា ត្រូវស្រឡាញ់អ្នកណា ឬមិនស្រឡាញ់អ្នកណាឡើយ។ ព្រះយេស៊ូបានមានបន្ទូលច្បាស់លាស់អំពីការនេះ គឺថាយើងស្រឡាញ់មនុស្សគ្រប់ជាន់ថ្នាក់ ទាំងមិត្តភក្តិទាំងសត្រូវ ទាំងអ្នកមាន ទាំងអ្នកក្រ ទាំងល្អ និងអាក្រក់។

ដ្បិតព្រះជាម្ចាស់ជាសេចក្ដីស្រឡាញ់ ការសម្ដែងឱ្យយើងឃើញពីសេចក្ដីស្រឡាញ់ដ៏ធំបំផុតនោះគឺឈើឆ្កាង ។ ព្រះជាម្ចាស់នៅតែសព្វព្រះហឫទ័យឱ្យលោកិយទាំងមូលបានស្គាល់ពីសេចក្ដីស្រឡាញ់របស់ព្រះអង្គ។ តើព្រះអង្គអាចបង្ហាញសេចក្ដីស្រឡាញ់របស់ព្រះអង្គបានយ៉ាងដូចម្ដេចនៅថ្ងៃនេះ? ព្រះអង្គសព្វព្រះហឫទ័យបង្ហាញតាមរយៈពួកសិស្សរបស់ព្រះអង្គ និងតាមរយៈអ្នកទាំងអស់គ្នា។ បើដូច្នេះ តើអ្នកព្រមឬទេ? ហើយតើអ្នកនឹងចេញទៅចំពោះអស់អ្នកដែលបាត់បង់ និងអ្នកដែលកំពុងឈឺចាប់ ហើយបង្ហាញសេចក្ដីស្រឡាញ់របស់ព្រះចំពោះពួកគេតាមរបៀបធម្មតាបានដែរឬទេ?

**២. ដោយហ៊ានលះបង់:** សេចក្ដីស្រឡាញ់ គឺមិនចាំបាច់មានលុយកាក់ទេ ប៉ុន្តែវាចាំបាច់ត្រូវការតែមានពេលវេលា និងកម្លាំងថាមពល។ ព្រះគម្ពីរបង្រៀនឱ្យចេះជួយសម្រាលបន្ទុកគ្នាទៅវិញទៅមក។ នៅពេលដែលអ្នកណាម្នាក់កំពុងតែមានការឈឺចាប់ ឬត្រូវការអ្វីមួយនោះ គឺយើងត្រូវការប្រើនូវកម្លាំងថាមពលផ្នែកអារម្មណ៍ច្រើន ដើម្បីដើរជាមួយអ្នកនោះ នៅកណ្ដាលនៃការឈឺចាប់ ឬវិបត្តិរបស់គាត់។ នៅពេលខ្លះត្រូវការប្រើពេលយូរ ដើម្បីជួយឱ្យមនុស្សម្នាក់បានប្រសើរឡើងវិញ ហើយយើងត្រូវដើរជាមួយអ្នកនោះរាប់ខែ ឬអាចដល់រាប់ឆ្នាំផង។ តើយើងស្ម័គ្រចិត្តចំណាយពេលរបស់យើង ដើម្បីជីវិតអស់កល្បអ្នកដទៃឬទេ ? តើយើងស្ម័គ្រចិត្តថ្វាយជីវិតរបស់យើង ដើម្បីបង្ហាញសេចក្ដីស្រឡាញ់របស់ព្រះដែរឬទេ?

*យ៉ូហាន ១៣:៣៥ «បើអ្នករាល់គ្នាស្រឡាញ់គ្នាទៅវិញទៅមក មនុស្សទាំងអស់មុខជាដឹងថា អ្នករាល់គ្នាពិតជាសាវ័ករបស់ខ្ញុំមែន»។*

ប្រសិនបើយើងបង្ហាញពីសេចក្ដីស្រឡាញ់របស់ព្រះជាម្ចាស់ដោយឥតលក្ខខណ្ឌ ហើយដោយលះបង់ នោះមនុស្សទាំងអស់គេនឹងឃើញថា សេចក្ដីស្រឡាញ់របស់ព្រះជាម្ចាស់នៅក្នុងយើង ហើយគេនឹងដឹងថាយើងមានលក្ខណៈខុសពីគេ ដោយសារតែយើងមានសេចក្ដីស្រឡាញ់របស់ព្រះជាម្ចាស់ ។ សេចក្ដីស្រឡាញ់របស់ព្រះអង្គនឹងបើកចិត្តអ្នកដែលបាត់បង់ទាំងនោះ ហើយគេនឹងចំហចិត្តស្ដាប់ ព្រមទាំងទទួលយកសេចក្ដីពិតរបស់ព្រះអង្គផង។ សេចក្ដីស្រឡាញ់របស់ទ្រង់នឹងបើកទ្វារចិត្តមនុស្សទាំងនោះដើម្បីឱ្យយើងអាចចែកចាយអំពីដំណឹងល្អនៃព្រះបាន។

## III. របៀបធ្វើតាមគោលការណ៍ អយ_ខស (OIKOS)

មាន គោល ការណ៍ មួយ ទៀត នៅ ក្នុង ចំណុច នេះ គោល ការណ៍ នោះ ហៅ ថា **Oikos**។ នៅក្នុងគម្ពីរកិច្ចការ ១៦:៣១ ចែងថា *«សូមជឿលើព្រះអម្ចាស់យេស៊ូទៅ នោះព្រះជាម្ចាស់នឹងសង្គ្រោះលោកព្រមទាំងសង្គ្រោះក្រុមគ្រួសាររបស់លោកដែរ»*។ ពាក្យថា**Oikos**មានន័យថា«គ្រួសារទាំងមូល» ឬ «នៅក្រោមឥទ្ធិពល» របស់អ្នក។ មនុស្សគ្រប់គ្នានៅលើផែនដីគឺ សុទ្ធតែស្ថិតនៅក្រោមចង្កោមគ្រួសារទាំងអស់។

នៅពេលដែលអ្នកបានជួបនឹងមនុស្ស ដែលប្រកបដោយសេចក្តីមេត្រីអ្នកប្រាកដ ជាចង់ឱ្យគេណែនាំទៅមនុស្សគ្រប់គ្នានៅក្នុងគ្រួសាររបស់គេ។ នៅពេលនោះអ្នកនឹង ស្គាល់សមាជិកគ្រួសាររបស់គេទាំងអស់គ្នា។ មិនតែប៉ុណ្ណោះសមាជិកនៅក្នុងគ្រួសារ នោះ ក៏មានគ្រួសាររបស់គេរៀងៗខ្លួនទៀតដែរ។ ឧទាហរណ៍ បើមនុស្សដែលប្រកប ដោយសេចក្តីមេត្រីមានសមាជិកគ្រួសារ ១០ នាក់ នោះប្រហែលជាអ្នកទាំង១០នោះ មានគ្រួសារ១០នាក់ផ្សេងទៀតដែរ។ ដូច្នេះ អ្នកក៏អាចស្គាល់ពួកគេទាំង នោះបានដែរ ។ គន្លឹះសំខាន់បំផុត នោះគឺ ត្រូវរកមនុស្ស ដែលប្រកបដោយ សេចក្តីមេត្រីជាមុន សិន រួចដើរតាម Oikoses គោលការណ៍គ្រួសារទាំងមូល។

## IV. របៀបដឹកនាំការសិក្សាព្រះគម្ពីរ

### ក. របៀបដឹកនាំការសិក្សាព្រះគម្ពីរបែបផ្សាយដំណឹងល្អ

#### ១. ការនិទានរឿង

ប្រើរឿងណាដែលល្អៗ រឿងជាវគ្គៗរបស់គ្រីស្ទី ប្រនើរ ដែលបានដាក់បញ្ចូល ក្នុងមេរៀននេះរួចមកហើយ។ រឿងប្រភេទនេះជារឿងសាមញ្ញ មានភាពងាយស្រួល ក្នុង ការ តាម ដាន សិក្សា ព្រម ទាំង ការ អនុវត្តន៍ ។ *ដំណឹងល្អរបស់ព្រះយេស៊ូ* មាន មេរៀនផ្សាយដំណឹងល្អប្រាំពីរ ដែលនិយាយពីជីវិតរបស់ព្រះយេស៊ូដកស្រង់ចេញពី ម៉ាថាយសម្រាប់ប្រើជាមួយអ្នកមិនជឿ។ *ការចាប់ផ្តើមជីវិតថ្មីក្នុងព្រះគ្រិស្ត* មានមេ រៀនទៅដល់ប្រាំបី សម្រាប់ថែបំប៉នដល់ពួកអ្នកដែលជឿថ្មី។

១. ចាប់ផ្តើមមេរៀនដោយការអធិស្ឋានសូមព្រះជាម្ចាស់ឱ្យប្រាប់គ្រប់គ្នាយល់ពីអត្ថ ន័យនៃសាច់រឿង។

២. អានរឿងឱ្យអ្នកចូលរួមទាំងអស់ស្តាប់ ឬបើពួកគេមានមេរៀន នោះយើងត្រូវអានរួមគ្នាដោយប្រើវិធីប្រយោល។

៣. អ្នកដឹកនាំគួរសួរសំនួរដោយផ្ទាល់មាត់នៅពេលបញ្ចប់មេរៀន។ គោលបំណងនៃការសួរសំនួរទាំងនេះ គឺដើម្បីរំលឹកមេរៀន និងការយល់ដឹងរបស់ពួកគេ។ មិនមែនសម្រាប់ការជជែកវែកញែក ឬឈ្លោះប្រកែកគ្នានោះទេ។

៤. អានសេចក្តីពិតខាងវិញ្ញាណ។ អនុញ្ញាតឱ្យសមាជិកក្រុមទាំងអស់គ្នាពិភាក្សានិងសួរសំនួរដោយសេរីទាក់ទងនឹងសេចក្តីពិតខាងវិញ្ញាណ។ ចូរប្រយ័ត្នកុំឱ្យមានការជជែកវែកញែកឥតប្រយោជន៍ ឬឈ្លោះប្រកែកគ្នាឱ្យសោះ។ ពេលនេះវាមិនមែនជាការសំខាន់សម្រាប់សមាជិកក្រុមយល់ព្រមទទួលយកនូវសេចក្តីពិតខាងវិញ្ញាណ នោះទេ។ ប៉ុន្តែ ឯការសំខាន់នោះគឺថា តើពួកគេយល់ពីការបើកសម្តែងនៃសេចក្តីពិតតាមរយៈព្រះបន្ទូលរបស់ព្រះជាម្ចាស់ដែរឬទេ។

៥. បន្ទាប់ពីការសិក្សាសេចក្តីពិតខាងវិញ្ញាណរួចហើយ យើងត្រូវទុកពេលឱ្យគ្រប់គ្នាអាចចែកចាយពីសេចក្តីត្រូវការ និងសំណូមអធិស្ឋានរបស់ខ្លួនដល់សមាជិកក្រុមទាំងមូល។

៦. អធិស្ឋានសម្រាប់សេចក្តីត្រូវការនីមួយៗ និងសម្រាប់មនុស្សម្នាក់ៗនៅក្នុងក្រុម។ នៅពេលដែលក្រុមនេះមានការរីកចម្រើន ហើយមានមនុស្សទទួលព្រះអម្ចាស់ច្រើន យើងគួរទុកឱកាសឱ្យសមាជិកក្រុមអធិស្ឋានឱ្យគ្នាទៅវិញទៅមក ក្នុងកម្មវិធីអធិស្ឋាននេះ។

## ២. វិធីដោយប្រយោល (ដោយ ឆាលស៍ ប្រូក)

### សេចក្តីផ្តើមៈ

មេរៀននេះត្រូវបានសរសេរឡើងដើម្បីជួយឱ្យគ្រប់គ្នារៀនពីរបៀបដឹកនាំការសិក្សាព្រះគម្ពីរ ដោយវិធីប្រយោល ។វិធីបង្រៀនចំពោះអ្នកដឹកនាំនេះគឺថា ការអប់រំ ឬវគ្គសិក្សាពិសេសផ្សេងៗ គឺមិនមែនជាការចាំបាច់ដើម្បីយកមកបង្រៀនឡើយ។

វិធីសម្រាប់បង្រៀនអ្នកដឹកនាំរបៀបនេះ អាចនឹងយកមកអនុវត្តចំពោះការសិក្សាពិសេសនេះ ជាពិសេសសម្រាប់ការសិក្សាជាវគ្គៗទាក់ទងទៅនឹងការផ្សាយដំណឹងល្អលើកដំបូងដែលអាចហៅថា «ដំណឹងល្អអំពីព្រះជាម្ចាស់» ដែលដកស្រង់ចេញពីការសិក្សាព្រះគម្ពីរយ៉ូហាន។

ចូរនឹកចាំពីអ្វីដែលសាវ័កប៉ូលបានធ្វើនៅក្នុងគម្ពីរ ២ ធីម៉ូថេ២:២ គឺគាត់បង្រៀនអ្នកផ្សេងឱ្យទៅបង្រៀនអ្នកផ្សេងទៀត ។ល ។ ប្រសិនបើយើងចង់ឱ្យអ្នកដែល យើងបង្រៀនចេញទៅបង្រៀនអ្នកផ្សេងទៀតនោះ គឺយើងនឹងត្រូវការប្រើប្រាស់ឧបករណ៍ និងវិធីផ្សេងៗដែលពួកគេអាចរកបាននៅពេលដែលចេញទៅបង្រៀនដល់អ្នកដទៃផ្សេងទៀតនោះ ។

**ក- វិធីបង្រៀនដោយប្រយោលទាក់ទងទៅនឹងកិច្ចការពីរយ៉ាង:**

គោលបំណងនៃចំណុចនេះ គឺដើម្បីបញ្ជាក់ឱ្យឃើញច្បាស់អំពីចំណុចដែល **ទាក់ទងទៅនឹងការដឹកនាំដោយប្រយោល ។**

ការដឹកនាំដោយប្រយោល មិនមែនដូចជាការដឹកនាំដោយផ្ទាល់នោះទេ ។ ការដឹកនាំដោយប្រយោលទាក់ទងនឹងពីរចំណុចគឺ៖

១. អ្នកដឹកនាំផ្តល់ការណែនាំដល់ក្រុម ។
២. មានការចូលរួមពីក្រុម ។

ការដឹកនាំដោយប្រយោលទាក់ទងទៅនឹង____________________ដោយសារអ្នកដឹកនាំ ហើយនិង________________________________________
ដោយក្រុមគ្រួសារ____________________________________________

**ការណែនាំ** **ការចូលរួម**

**ខ. មានច្បាប់ប្រាំចំណុចដែលយើងធ្វើតាម ប្រសិនបើយើងនឹងប្រើរបៀបដោយប្រយោលនេះ ។**

**១. អ្នកដឹកនាំគួរតែលើកទឹកចិត្តសមាជិកនៃក្រុមឱ្យចូលរួម៖**

ការដឹកនាំដោយប្រយោល មិនអាចប្រព្រឹត្តិទៅបានទេ នៅពេលដែលអ្នកដឹកនាំគ្រប់គ្រងដោយខ្លួនឯងនោះ ។ ការដឹកនាំដោយប្រយោល គឺសំខាន់ដែលមានសមាជិកទាំងអស់ទទួលនូវការលើកទឹកចិត្តដើម្បី________________________
________________________________________________________

ការចូលរួម

**២. ចែកសៀវភៅដែលមានចន្លោះសម្រាប់ឆ្លើយនឹងសំនួរ ឬអ្វីផ្សេងទៀតដែលអាចអានបានទៅដល់សមាជិក ។ ធ្វើដូច្នេះ នឹងបានជួយ ដល់គ្រូឱ្យរកឃើញ**

ទិសដៅសម្រាប់ក្រុម។

ឧបករណ៍ទាំងនេះនឹងជួយលើកទឹកចិត្តដល់សមាជិកឱ្យបានចូលរួមផងដែរ។ រីឯសៀវភៅលំហាត់ដែលជួយឱ្យដល់គ្រូរកឃើញ________________សម្រាប់ក្រុម។ ក្រៅពីនោះក៏ជួយលើកទឹកចិត្តដល់សមាជិកឱ្យ________________ ________________________________________________។

________________________________________________

ការណែនាំ ការចូលរួម

៣. អ្នកដឹកនាំត្រូវអត់ធ្មត់នៅពេលដែលដឹកនាំការរៀនព្រះគម្ពីរដល់អ្នកដែលមិនជឿ។ ការអត់ធ្មត់ជាការសំខាន់បំផុតនៅពេលដែលយើងប្រើវិធីប្រយោលនេះ។ សមាជិកក្រុមខ្លះនឹងមានចិត្តចង់ចូលរួមយ៉ាងខ្លាំង ហើយខ្លះទៀតមិនចង់ចូលរួមទេ។ ដូច្នេះបានជាមានច្បាប់មួយសម្រាប់អ្នកដឹកនាំតែងតែយកមកដាក់នៅក្នុងខ្លួននោះគឺ ត្រូវតែមានការ________________________________

អត់ធ្មត់

៤. នៅក្នុងការដឹកនាំក្រុមបង្រៀនព្រះគម្ពីរ អ្នកដឹកនាំគួរតែធ្វើឱ្យមាននូវការដឹកនាំដែលគេអាចយកតម្រាប់តាម។ ការដឹកនាំដែលគេអាចយកតម្រាប់តាម។ ការដឹកនាំដែលគេអាចយកតម្រាប់តាមមានន័យថា ជាប្រភេទនៃការដឹកនាំមួយដែលសមាជិកនៅក្នុងថ្នាក់រៀននឹងអាចធ្វើដូចគ្នាយ៉ាងឆាប់រហ័សនូវអ្វីដែលអ្នកកំពុងធ្វើ។ អ្នកដឹកនាំគួរកាន់យកអកប្បកិរិយាមួយដែលភាពជាអ្នកដឹកនាំរបស់គាត់អាច ________________________________ដោយសមាជិកនៃក្រុម។

យកតម្រាប់តាម

៥. យើងបានរៀនរួចមកហើយថា ការដឹកនាំដោយប្រយោលទាក់ទងនឹងការចូលរួមពីសមាជិកនៃក្រុម។ ក្រុមនោះត្រូវពឹងផ្អែកលើព្រះវិញ្ញាណបរិសុទ្ធ ដើម្បីទទួលជោគជ័យ ។ មានតែព្រះវិញ្ញាណបរិសុទ្ធប៉ុណ្ណោះដែលអាចកាត់ទោស និងបំផ្លាស់បំប្រែបាន។ កិច្ចការរបស់ព្រះវិញ្ញាណបរិសុទ្ធគឺ________________ និង________________________________________________។

ការកាត់ទោស ការបំផ្លាស់បំប្រែចិត្ត

**គ. បីចំណុចដែលអ្នកដឹកនាំមិនគួរធ្វើ នៅពេលដែលដឹកនាំបង្រៀនព្រះគម្ពីរដោយប្រើវិធីប្រយោល៖**

១. ជារឿយៗអ្នកដឹកនាំការសិក្សាព្រះគម្ពីរច្រើនជាសមាជិកក្រុមរបស់គាត់។ ពេលខ្លះគាត់មានភាពអំណួត។ ដូច្នេះគាត់និយាយចេញនូវអ្វីៗដែលគាត់ចេះទាំងអស់។ អាកប្បកិរិយាបែបនេះគឺ____________________ ____________________។

ក. ដែលមានការចេតនា

ខ. ដែលគ្មានចេតនាក្នុងការដឹកនាំដោយប្រយោល

ជាការសំខាន់ណាស់ដែលអ្នកដឹកនាំ**មិននិយាយអ្វីៗដែលគាត់ដឹង**។ ផ្ទុយទៅវិញ គាត់និយាយតែអ្វីដែលជាការណែនាំផ្លូវដល់សមាជិកក្រុមតែប៉ុណ្ណោះ។

**ដែលគ្មានចេតនា**

២. នៅក្នុងថ្នាក់សិក្សាព្រះគម្ពីរប្រាកដជាមានម្នាក់លេចចេញមកដើម្បីបង្ហាញអំពីប្រាជ្ញារបស់ខ្លួន។ យើងហៅមនុស្សប្រភេទនោះថា «ទស្សនវិទូ»។ វាជាការចំណាយពេលឥតប្រយោជន៍ក្នុងការជជែកវែកញែកជាមួយមនុស្សបែបនេះ។ «អ្នកទស្សនវិទូ» បែបនេះជាទូទៅគេហៅថា ____________________សូមជ្រើសរើសច្រើនជាមួយ

ក. អ្នកដែលស្វែងរកសេចក្តីពិតមែនទែន
ខ. ព្យាយាមឱ្យគេយកចិត្តទុកដាក់ចំពោះខ្លួន
គ. ចូលចិត្តនិយាយ

---

**ព្យាយាមឱ្យគេយកចិត្តទុកដាក់ចំពោះខ្លួន** **ចូលចិត្តនិយាយ**

៣. ដោយពាក្យថា ការដឹកនាំដោយប្រយោល មានន័យថា សមាជិកជាច្រើននឹងចូលរួមក្នុងថ្នាក់រៀននោះ *អ្នកដឹកនាំត្រូវតែប្រាកដថា មនុស្សតែម្នាក់មិនអាចសម្រេចលើទៅលើការពិភាក្សាគ្នាទេ*។ នៅពេលដែលមាននរណាម្នាក់និយាយច្រើនជាងគេនៅក្នុងថ្នាក់រៀនដូច្នេះ នោះមានន័យថា អ្នកដឹកនាំមិនបានធ្វើការដឹកនាំដោយ____________________

____________________________________________________បានល្អទេ។

__________________________________________________________។

ដោយប្រយោល

ឃ.មូលហេតុពីរដែលថា ហេតុអ្វីបានជាការប្រើវិធីដឹកនាំដោយប្រយោលល្អនៅពេលដែលបង្កើតក្រុមជំនុំថ្មី៖

១. នៅពេលដែលយើងប្រើវិធីប្រយោលគឺ មានភាពងាយស្រួលក្នុងការផ្ទេរកិច្ចទទួលខុសត្រូវជាអ្នកដឹកនាំដល់សមាជិកក្រុមផ្សេងទៀត។ ជាចម្លើយដ៏សាមញ្ញក្នុងការផ្តល់នូវការដឹកនាំដល់ក្រុមមួយតាមរយៈការសិក្សាព្រះគម្ពីរដែលនឹងកើតជាក្រុមជំនុំនៅថ្ងៃណាមួយ។ បុគ្គលិកលក្ខណៈមួយរបស់អ្នកដឹកនាំដែលឈ្លាសវៃនោះ គឺមានលទ្ធភាពក្នុងការ________________ភាពជាអ្នកដឹកនាំ។

__________________________________________________________

ផ្ទេរ

២. នៅពេលដែលអ្នកប្រើវិធីដឹកនាំដោយប្រយោល ដែលយើងបានរៀននៅក្នុងមេរៀននេះ *អ្នកនឹងចាប់ផ្តើម ហើយដឹកនាំក្រុមថ្មីៗដែលមិនចាំបាច់កំណត់ថា អ្នកដឹកនាំនោះត្រូវតែមានបទពិសោធ មានលុយ ឬបានទទួលការហ្វឹកហាត់នោះទេ។ គឺថាគ្រប់គ្នាអាចធ្វើបាន!*

ដូច្នេះមានន័យថា មនុស្សជាច្រើនក៏អាច__________________ក្រុមថ្មីបានដែរ។

ដឹកនាំ

## ខ. របៀបដឹកនាំការសិក្សាព្រះគម្ពីរបែបថៃបំប៉ន

**ម៉ាថាយ ២៨:១៩ និង ២ ធីម៉ូថេ ២:២**

ព្រះយេស៊ូបានបង្គាប់ដល់យើងរាល់គ្នាថា «ចូរចេញទៅហើយ *បង្កើតសិស្ស*» មិនមែនមានន័យថាគ្រាន់តែជាអ្នកជឿថ្មីធម្មតានោះទេ។ នៅពេលណាដែលសិស្សនៅក្នុងថ្នាក់រៀនរបស់អ្នកបានថ្វាយខ្លួនភ្លាមជាការសំខាន់ នោះគឺអ្នកត្រូវថែបំប៉នគេ

ឱ្យក្លាយជាសិស្សដែលចេះបង្កើតសិស្សបន្តទៀត។ ការបង្កើតសិស្សគួរតែចាប់ផ្ដើមភ្លាមៗ ដើម្បីឱ្យគេរីកចម្រើនខាងការប្រកបទាក់ទងជាមួយនឹងព្រះ ហើយមានជីវិតពេញបរិបូរ ប្រកបដោយគោលបំណង និងអត្ថន័យក្នុងព្រះអម្ចាស់។

ដំបូងឡើយត្រូវដឹកនាំគេឱ្យស្គាល់ព្រះ បង្រៀនគេឱ្យចេះចំណាយពេលជាមួយនឹងព្រះក្នុងការសញ្ជឹងគិតពីព្រះបន្ទូលព្រះអង្គ និងតាមរយៈការអធិស្ឋាន។ បន្ទាប់មកគឺហ្វឹកហាត់ពួកគេពីកិច្ចការងាររបស់ព្រះ។

## ១. ចំណុចដែលត្រូវសម្រេចចិត្ត

អ្នកផ្សាយដំណឹងល្អបានមកដល់ចំណុចដែលត្រូវសម្រេចចិត្ត។ ឥឡូវនេះមកដល់ពេលដែលគាត់ជួបជាមួយនឹងអស់អ្នកដែលបានទើបតែរៀនចប់ជាមួយគាត់។ អ្នកផ្សាយដំណឹងល្អគួរតែអញ្ជើញទាំងអ្នកដែលបានសម្រេចចិត្ត និងអ្នកដែលមិនទាន់បានសម្រេចចិត្តឱ្យចូលរៀនថ្នាក់ថែបំប៉នបន្តទៀត។ ករណីនេះអ្នកផ្សាយដំណឹងល្អគួរធ្វើកិច្ចការពីរយ៉ាង៖

ក. ចាប់ផ្ដើមរៀនថ្នាក់ថែបំប៉នដោយមានសំភារៈភ្លាមៗ។ អ្នកជឿថ្មីគួរតែមានការថែបំប៉ន។ ការបង្កើតសិស្សជាការសំខាន់សម្រាប់អ្នកជឿគ្រប់ៗរូប ណិងសម្រាប់ក្រុមជំនុំទាំងអស់ដែរ។ ការបង្កើតសិស្សជួយដល់អ្នកជឿឱ្យមានការរីកចម្រើនខាងព្រលឹងវិញ្ញាណ ដែលជាគ្រឹះសម្រាប់ក្រុមជំនុំរឹងមាំមួយ ហើយអាចចាប់ផ្ដើមបង្កើតជាក្រុមជំនុំជាច្រើនទៀត។ អ្នកផ្សាយដំណឹងល្អគួរដឹកនាំការប្រើសំភារៈថែបំប៉នដោយប្រើវិធីប្រយោល។ អ្នកផ្សាយដំណឹងល្អអាចប្រើសំភារៈ ឬឧបករណ៍អ្វីក៏បាន។ ប៉ុន្តែយើងចង់ឱ្យយោបល់ថា វាគួរជាឧបករណ៍ដែលមានការនិទានរឿង«ការចាប់ផ្ដើមជីវិតថ្មី»។

ខ. ជាការសំខាន់ណាស់ បើអ្នកផ្សាយដំណឹងល្អតែងតែបន្តស្វែងរកមនុស្សផ្សេងទៀតដើម្បីចាប់ផ្ដើមក្រុមថ្មីរៀនដោយប្រើការសិក្សាអំពីដំណឹងល្អ ឬក៏រឿងនិទានជាវគ្គៗ ដោយមានសេចក្ដីសង្ឃឹមថ្មីៗទៀត។

## ២. សប្ដាហ៍ទីបី

នេះជាសប្ដាហ៍មួយទៀតហើយដែលត្រូវធ្វើការសម្រេចចិត្ត។ អ្នកផ្សាយដំណឹងល្អគួរទុកឱ្យសមាជិកក្រុមទាំងមូលជាអ្នកជ្រើសរើសអ្នកដឹកនាំម្នាក់ដែលចេញពីពួកគេ សម្រាប់ការជួបជុំពិភាក្សាគ្នានៅសប្ដាហ៍ក្រោយៗទៀត។ អ្នកផ្សាយដំណឹងល្អមិនចាំបាច់ខំប្រឹងរើសអ្នកដឹកនាំឱ្យពួកគេទេ ប៉ុន្តែគាត់អាចជួយណែនាំនិង

ឱ្យយោបល់ដើម្បីកុំឱ្យខុសពីគោលលទ្ធិនៃអ្នកជឿ។ អ្នកផ្សាយដំណឹងល្អគួរជួបជាមួយនិងអ្នកដឹកនាំក្រុមថ្មីនោះដោយឡែកដើម្បីហ្វឹកហាត់ដល់ពួកគេ។ ក្រោមការដឹកនាំរបស់ព្រះវិញ្ញាណបរិសុទ្ធ នោះអ្នកផ្សាយដំណឹងល្អឥឡូវនេះអាចរៀបចំឱ្យមានជាទ្រង់ទ្រាយក្រុម ដែលកើតមកពីពួកអ្នកដែលព្រះបានរើសឡើងចេញពីពួកអ្នកជឿថ្មីនេះ។ អ្នកផ្សាយដំណឹងល្អនឹងហ្វឹកហាត់ ហើយចាត់ឱ្យពួកគេចេញទៅធ្វើការបន្តទៀត ដើម្បីបង្កើតក្រុមថ្មី។ ចូរចាំថា អ្នកផ្សាយដំណឹងល្អនឹងត្រូវជួបក្រុមរបស់ខ្លួនរាល់សប្តាហ៍។

៣. សប្តាហ៍ទីបួន និងទីប្រាំ

អ្នកដឹកនាំថ្មីនឹងដឹកនាំបង្រៀន ចំណែកឯអ្នកផ្សាយដំណឹងល្អពេលនេះ គឺគ្រាន់តែជាអ្នកស្តាប់ប៉ុណ្ណោះ ហើយមិនត្រូវរំខានដល់ការបង្រៀនរបស់អ្នកដឹកនាំថ្មីឡើយ

៤. សប្តាហ៍ទីប្រាំមួយ

ចំពោះសប្តាហ៍នេះ អ្នកផ្សាយដំណឹងល្អត្រូវរកហេតុផលថាហេតុអ្វីបានជាគាត់មិនអាចចូលរួមការរៀននេះបាន។ ប៉ុន្តែគាត់ត្រូវពន្យល់គេឱ្យច្បាស់ថា ពួកគេត្រូវតែជួបជុំគ្នារៀងរាល់សប្តាហ៍។

## គ. របៀបដឹកនាំការសិក្សាព្រះគម្ពីរនៅតាមផ្ទះដោយគ្មានសម្ភារៈអ្វីក្រៅពីព្រះគម្ពីរ

**ជំហ៊ានទី១:** អ្នកដឹកនាំក្រុមត្រូវជ្រើសរើសបទគម្ពីរដើម្បីបង្រៀន។

**ជំហ៊ានទី២:** អ្នកដឹកនាំត្រូវស្នើឱ្យអ្នកណាម្នាក់អានបទគម្ពីរនោះ។

**ជំហ៊ានទី៣:** អ្នកដឹកនាំអានបទគម្ពីរឡើងវិញ ហើយបកស្រាយខគម្ពីរនីមួយៗយ៉ាងសាមញ្ញ។

**ជំហ៊ានទី៤:** ក្រោយពេលអានខគម្ពីរហើយ អ្នកដឹកនាំចាប់ផ្តើមសួរសំនួរស្រួលៗទាក់ទងនឹងសេចក្តីពិត៖

ក. តើខគម្ពីរនេះនិយាយអ្វីអំពីព្រះ?

ខ. តើខគម្ពីរនេះនិយាយអ្វីអំពីព្រះយេស៊ូ?

គ. តើខគម្ពីរនេះនិយាយអ្វីអំពីព្រះវិញ្ញាណបរិសុទ្ធ?

ឃ. តើខគម្ពីរនេះនិយាយអ្វីអំពីអំពើបាប?

ង. តើខគម្ពីរនេះបង្រៀនអ្វីដល់ខ្ញុំ?

ច. តើធ្វើដូចម្ដេចដើម្បីឱ្យខ្ញុំអាចយកខគម្ពីរនោះមកអនុវត្តក្នុងជីវិត?

**ជំហ៊ានទី៥:** អ្នកដឹកនាំគួរបង្ហាញខគម្ពីរដែលទាក់ទងផ្សេងទៀតដល់ក្រុមរបស់គាត់ប្រសិនបើដឹង។

**ជំហ៊ានទី៦:** អ្នកដឹកនាំគួរដឹកនាំសមាជិកក្រុមឱ្យចេះទទួលយកខគម្ពីរដាក់នៅក្នុងជីវិតរបស់គេ។

**ជំហ៊ានទី៧:** បន្តទៅខគម្ពីរបន្ទាប់ទៀត។

**ជំហ៊ានទី៨:** ចុងបញ្ចប់នៃសេចក្ដីបង្រៀន អ្នកដឹកនាំគួរអធិស្ឋានសម្រាប់សេចក្ដីត្រូវការរបស់គេគ្រប់គ្នា។

## ឃ. របៀបដឹកនាំការសិក្សាព្រះគម្ពីរជាមួយអ្នកមិនជឿ

១. ការជួបជុំដំបូង

ក. អ្នកផ្សាយដំណឹងល្អមុនដំបូងនេះ គួរយកនូវសំភារៈដូចខាងក្រោម៖

- ព្រះគម្ពីរសញ្ញាថ្មី
- ប៊ិច ឬ ខ្មៅដៃ
- ក្រដាសសម្រាប់សរសេរ
- ក្រដាសបទចំរៀងផ្សេងៗដែលទាក់ទងនឹងសេចក្ដីបង្រៀន
- ខិត្តប័ណ្ណ «តើធ្វើដូចម្ដេចដើម្បីឱ្យបានជីវិតអស់កល្ប»

សិក្សាអំពី «ដំណឹងល្អ» រឿងរ៉ាវផ្សេងៗនៃដំណឹងល្អ ឬ អ្វីដែលគាត់បានរៀបចំសម្រាប់បង្រៀន។

ខ. អ្នកផ្សាយដំណឹងល្អមុនដំបូង គួរណែនាំខ្លួនគាត់ឱ្យគេដឹងថា ជាអ្នកដឹកនាំការបង្រៀនព្រះគម្ពីរ។

គ. អ្នកផ្សាយដំណឹងល្អមុនដំបូង គួរសុំឱ្យសមាជិកគ្រប់គ្នាសរសេរឈ្មោះអាយុ

និងថ្ងៃខែកំណើតនៅលើក្រដាស់មួយ។ ពន្យល់ប្រាប់គេថា ក្រដាសសរសេរឈ្មោះនេះគឺសម្រាប់អ្នកដើម្បីយកទៅអធិស្ឋានឱ្យសមាជិកៗគ្រប់គ្នា ហើយប្រាប់គេថា អ្នកនឹងនាំមកនូវមេរៀនក្នុងគម្ពីរដំណឹងល្អយ៉ូហាន សម្រាប់មេរៀនលើកក្រោយ។ ក្រដាសសរសេរឈ្មោះនេះ គួររក្សាទុកក្នុងសៀវភៅកំណត់ហេតុសម្រាប់អធិស្ឋានជាប្រចាំថ្ងៃ។

ឃ. អ្នកផ្សាយដំណឹងល្អមុនដំបូង គួរតែច្រៀងចម្រៀងពីរបីបទ បន្ទាប់មកសួរពួកគេថា តើចង់ចេះច្រៀងដែរឬទេ។ ហើយទុកឱ្យក្រុមទាំងមូលជាអ្នកសម្រេច។ បើគេចង់ចេះនោះយើងបង្រៀនគេមួយ ឬពីរបទដែលមានអត្ថន័យល្អ។

ង. អ្នកផ្សាយដំណឹងល្អមុនដំបូងគួររើសយកបទចំរៀងមួយធ្វើជាប្រធានបទ។

ច. អ្នកផ្សាយដំណឹងល្អ មុនដំបូងគួរសួរដល់សមាជិកក្រុមអំពីសេចក្តីត្រូវការឬសំណូមពរអធិស្ឋានអ្វីនៅក្នុងជីវិតរបស់ពួកគេ។ បន្ទាប់មកអធិស្ឋានជាមួយគ្នាលើសំណុមអធិស្ឋានទាំងនោះ ហើយរក្សាការអធិស្ឋាននេះរហូតពេញមួយសប្តាហ៍។

## ២. ណែនាំឱ្យស្គាល់ព្រះគម្ពីរ ហើយដឹកនាំការបង្រៀន

<u>ចូរចាំថា</u>: អ្នកទាំងនេះមិនមែនជាពួកអ្នកជឿទេ។ គេមិនទាន់ស្គាល់ព្រះគម្ពីរហើយក៏មិនទាន់ដឹងពីរបៀបប្រើដែរ។ ដូច្នេះ អ្នកបង្រៀនត្រូវការអត់ធ្មត់ច្រើន។ យើងគួរតែចែកចេញជាគូរៗ ធ្វើការក្នុងភាពជាដៃដូរដើម្បីជួយគ្នាទៅវិញទៅមកឱ្យរៀនប្រើព្រះគម្ពីរ។

ក. បង្ហាញព្រះគម្ពីរឱ្យគេស្គាល់សិន រួចចាប់ផ្តើមពន្យល់ថា ព្រះគម្ពីរចែកចេញជាពីរផ្នែកគឺ ព្រះគម្ពីរសញ្ញាចាស់ និងសញ្ញាថ្មី ហើយនៅក្នុងនោះចែកចេញជាសៀវភៅតូចៗជាច្រើនទៀត។ បន្ទាប់មកពន្យល់ដោយសង្ខេបពីសារបាននៃគម្ពីរទាំងសញ្ញាចាស់ និងសញ្ញាថ្មី។

ខ. ប្រាប់ពីរបៀបរកព្រះគម្ពីរដោយមើលលេខទំព័រ។ ជួយរកលេខទំព័រសម្រាប់គម្ពីរយ៉ូហាន រួចអ្នកជួយបើកទៅព្រះគម្ពីរយ៉ូហាននោះជាមួយគេ។ នៅពេលដែលគេរកឃើញគម្ពីរយ៉ូហានហើយ នោះអ្នកអាចប្រាប់គេឱ្យស្គាល់ជំពូកខ នៅក្នុងគម្ពីរនោះបាន។

គ. នៅពេលដែលអ្នកបានរកឃើញគម្ពីររួចរាល់ហើយ នោះអ្នកអាចចាប់ផ្តើមរៀនដោយអនុញ្ញាតឱ្យពួកគេអានសំនួរ ខគម្ពីរ ហើយឆ្លើយនឹងសំនួរផ្សេងៗ

ផងដែរ។ សូមប្រើវិធីប្រយោល ដែលអ្នកដឹកនាំនឹងមិនអានខគម្ពីរ សំនួរផ្សេងៗ ឬក៏ឆ្លើយនឹងសំនួរអ្វីឡើយ។ អ្នកដឹកនាំនឹងជួយឱ្យពួកគេរកចម្លើយដែលត្រឹមត្រូវ។ ប្រសិនបើពួកគេឆ្លើយមិនត្រូវ នោះសូមឱ្យពួកគេអានខគម្ពីរ និងឃ្លានៃសំណួរឡើងវិញដើម្បីរកចម្លើយ។ ការប្រើវិធីរបៀបនេះនឹងជួយដល់អ្នកជឿថ្មីអាចមានលទ្ធភាពដឹកនាំការរៀនព្រះគម្ពីរនៅតាមផ្ទះនៅតាមអ្នកមិនជឿផ្សេងទៀតបាន។

### ៣. សេចក្តីអញ្ជើញ

មេរៀន «ដំណឹងល្អ» ទាំងប្រាំមួយនោះមានសេចក្តីអញ្ជើញមួយ នៅក្នុងនោះ (ប្រសិនបើអ្នកប្រើមេរៀនជាការនិទានរឿងនោះ សេចក្តីអញ្ជើញគឺមាននៅក្នុងមេរៀនទាំង៧)។ អ្នកដឹកនាំអាចប្រើខិតប័ណ្ណដែលមានឈ្មោះថា «តើធ្វើដូចម្តេចដើម្បីឱ្យបានជីវិតអស់កល្ប» ឬឧបករណ៍អ្វីផ្សេងទៀត ដើម្បីយកមកពន្យល់អំពីដំណឹងល្អនៃព្រះ ហើយអញ្ជើញពួកគេឱ្យទទួលយកព្រះយេស៊ូ ធ្វើជាព្រះអម្ចាស់របស់ពួកគេ។

### ៤. មេរៀនចុងក្រោយ

បន្ទាប់ពីរៀនចប់ហើយ គឺជាពេលវេលាសម្រាប់ឱ្យពួកគេធ្វើការសម្រេចចិត្ត។ អ្នកផ្សាយដំណឹងល្អគួរសួរពួកគេថា តើចង់បន្តរៀនជាមួយគ្នាទៀតដែរឬទេ។ ប្រសិនបើគេថា «ចង់» នោះគាត់គួរគិតគូរអំពីមេរៀនសម្រាប់ការថែបំប៉នពួកគេបន្តទៀត។ ការចាប់ផ្តើមជីវិតថ្មីជាមួយព្រះយេស៊ូ នោះប្រាកដជាមានការអស្ចារ្យមួយកើតឡើង។ អ្នកផ្សាយដំណឹងល្អគួរប្រាប់ដល់ពួកគេទាំងអស់គ្នាឱ្យជួបជុំនៅកន្លែងតែមួយ ប្រសិនបើអាច។ សូមឱ្យប្រាកដក្នុងការអញ្ជើញពួកគេឱ្យចូលរួមគ្រប់គ្នាទោះបីអ្នកមិនទាន់សម្រេចចិត្តជឿក៏ដោយ។

ប្រើរឿងណាដែលល្អៗ រឿងជាវគ្គៗរបស់គ្រីស្ទ ប្រនើរ ដែលបានដាក់បញ្ចូលក្នុងមេរៀននេះរួចមកហើយ។ រឿងប្រភេទនេះជារឿងសាមញ្ញ មានភាពងាយស្រួលក្នុងការតាមដានសិក្សា ព្រមទាំងការអនុវត្តន៍។ *ដំណឹងល្អរបស់ព្រះយេស៊ូ* មានមេរៀនផ្សាយដំណឹងល្អប្រាំពីរ ដែលនិយាយពីជីវិតរបស់ព្រះយេស៊ូដកស្រង់ចេញពីម៉ាថាយសម្រាប់ប្រើជាមួយអ្នកមិនជឿ។ *ការចាប់ផ្តើមជីវិតក្នុងព្រះគ្រិស្ត* មានមេរៀនទៅដល់ប្រាំបី សម្រាប់ថែបំប៉នដល់ពួកអ្នកដែលជឿថ្មី។

១. ចាប់ផ្តើមមេរៀនដោយការអធិស្ឋានសូមព្រះឱ្យប្រាប់គ្រប់គ្នាយល់ពីអត្ថន័យនៃ

សាច់រឿង។

២. អានរឿងឱ្យអ្នកចូលរួមទាំងអស់ស្តាប់ ឬបើពួកគេមានមេរៀន នោះយើងត្រូវអានរួមគ្នាដោយប្រើវិធីប្រយោល។

៣. អ្នកដឹកនាំគួរសួរសំនួរដោយផ្ទាល់មាត់នៅពេលបញ្ចប់មេរៀន។ គោលបំណងនៃការសួរសំនួរទាំងនេះ គឺដើម្បីរំលឹកមេរៀន និងការយល់ដឹងរបស់ពួកគេ។ មិនមែនសម្រាប់ការជជែកវែកញែក ឬឈ្លោះប្រកែកគ្នានោះទេ។

៤. អានសេចក្តីពិតខាងវិញ្ញាណ។ អនុញ្ញាតឱ្យសមាជិកក្រុមទាំងអស់គ្នាពិភាក្សានិងសួរសំនួរដោយសេរីទាក់ទងនឹងសេចក្តីពិតខាងវិញ្ញាណ។ ចូរប្រយ័តកុំឱ្យមានការជជែកវែកញែកឥតប្រយោជន៍ ឬឈ្លោះប្រកែកគ្នាឱ្យសោះ។ ពេលនេះវាមិនមែនជាការសំខាន់សម្រាប់សមាជិកក្រុមយល់ព្រមទទួលយកនូវសេចក្តីពិតខាងវិញ្ញាណនោះទេ។ ប៉ុន្តែ ឯការសំខាន់នោះគឺថា តើពួកគេយល់ពីការបើកសម្តែងនៃសេចក្តីពិតតាមរយៈព្រះបន្ទូលរបស់ព្រះដែរឬអត់។

៥. បន្ទាប់ពីការសិក្សាសេចក្តីពិតខាងវិញ្ញាណរួចហើយ យើងត្រូវទុកពេលឱ្យគ្រប់គ្នាអាចចែកចាយពីសេចក្តីត្រូវការ និងសំណូមអធិស្ឋានរបស់ខ្លួនដល់សមាជិកក្រុមទាំងមូល។

៦. អធិស្ឋានសម្រាប់សេចក្តីត្រូវការនីមួយៗ និងសម្រាប់មនុស្សម្នាក់ៗនៅក្នុងក្រុម។ នៅពេលដែលក្រុមនេះមានការរីកចម្រើន ហើយមានមនុស្សទទួលព្រះអម្ចាស់ច្រើន យើងគួរទុកឱកាសឱ្យសមាជិកក្រុមអធិស្ឋានឱ្យគ្នាទៅវិញទៅមក ក្នុងកម្មវិធីអធិស្ឋាននេះ។

## ផ្នែកទី២: របៀបបង្ហាត់ក្រុមរបស់លោកអ្នក

### I. អ្នកត្រួសត្រាយផ្លូវផ្សាយដំណឹងល្អ និងព្រះវិញ្ញាណបរិសុទ្ធ

ក). លក្ខណៈនៃព្រះវិញ្ញាណបរិសុទ្ធ:

១. ហេព្រើរ៩:១៤: ព្រះវិញ្ញាណបរិសុទ្ធគង់នៅអស់កល្បជានិច្ច។
២. ទំនុកដំកើង១៣៩:៧-១០: ព្រះវិញ្ញាណបរិសុទ្ធសណ្ឋិតនៅគ្រប់ទីកន្លែង។
៣. លូកា១:៣៥: ព្រះវិញ្ញាណបរិសុទ្ធប្រកបដោយព្រះចេស្តា។

៤. យ៉ូហាន១៤:១២, ២៦: ព្រះវិញ្ញាណបរិសុទ្ធជ្រាបគ្រប់ការទាំងអស់។

**ខ). កិច្ចការរបស់ព្រះវិញ្ញាណបរិសុទ្ធចំពោះមនុស្សដែលបាត់បង់:**

១. យ៉ូហាន១៥:២៦-២៧: បញ្ជាក់ថា ព្រះយេស៊ូគឺសេចក្ដីពិត។
២. យ៉ូហាន១៦:៨-១១: កាត់ទោសលោកិយពីអំពើបាបសេចក្ដីសុចរិតហើយ សេចក្ដីជំនុំជម្រះ។

**គ). កិច្ចការរបស់ព្រះវិញ្ញាណបរិសុទ្ធចំពោះគ្រិស្តបរិស័ទ:**

១. ២កូរិនថូស១:២២, អេភេសូរ១:១៣-១៤: ការអះអាងពីជីវិតអស់កល្ប។
២. ទីតុស៣:៥: ការកើតជាថ្មីរបស់គ្រិស្តបរិស័ទ។
៣. រ៉ូម៨:២: ប្រោសឱ្យរួចពីអំណាចរបស់អំពើបាប និងសេចក្ដីស្លាប់។
៤. អេភេសូរ៣:១៦: ចម្រើនកម្លាំងនៃមនុស្សខាងក្នុងដោយព្រះវិញ្ញាណ។
៥. កិច្ចការ១៨: បានកើតជាថ្មី ហើយបានប្រោសឱ្យរួច ដើម្បីនឹងធ្វើបន្ទាល់។

**ឃ). ភាពពេញដោយព្រះវិញ្ញាណបរិសុទ្ធ:**

១. អេភេសូរ៥:១៨: អ្នកជឿត្រូវឱ្យបានពេញដោយព្រះវិញ្ញាណបរិសុទ្ធ។
២. កាឡាទី៥:២២-២៣: ផលផ្លែនៃព្រះវិញ្ញាណ។
៣. កិច្ចការ៤:២៩, ៣១: ប្រទាននូវសេចក្ដីក្លាហាន ដើម្បីផ្សាយព្រះបន្ទូលព្រះ។

**ង). លក្ខខណ្ឌដែលអាចពេញដោយព្រះវិញ្ញាណបរិសុទ្ធ:**

១. កិច្ចការ២:៣៨: ត្រូវតែបានសង្គ្រោះជាមុន។
២. ១យ៉ូហាន១:៩, ទំនុកដំកើង៦៦:១៨: សារភាពនូវអំពើបាប។
៣. ១យ៉ូហាន៥:១៤-១៥, រ៉ូម១:១៧: សូមព្រះវិញ្ញាណបរិសុទ្ធបំពេញ និងគ្រប់គ្រងអ្នកដោយសេចក្ដីជំនឿ។
៤. កិច្ចការ៥:៣២: ស្ដាប់បង្គាប់ព្រះអង្គជារៀងរាល់ថ្ងៃ។

**ការអនុវត្តន៍:** អធិស្ឋានសូមព្រះវិញ្ញាណបរិសុទ្ធឱ្យបើកសម្ដែងនូវអំពើបាបក្នុងជីវិតរបស់លោកអ្នក។ សារភាពនូវអំពើបាបទាំងអស់នោះ រួចសុំព្រះវិញ្ញាណបរិសុទ្ធឱ្យគ្រប់គ្រងលើទាំងអស់នៅក្នុងជីវិតរបស់អ្នក។

## II. អ្នកត្រួសត្រាយផ្លូវផ្សាយដំណឹងល្អ និងការអធិស្ឋាន

ខាងក្រោមនេះមានចំណុចនៃសេចក្តីអធិស្ឋានយ៉ាងហោចណាស់៨យ៉ាងដែល មនុស្សម្នាក់អាចយកមកប្រើនៅខណៈដែលចំណាយពេលតែម្នាក់ឯងជាមួយនឹងព្រះ។

ក) ពាក្យសរសើរតម្កើង និងការថ្វាយបង្គំ (ទំនុកដំកើង ៤៨:១,៣៤:១-៣,២២:៣)

១. ច្រៀងទំនុកបរិសុទ្ធថ្វាយព្រះ
២. ច្រៀង ឬ អានទំនុកដំកើងថ្វាយព្រះ
៣. អានគម្ពីរនៃការសរសើរដំកើងថ្វាយព្រះនៅពេលដែលអ្នកអធិស្ឋាន។
៤. ដូចជាគម្ពីរទំនុកដំកើង៨, ៩, ២៤, ៦៥, ៩២, ១០៤, ១៩៣។ល។

ខ) ការទទួលសារភាពបាប- ១ យ៉ូហាន ១:៩

គ) ពាក្យអរគុណ- ភីលីព ៤:៦

ឃ) ស្តាប់ព្រះសូរសៀងនៃព្រះ- ១១:១៥

ចាប់ផ្តើមបទគម្ពីរណាមួយ ឧទាហរណ៍ អេភេសូរ ១:១។

-អានខគម្ពីរនីមួយៗ ហើយ សូមឱ្យព្រះបង្ហាញសេចក្តីពិតខាងវិញ្ញាណ ឬ សេចក្តីពិតនៅក្នុងខនោះ។

១:________________________________________

២:________________________________________

៣:________________________________________

៤:________________________________________

- ទទួលស្គាល់គ្រប់ទាំងសេចក្តីពិត និងខាងវិញ្ញាណដោយផ្ទាល់ខ្លួនថា ព្រះមានបន្ទូលមកកាន់អ្នក។

១:________________________________________

២:________________________________________

៣:________________________________________

៤: ____________________

- ប្រើសេចក្តីពិតខាងវិញ្ញាណនោះសម្រាប់អធិស្ឋានទៅកាន់ព្រះ។

ង) ពាក្យទូលអង្វរ- អេភេសូរ ៦:១៨: ធ្វើតារាងអធិស្ឋានរាល់ថ្ងៃប្រចាំសប្តាហ៍

ច) សញ្ជឹងគិត និងចងចាំខគម្ពីរ- យ៉ូស្វេ ១៨

ឆ) ពាក្យទូលសូម- ហេព្រើរ៤:១៦

## III. អ្នកត្រួសត្រាយផ្លូវផ្សាយដំណឹងល្អ និងសេចក្តីសង្គ្រោះ

ក) តើដំណឹងល្អគឺជាអ្វី? ១ កូរិនថូស ១៥:៤

____________________

____________________

ខ) តើជីវិតអស់កល្បគឺជាអ្វី? យ៉ូហាន ១៧:៣

____________________

____________________

គ) តើការប្រែចិត្តគឺជាអ្វី? ម៉ាកុស ១:១៥

____________________

____________________

ឃ) តើសេចក្តីជំនឿគឺជាអ្វី? ម៉ាកុស ១:១៥

____________________

____________________

## IV. អ្នកត្រួសត្រាយផ្លូវផ្សាយដំណឹងល្អ និងទីបន្ទាល់ផ្ទាល់ខ្លួន

ក) តើជីវិតរបស់ខ្ញុំមានសណ្ឋានយ៉ាងដូចម្ដេច មុនពេលដែលបានជួបនឹងព្រះគ្រិស្ត? កិច្ចការ ២២:១-៥

ខ) តើធ្វើដូចម្ដេចទើបខ្ញុំដឹងថា ខ្ញុំត្រូវការព្រះគ្រិស្ត? កិច្ចការ ២២:៦-៨

គ) តើខ្ញុំបានទទួលព្រះគ្រិស្តនៅទីណាហើយយ៉ាងដូចម្ដេច? កិច្ចការ២២:៩-១៣

ឃ) តើ ជីវិតរបស់ខ្ញុំ មានលក្ខណៈខុសប្លែកយ៉ាងដូចម្ដេច តាំងពីបានទទួលព្រះគ្រិស្តមក? កិច្ចការ ២២:១៤-១៨

## V. អ្នកត្រួសត្រាយផ្លូវផ្សាយដំណឹងល្អ និងការផ្សាយដំណឹងល្អផ្ទាល់ខ្លួន—ខគម្ពីរប្រាំមួយដែលពន្យល់ដំណឹងល្អ

ប្រសិនបើអ្នកផ្សាយដំណឹងល្អម្នាក់ដែលវប្បធម៌ប្រពៃណីរបស់គាត់មិនមែនជាគ្រិស្តបរិស័ទ ឬក៏រស់នៅក្នុងវប្បធម៌ជាគ្រិស្តបរិស័ទយ៉ាងណាក៏ដោយ តែធាតុពិតនៃដំណឹងល្អមិនដែលផ្លាស់ប្តូរទេ។ ខទាំង៦នេះនឹងពន្យល់យ៉ាងច្បាស់លាស់ពីគ្រឹះសំខាន់នៃដំណឹងល្អ។

ក) ព្រះមានគោលបំណងសម្រាប់ជីវិតរបស់អ្នក- យ៉ូហាន ៥:១៣

- គោលបំណងនៃខគម្ពីរៈ ប្រាប់យើងឱ្យដឹងប្រាកដថា យើងអាចមានជីវិតអស់កល្បជានិច្ច។
- សេចក្តីពន្យល់លើខគម្ពីរៈ
១. ស្គាល់ព្រះយេស៊ូគ្រិស្ត ហើយឥឡូវនេះមានសេចក្តីមេត្រីនៅក្នុងចិត្ត។
២. រស់នៅជាមួយនឹងព្រះយេស៊ូគ្រិស្តនៅឯស្ថានសួគ៌អស់កល្បជានិច្ច។
- ការអនុវត្តន៍ចំពោះខគម្ពីរៈ តើអ្នកមានការធានាអះអាងចំពោះជីវិតអស់កល្បដែរឬទេ?

ខ) សេចក្តីត្រូវការរបស់អ្នក- រ៉ូម ៣:២៣

- គោលបំណងនៃខគម្ពីរៈ ប្រាប់យើងឱ្យដឹងថា មនុស្សទាំងអស់មានបាប។
- សេចក្តីពន្យល់លើខគម្ពីរៈ អំពើបាប គឺជាការមិនស្តាប់បង្គាប់ព្រះ។
- សេចក្តីពន្យល់លើខគម្ពីរៈ តើអ្នកធ្លាប់ធ្វើបាបដែរឬទេ?

រ៉ូម ៦:២៣
- គោលបំណងនៃខគម្ពីរៈ ប្រាប់យើងឱ្យដឹងថា ការប្រោសលោះមានតែមួយ។
- សេចក្តីពន្យល់លើខគម្ពីរៈ សេចក្តីស្លាប់មានន័យថា ការបែកចេញពីព្រះតាមរបៀបពីរយ៉ាង៖
  ១. បែកចេញពេលដែលមានជីវិតរស់នៅលើផែនដី។
  ២. បែកចេញពីព្រះក្រោយពេលស្លាប់ ហើយអស់កល្បជានិច្ច។
- សេចក្តីពន្យល់លើខគម្ពីរៈ តើអ្នកយល់ថា អ្នកនឹងត្រូវបែកចេញពីព្រះដោយព្រោះអំពើបាបឬទេ?

គ) ការផ្គត់ផ្គង់របស់ព្រះជាម្ចាស់- រ៉ូម ៥:៨

- **គោលបំណងនៃខគម្ពីរៈ** ប្រាប់យើងឱ្យដឹងពីដំណោះស្រាយនៃអំពើបាប។
- **សេចក្តីពន្យល់លើខគម្ពីរៈ** ព្រះយេស៊ូគ្រិស្តបានទទួលទណ្ឌកម្មការអត់ទោស រហូតត្រូវបានគេសម្លាប់នៅលើឈើឆ្កាងដើម្បីលោះបាបយើងទាំងអស់គ្នា។
- **សេចក្តីពន្យល់លើខគម្ពីរៈ** តើអ្នកជឿថា ព្រះយេស៊ូគ្រិស្តគឺជាដង្វាយតែមួយគត់ដើម្បីឱ្យធួននឹងបាបអ្នកដែរឬទេ?

ឃ) ការឆ្លើយតបរបស់អ្នក- រ៉ូម ១០:៩

- **គោលបំណងនៃខគម្ពីរៈ** ប្រាប់យើងឱ្យទទួលព្រះយេស៊ូធ្វើជាព្រះអម្ចាស់និងជាព្រះអង្គសង្គ្រោះ។
- **សេចក្តីពន្យល់លើខគម្ពីរៈ** ដើម្បីទទួលព្រះយេស៊ូបាន អ្នកត្រូវធ្វើការពីរយ៉ាង
  ១. ទទួលព្រះយេស៊ូគ្រិស្តថា ជាព្រះអម្ចាស់តែមួយរបស់អ្នក។
  ២. ជឿក្នុងចិត្តថា ព្រះគ្រិស្តបានរស់ពីសុគតឡើងវិញ ហើយព្រះអង្គជាព្រះអង្គសង្គ្រោះរបស់អ្នកតែមួយគត់។ មានន័យថា ថ្វាយជីវិតរបស់អ្នកដល់ព្រះយេស៊ូគ្រិស្ត។
- **សេចក្តីពន្យល់លើខគម្ពីរៈ** តើអ្នកចង់ថ្វាយជីវិតរបស់អ្នកដល់ព្រះយេស៊ូដែលជាព្រះអង្គសង្គ្រោះ និងជាព្រះអម្ចាស់ដែរឬទេ?

# ផ្នែកទី៣

## ផែនការ

THE PLAN

## ជំហានក្នុងការបង្កើតក្រុមជំនុំថ្មី

STEPS TO START A NEW CHURCH

# ផែនការ

## ជំហានទី១

នៅក្នុងការបង្កើតក្រុមជំនុំ គឺចាប់ផ្តើមពីចំណុចសូន្យរហូតទៅដល់ចំណុចមួយដែលអ្នកអាចរៀបចំជារចនាសម្ព័ន្ធរបស់ព្រះវិហារ។

## ជំហានទី២

អ្នកនឹងរៀបចំនូវរចនាសម្ព័ន្ធការងារថ្មីមួយ។ មានគំរូជាច្រើនក្នុងការរៀបចំនូវក្រុមជំនុំថ្មីមួយ ប៉ុន្តែយើងនឹងលើកយកមកនិយាយតែចំនួនបួនប៉ុណ្ណោះ។ នៅក្នុងជំពូកនោះយើងនឹងយកតែផែនការសម្រាប់ជំហានទី១តែប៉ុណ្ណោះ។

## ១. ក្រុមជំនុំសម័យដើម

គំរូនេះផ្តែកទៅលើកម្មវិធីជាមូលដ្ឋានក្រុមជំនុំបែបនេះតែងតែមានកម្មវិធីដូចជាថ្នាក់រៀនសម្រាប់ថ្ងៃអាទិត្យ ហើយក្រុមជំនុំបែបនោះមានការសង្កត់យ៉ាងខ្លាំងទៅលើអាគារហើយគ្រូគង្វាលរ ឬក៏ក្រុមចាស់ទុំ មានអំណាចយ៉ាងខ្លាំងក្នុងការគ្រប់គ្រង។

## ២. ក្រុមជំនុំសាខា

គំរូនេះជាទូទៅមានការគាំទ្រពីក្រុមជំនុំមេមួយ ដែលគេមានចំនួនបេសកកម្មឬក្រុមជំនុំជាច្រើន។ ក្រុមជំនុំមេឬអ្នកគាំទ្រនោះគឺជាអ្នកគ្រប់គ្រងក្រុមជំនុំ និងបេសកកម្មនេះ។ នៅក្នុងក្រុមជំនុំនីមួយៗ «នឹងមានការថ្វាយបង្គំ ការសិក្សាព្រះគម្ពីរ ការប្រកបគ្នា»។ល។

ពេលខ្លះគេថ្វាយបង្គំនៅក្នុងផ្ទះ នៅតាមកន្លែងទំនេរ តែពួកគេនៅតែជាសមាជិករបស់ក្រុមជំនុំមេ ហើយដង្វាយដែលបានមកគេតែងតែបញ្ជូនទៅក្រុមជំនុំមេ។ អ្វីដែលជាបញ្ហានោះគឺក្រុមជំនុំរណបទាំងនោះមិនមានទស្សនៈខ្លួនឯងអំពីការ

រីកចម្រើន ឬក៏បង្កើតផលទៅទៀតលុះត្រាតែក្រុមជំនុំមេរៀបចំឱ្យ។ ហើយមានករណីជាច្រើនដែលថា ដើម្បីឱ្យគេរៀបចំបានលុះត្រាតែគេមានដីអាគារ និងគ្រូគង្វាល។ ដែលរបស់ទាំងអស់នេះសុទ្ធតែមកពីតម្រូវការរបស់មនុស្សមិនមែនមកពីព្រះ។

## ៣. ក្រុមជំនុំកោសិកា

គំរូនេះនៅពេលដែលក្រុមជំនុំមេមានក្រុមតូចដែលជាកោសិកាជាច្រើនជួបប្រជុំគ្នាតាមផ្ទះ ការិយាល័យ និងទីកន្លែងទំនេរ។ ដែលក្រុមតូចទាំងនោះបានរៀបចំឡើង ដោយមាន ដូចជា ក្រុមកោសិកាយុវជន ក្រុមកោសិកាស្រ្តី ក្រុមកោសិកាបុរស។ល។ ការសំខាន់ការប្រជុំក្រុមកោសិកានេះ គឺគិតពីសហគមន៍ និងជីវិត ការគ្រប់គ្រង ការថែរក្សាសមាជិក និងការទទួលខុសត្រូវ។

ការធ្វើពិធីលៀងព្រះអម្ចាស់ ជ្រមុជទឹក ក៏ធ្វើនៅក្នុងកម្រិតក្រុមកោសិកាបានដែរ។ អ្នកដែលបង្កើតជាអ្នកដែលបង្កើតបទបញ្ញត្តិដឹកនាំក្រុមនីមួយៗ។ នៅរៀងរាល់សប្តាហ៍ក្រុមនីមួយៗអាចជួបជុំគ្នាការថ្វាយបង្គំ។

តាមមូលដ្ឋាននៃទីតាំង ភូមិសាស្រ្តផ្ទាល់។ ពួកគេក៏អាចធ្វើពិធីលៀងព្រះអម្ចាស់ ឬក៏ពិធីជ្រមុជទឹកនៅក្នុងចំណោមក្រុមតូចផងដែរ។

## ៤. ក្រុមជំនុំដែលមានការរួបរួម គោរពកោតខ្លាចព្រះ អ្នកដឹកនាំមិនមានប្រាក់ខែ មានលក្ខណៈជាកោសិកា និង ជួបជំនុំតាមផ្ទះ

គំរូនេះបានបង្កើតឡើងដោយបេសកជនម្នាក់ឈ្មោះ **Curtis Sargaent** ដែលក្រុមជំនុំតូចកើនឡើងនៅក្នុងផ្ទះអ្នកដែលទើបនឹងជឿថ្មី។ ហើយពួកគេទាំងអស់នោះជាអ្នកដឹកនាំដោយមិនមានប្រាក់កម្រៃរហូតដល់ក្រុមជំនុំរីកបានចំនួន១៥នាក់ និងក្រោយមកកើតទ្វេរឡើង ហើយគេក៏ចាប់ផ្តើមបំបែក។ ក្រុមនីមួយៗគឺជាក្រុមជំនុំឯករាជ្យដែលនៅក្នុងតំបន់ដាច់ដោយឡែកពីគ្នា។ ពាក្យ **POUCH** មានន័យថា

**P = Participation** «ការចូលរួម» សមាជិកទាំងអស់ចូលរួមសិក្សាព្រះគម្ពីរ ការថ្វាយបង្គំ និងជីវិតរស់នៅប្រចាំថ្ងៃ។

**O = Obedience** «ស្តាប់បង្គាប់» នេះគឺជាស្តង់ដានៃការវាស់វែងសម្រាប់ទទួលជោគជ័យ ហើយមិនមែនសំដៅលើការរីកចម្រើនប៉ុណ្ណោះទេ។

**U = Unpaid leader** «អ្នកដឹកនាំដែលមិនមានប្រាក់ខែ» អ្នកដឹកនាំ និងគ្រូគង្វាល

ទាំងអស់ជាមនុស្សធម្មតា។

**C = Cells** «កោសិកា» ពួកគេជួបគ្នានៅក្នុងក្រុមតូច។

**H = House** «ផ្ទះ» ថ្វាយបង្គំនៅតាមផ្ទះ។

# ផ្នែកទី៤

## សេចក្តីពិតប្រាំមួយយ៉ាងសម្រាប់អ្នកជឿថ្មី

## SIX TRUTHS FOR THE NEW CONVERT

នៅក្នុងព្រះគម្ពីរកូល៉ុស ២:៦ *«ដូច្នេះ បើបងប្អូនបានទទួលព្រះគ្រិស្តយេស៊ូទុកជាព្រះអម្ចាស់យ៉ាងណាហើយ ចូររស់នៅជាមួយព្រះអង្គយ៉ាងនោះតទៅទៀតទៅ»*នៅក្នុងមេរៀននេះលោកអ្នកនឹងរៀនពីរបៀបរស់នៅក្នុងការប្រកបស្និទ្ធស្នាលជាមួយព្រះយេស៊ូគ្រិស្ត។

នៅពេលលោកអ្នកបានកើតខាងឯសាច់ឈាមលោកអ្នកកើតតែម្តងគត់នៅពេលលោកអ្នកបានទទួលជឿព្រះយេស៊ូគ្រិស្តលោកអ្នកកើតខាងឯព្រលឹងវិញ្ញាណ ហើយលោកអ្នកក៏កើតតែម្តងដែរ។ នេះហើយគឺជាអ្វីដែលព្រះគម្ពីរយ៉ូហាន៣ហៅថា«ការកើតជាថ្មី»។ ខាងឯសាច់ឈាមលោកអ្នកមិនអាចត្រូវបានកើតជាថ្មីជារៀងរាល់ថ្ងៃអាទិត្យនោះទេ ហើយនេះក៏ជាការពិតផងដែរជាមួយនឹងកំណើតខាងឯព្រលឹងវិញ្ញាណរបស់លោកអ្នក។

## ១. ការធានាអះអាងនៃសេចក្តីសង្គ្រោះ និង ជីវិតដ៏នៅអស់កល្ប

### សេចក្តីពិតទី១

តើអ្វីទៅជាជីវិតដ៏នៅអស់កល្បជានិច្ចយ៉ូហាន ១:៧៣ចែងថា *«រីឯជីវិតអស់កល្បជានិច្ចនោះ គឺឱ្យគេស្គាល់ព្រះអង្គដែលជាព្រះអម្ចាស់ដ៏ពិតតែមួយគត់ និងឱ្យគេស្គាល់ព្រះយេស៊ូគ្រិស្តដែលព្រះអង្គចាត់ឱ្យមក»*។ នៅក្នុងន័យមួយទៀតជីវិតដ៏នៅអស់កល្បជានិច្ចគឺព្រះយេស៊ូគង់នៅក្នុងចិត្តរបស់លោកអ្នក (វិញ្ញាណ)។ នេះមានន័យថា នៅពេលព្រះយេស៊ូចូលមកគង់នៅក្នុងជីវិតរបស់លោកអ្នកព្រះអង្គនឹងប្រទាននូវជីវិតថ្មីដល់លោកអ្នក ហើយលោកអ្នកនឹងរស់នៅអស់កល្បជានិច្ចជាមួយព្រះអង្គនៅឯស្ថានសួគ៌។

១ យ៉ូហាន៥:១២ចែងថា *«អ្នកណាមានព្រះបុត្រា អ្នកនោះក៏មានជីវិតដែរ ហើយអ្នកណាគ្មានព្រះបុត្រារបស់ព្រះជាម្ចាស់ទេ អ្នកនោះគ្មានជីវិតនេះឡើយ ឯអ្នកណាដែលមានព្រះរាជបុត្រានោះក៏មានជីវិតដែរតែអ្នកណាដែលគ្មានព្រះរាជបុត្រានៃព្រះទេនោះគ្មានជីវិតឡើយ»*។

តើនឹងមានអ្វីកើតឡើង នៅពេលលោកអ្នកធ្វើបាបក្រោយពេលបងប្អូនបានទទួលជឿព្រះយេស៊ូគ្រិស្តនោះ? លោកអ្នកមិនបានបាត់នូវសេចក្តីសង្គ្រោះលោកអ្នក

នោះទេ។ សូមឱ្យខ្ញុំពន្យល់ ខ្ញុំមានកូន៣នាក់ ហើយពេលខ្លះពួកគេមិនស្តាប់បង្គាប់ខ្ញុំទេ តើលោកអ្នកគិតថា ខ្ញុំចង់ឱ្យគេចាកចេញទៅជារៀងរហូតឬអី? មិនមែនទេ! ពួកគេជាកូនរបស់ខ្ញុំ ហើយខ្ញុំស្រឡាញ់ពួកគេ អ្វីដែលខ្ញុំត្រូវធ្វើគឺកែតម្រង់ពួកគេ បង្រៀនពួកគេ និងបង្វឹកបង្ហាត់ពួកគេ។

នៅក្នុងគម្ពីរហេព្រើរ ១២:៧-៨ ចែងថា *«បើសិនអ្នករាល់គ្នាត្រូវការសេចក្ដីផ្ចាញ់ផ្ចាល់នោះគឺព្រះទ្រង់ប្រព្រឹត្តនឹងអ្នករាល់គ្នាដូចជាកូនហើយ ដ្បិតតើមានកូនឯណាដែលឪពុកមិនវាយផ្ចាល់នោះ តើបើសិនជាអ្នករាល់គ្នាមិនដែលត្រូវផ្ចាញ់ផ្ចាលសោះជាសេចក្ដីដែលគ្រប់គ្នាត្រូវរងទ្រាំ នោះអ្នករាល់គ្នាជាកូនឥតខាន់ស្លាទេមិនមែនជាកូនពិតប្រាកដនោះឡើយ»។*

*«លោកអ្នកស៊ូទ្រាំនឹងការប្រដៅបែបនេះមកពីព្រះជាម្ចាស់រាប់លោកអ្នកថាជាកូន។តើមានកូនណាដែលឪពុកមិនវាយប្រដៅ? ប្រសិនបើលោកអ្នកមិនបានទទួលការវាយប្រដៅដូចកូនឯទៀតៗទទួលទេនោះបានសេចក្ដីថា លោកអ្នកជាកូនឥតខាន់ស្លា មិនមែនជាកូនពេញច្បាប់ឡើយ»* នៅក្នុងយ៉ូហាន១:១២ចែងថា *«រីឯអស់អ្នកដែលបានទទួលព្រះអង្គ គឺអស់អ្នកដែលជឿលើព្រះនាមព្រះអង្គ ព្រះអង្គប្រទានអំណាចឱ្យគេត្រលប់ទៅជាបុត្រធីតារបស់ព្រះជាម្ចាស់»* ។*«ប៉ុន្តែអស់ណាដែលទទួលទ្រង់គឺអស់អ្នកដែលជឿដល់ព្រះនាមទ្រង់នោះទ្រង់បានប្រទានអំណាចឱ្យត្រលប់ជាកូនព្រះ»*។

ដូច្នេះកូនរបស់ព្រះជាម្ចាស់នឹងត្រូវបានកែតម្រង់នៅពេលគេភ្លាត់ធ្វើអំពើបាប។ ប្រសិនបើគ្មានទេអ្នកពិតជាមិនមែនជាកូនរបស់ព្រះនោះទេ។ ប៉ុន្តែកូនដ៏ពិតមិនអាចបាត់នូវសេចក្ដីសង្គ្រោះរបស់គេបានទេ ពីព្រោះគេមានជីវិតដ៏នៅអស់កល្បជានិច្ច។

ប្រសិនជាលោកអ្នកភ្លាត់ធ្វើអំពើបាបក្រោយពេលដែលលោកអ្នកបានទទួលជឿព្រះគ្រិស្ត ព្រះទ្រង់នឹងផ្ចាញ់ផ្ចាល់លោកអ្នក ដើម្បីបង្វឹកបង្ហាត់លោកអ្នក ឱ្យដើរទៅតាមផ្លូវដ៏សុចរិតវិញ។ ទ្រង់នឹងមិនដកយកនូវសេចក្ដីសង្គ្រោះរបស់លោកអ្នកចេញនោះទេ។សេចក្ដីសង្គ្រោះរបស់លោកអ្នកគឺនៅអស់កល្បជានិច្ច ហើយអស់កល្បជារៀងរហូត។

# ២. ការជ្រមុជទឹក

## សេចក្ដីពិតទី២

ព្រះយេស៊ូមានបន្ទូលនៅក្នុងព្រះគម្ពីរម៉ាថាយ២៨:១៩ *«ដូច្នេះចូរទៅបញ្ចុះបញ្ចូលឱ្យមានសិស្សទាំងគ្រប់ទាំងសាសន៍ព្រមទាំងធ្វើបុណ្យជ្រមុជទឹកឱ្យដោយនូវព្រះនាមព្រះវរបិតា ព្រះរាជបុត្រា និងព្រះវិញ្ញាណបរិសុទ្ធចុះ» ។ « ដូច្នេះ ចូរចេញទៅនាំមនុស្សគ្រប់ជាតិសាសន៍ឱ្យធ្វើជាសិស្ស ហើយធ្វើពិធីជ្រមុជទឹកឱ្យគេក្នុងព្រះនាមព្រះបិតា ព្រះបុត្រា និងព្រះវិញ្ញាណបរិសុទ្ធ»* ។

ប្រហែលជាលោកអ្នកធ្លាប់បានទទួលពិធីជ្រមុជទឹកតាំងពីលោកអ្នកនៅជាទារកមកម្ល៉េះ ។ ប៉ុន្តែ ព្រះយេស៊ូមានបន្ទូលថាបានតែអស់អ្នកដែល ជាដើរតាម ព្រះអង្គប៉ុណ្ណោះដែលមានសិទ្ធិនឹងទទួលការជ្រមុជទឹកបាន។ លោកអ្នកមិនមែនជាអ្នកដើរតាមព្រះយេស៊ូគ្រិស្តនោះទេ កាលពីលោកអ្នកនៅជាទារកនោះលោកអ្នកមិនទាំងដឹងអ្វីបន្តិចផង អំពីព្រះយេស៊ូ ។ លោកអ្នកទើបក្លាយជាអ្នកដើរតាមព្រះគ្រិស្តនៅពេលលោកអ្នកបានទទួលព្រះអង្គមកគង់នៅក្នុងចិត្តរបស់លោកអ្នកទៅតាមសេចក្ដីជំនឿ និងការប្រែចិត្ត។

តើហេតុអ្វីបានជាយើងមិនគួរទទួលការជ្រមុជទឹកក្នុងកាលដែលយើងនៅជាទារកនៅឡើយ? ពីព្រោះការជ្រមុជទឹកគឺជានិមិត្តសញ្ញា (ជាអត្ថន័យនៃការកំណត់សំគាល់) ថា លោកអ្នកជាអ្នកដើរតាមព្រះគ្រិស្តមួយរូប។

នៅក្នុងព្រះគម្ពីរ អ្នកជឿទាំងអស់ត្រូវបានទទួលការជ្រមុជទឹកដោយលេចចូលទៅក្នុងទឹកក្រោយពីពួកគេបានទទួលជឿព្រះយេស៊ូហើយ។ តើការលេចចូលទៅក្នុងទឹកមានន័យយ៉ាងដូចម្ដេច?

នៅពេលលោកអ្នកទទួលការជ្រមុជទឹក នឹងមានម្នាក់ជ្រមុជខ្លួនរបស់លោកអ្នកទាំងមូលឱ្យលេចចូលទៅក្នុងទឹក ហេតុអ្វី? ពីព្រោះនេះជាសញ្ញានៃការស្លាប់ការបញ្ចុះ និងការរស់ឡើងវិញនៃព្រះយេស៊ូ។ លោកអ្នកមិនអាចធ្វើការនេះក្នុងកាលដែលលោកអ្នកនៅជាទារកនៅឡើយទេ។ ប៉ុន្តែ លោកអ្នកគួរតែធ្វើការនេះក្រោយពេលបងប្អូនទទួលជឿព្រះគ្រិស្តហើយ។

គម្ពីររ៉ូម ៦:៣-៤ ចែងថា *«តើអ្នករាល់គ្នាមិនដឹងឬអីថា យើងទាំងប៉ុន្មានដែល*

*បានទទួលបុណ្យជ្រមុជក្នុងព្រះយេស៊ូគ្រិស្តនោះ គឺបានទទួលជ្រមុជក្នុងសេចក្តីសុគតនៃទ្រង់ ដូច្នេះយើងបានត្រូវកប់ជាមួយនឹងទ្រង់ហើយ ដោយទទួលជ្រមុជក្នុងសេចក្តីស្លាប់ដើម្បីឱ្យយើងបានដើរក្នុងជីវិតបែបថ្មីដូចជាព្រះគ្រិស្តបានរស់ពីស្លាប់ឡើងវិញ ដោយសារសិរីល្អនៃព្រះវរបិតាដែរ»។*

*«តើលោកអ្នកមិនជ្រាបទេឬ យើងទាំងអស់គ្នាដែលបានទទួលពិធីជ្រមុជទឹកដើម្បីរួមជាមួយព្រះគ្រិស្តយេស៊ូ នោះ គឺយើងបានជ្រមុជរួមជាមួយព្រះអង្គដែលសោយទិវង្គត។ ហេតុនេះ ដោយពិធីជ្រមុជទឹកដើម្បីរួមស្លាប់ជាមួយព្រះអង្គ យើងដូចជាបានចូលទៅក្នុងផ្នូររួមជាមួយព្រះអង្គដែរ»។*

ទឹកមិនអាចនឹងសង្គ្រោះយើងបានទេ មានតែព្រះយេស៊ូគ្រិស្តប៉ុណ្ណោះដែលអាចសង្គ្រោះយើងបាន។ ការទទួលពិធីជ្រមុជទឹករបស់អ្នក គឺជាសញ្ញាដំបូងបង្អស់ដែលបង្ហាញថា លោកអ្នកពិតជាសម្រេចចិត្តដើរតាមព្រះគ្រិស្ត។ ប្រសិនលោកអ្នកមិនដឹងថា កន្លែងណាដែលលោកអ្នកនឹងត្រូវទៅធ្វើពិធីជ្រមុជទឹក លោកអ្នកអាចសួរដល់អ្នកដឹកនាំរបស់លោកអ្នកបាន។

## ៣. ចូរអានព្រះគម្ពីររបស់លោកអ្នក

### សេចក្តីពិតទី៣

ទំនុកដំកើង១១៩:១០៥ចែងថា *«ព្រះបន្ទូលរបស់ព្រះអង្គជាចង្កៀងបំភ្លឺជំហានទូលបង្គំ និងជាពន្លឺបំភ្លឺផ្លូវរបស់ទូលបង្គំ»*។ *«ព្រះបន្ទូលនៃទ្រង់ជាចង្កៀងដល់ជើងទូលបង្គំ ហើយជាពន្លឺបំភ្លឺផ្លូវរបស់ទូលបង្គំផង»*។ ព្រះគម្ពីរជាព្រះបន្ទូលនៃព្រះ។ ផ្នែកដំបូងហៅថា ព្រះគម្ពីរសញ្ញាចាស់។ ផ្នែកទីពីរហៅថា ព្រះគម្ពីរសញ្ញាថ្មី។ ពាក្យថាTestament មានន័យថា «កតិកាសញ្ញា»។

តើអ្នកគួរអានព្រះគម្ពីររបស់អ្នកដោយរបៀបណា? ព្រះគម្ពីរជាសំបុត្រនៃសេចក្តីស្រលាញ់របស់ព្រះមកកាន់លោកអ្នក។ អានព្រះគម្ពីររបស់លោកអ្នកដោយ**ប្រើនូវវិធីដូចខាងក្រោម៖**

១. ចាប់ផ្តើមអានសៀវភៅ ឧទាហរណ៍ដូចជា: សៀវភៅយ៉ូហាន

២. អាននូវខដំបូង

៣. ទូលសូមដល់ព្រះជាម្ចាស់ ដើម្បីឱ្យព្រះអង្គបង្ហាញលោកអ្នកនូវសេចក្តីពិតខាងឯព្រលឹងវិញ្ញាណនៅក្នុងខដែលលោកអ្នកកំពុងអាន។ ឧទាហរណ៍ដូចជាៈ យ៉ូហាន១:១ *«កាលពីដើមដំបូងបង្អស់ ព្រះបន្ទូលមានព្រះជន្មគង់នៅ។ ព្រះបន្ទូលបែរទៅរកព្រះជាម្ចាស់ ហើយព្រះបន្ទូលជាព្រះជាម្ចាស់»*។

*«កាលដើមដំបូងមានព្រះបន្ទូលព្រះបន្ទូលក៏គង់នៅជាមួយនឹងព្រះ ហើយព្រះបន្ទូលនោះឯងជាព្រះ»*។

តើសេចក្តីពិតអ្វីខ្លះដែលបានរកឃើញនៅក្នុងខនេះ?

ក. ពិភពលោកត្រូវបានបង្កើតឡើងដោយព្រះបន្ទូល

ខ. ព្រះបន្ទូលជាព្រះ

(នៅក្នុងខ.១៤ ក្រោយមកប្រាប់យើងថា ព្រះបន្ទូលនោះជាព្រះយេស៊ូ)។

៤. អាននូវខនីមួយៗ ឬអត្ថបទនីមួយៗដោយប្រើវិធីនេះ ហើយអនុញ្ញាតឱ្យព្រះជាម្ចាស់មានបន្ទូលមកកាន់លោកអ្នកអំពីព្រះអង្គជានរណា អំពីអំពើបាបរបស់លោកអ្នក ដើម្បីឱ្យលោកអ្នកគោរព និងដើរតាមព្រះបន្ទូលព្រះអង្គជាដើម...។ ល។

# ៤. ការអធិស្ឋាន

## សេចក្តីពិតទី៤

ព្រះជាម្ចាស់មានបន្ទូលនៅក្នុងព្រះគម្ពីរលូកា១៨:១ថា យើងគួរតែអធិស្ឋានគ្រប់ពេលវេលា ហើយឥតឈប់ឈរ។ តើលោកអ្នកអាចអធិស្ឋានដោយរបៀបណា? វាជាការសំខាន់បំផុតដែលលោកអ្នកមានពេលវេលាតែម្នាក់ឯងជាមួយនឹងព្រះ។ ចាប់ផ្តើមពេលវេលារបស់លោកអ្នកដោយប្រើនូវវិធីនេះ៖

១. ការអានព្រះគម្ពីរ- ប្រើនូវវិធី ៣ ជំហានដោយប្រើរយៈពេល៥នាទី

២. សរសើរតម្កើងនិយាយថា «ឱព្រះវរបិតាកូនស្រឡាញ់ព្រះអង្គដោយព្រោះ..»

៣. អរព្រះគុណ- «អរព្រះគុណព្រះអម្ចាស់ដោយព្រោះ...»

៤. អធិស្ឋានសម្រាប់អ្នកដទៃ- «ឱព្រះជាម្ចាស់អើយកូនសូមអធិស្ឋានសម្រាប់កូនរបស់ទូលបង្គំចំពោះសេចក្តីត្រូវការរបស់គាត់» (បន្តដោយអធិស្ឋានសម្រាប់អស់

អ្នកដែលទទួលជឿព្រះយេស៊ូនេះក្នុងជីវិតរបស់ពួកគេ) ចូរសរសេរឈ្មោះមនុស្ស ដែលលោកអ្នកស្គាល់ សរសេរឈ្មោះទាំងនេះនៅលើបញ្ជីសម្រាប់ថ្ងៃអាទិត្យ ច័ន្ទ អង្គារ...។ល។

(ហើយអធិស្ឋានសម្រាប់ពួកគេនៅថ្ងៃទាំងនេះ)

៥. ការផ្គត់ផ្គង់- ទូលដល់ព្រះនូវអ្វីដែលលោកអ្នកត្រូវការ

៦. លន់តួ- នៅដោយស្ងាត់ស្ងៀមក្នុងពេលមួយ ហើយទូលសូមដល់ព្រះដើម្បីឱ្យព្រះអង្គបណ្តាលឱ្យគំនិតរបស់លោកអ្នកបានគិតឃើញនូវអស់ទាំងអំពើបាបឬការអាក្រក់ទាំងអស់នៅក្នុងជីវិតរបស់លោកអ្នក១យ៉ូហាន១:៩ « *បើយើងលន់តួបាបវិញ នោះទ្រង់មានព្រះហឫទ័យស្មោះត្រង់ហើយសុចរិតប្រយោជន៍នឹងអត់ទោសបាបឱ្យយើង ហើយនិងសំអាតយើងពីគ្រប់អំពើទុច្ចរិតទាំងអស់ផង*»។ «*ប៉ុន្តែ បើយើងទទួលសារភាពអំពើបាបរបស់យើង នោះព្រះជាម្ចាស់ដែលមានព្រះហឫទ័យស្មោះស្ម័គ្រ និង សុចរិត ទ្រង់នឹងអត់ទោសយើងឱ្យរួចពីបាបព្រមទាំងជំរះយើងឱ្យបានបរិសុទ្ធ រួចពីគ្រប់អំពើទុច្ចរិតទាំងអស់ផង*»។ ខនេះគឺត្រូវបានសរសេរសម្រាប់អស់អ្នកដែលបានទទួលជឿព្រះគ្រិស្ត រួចហើយនៅពេលលោកអ្នកខ្វក់ លោកអ្នកត្រូវតែលាងសំអាត រីការប្រែចិត្តរបស់គ្រិស្តបរិស័ទ គឺជាការលាងសំអាតខាងឯព្រលឹងវិញ្ញាណ។

## ៥. ក្លាយទៅជាសមាជិកនៃក្រុមជំនុំផ្សាយដំណឹងល្អ

### សេចក្តីពិតទី៥

អេភេសូរ១:២២ចែងថា «*ដល់ពួកជំនុំជារូបកាយរបស់ព្រះគ្រិស្ត*» ព្រះយេស៊ូគ្រិស្តគឺជាព្រះសិរិសាររបស់ក្រុមជំនុំ អេភេសូរ១:២២ ចែងថា « *ហើយទ្រង់បានបង្ក្រាបគ្រប់ទាំងអស់នៅក្រោមព្រះបាទនៃព្រះរាជបុត្រា ទាំងប្រទានទ្រង់ធ្វើជាសិរិសាលើគ្រប់ទាំងអស់ដល់ពួកជំនុំ*» « *ព្រះជាម្ចាស់បានបង្ក្រាបអ្វីៗទាំងអស់ឱ្យទៅក្រោមព្រះបាទារបស់ព្រះគ្រិស្ត ព្រមទាំងប្រទានឱ្យព្រះអង្គគង់នៅលើអ្វីៗទាំងអស់ធ្វើជាសិរសាលើក្រុមជំនុំ*»។

ពាក្យថា ពេត្រុសមានន័យថា«សិលា»ព្រះយេស៊ូមានបន្ទូលក្នុងន័យពីនេះនៅ

ក្នុង ព្រះគម្ពីរ ម៉ាថាយ ១៦:១៨ ព្រះជាម្ចាស់ មិន បាន មាន បន្ទូល ថា ពេត្រុស គឺ ជា សិរិសានៃពួកជំនុំនោះទេ ប៉ុន្តែថាព្រះយេស៊ូជាប្រធានលើអស់ទាំងថ្មជ្រុងឯកនោះវិញ។ ១ កូរិនថូស ៣:១១ចែងថា *«ដ្បិតគ្មានអ្នកណាអាចនឹងដាំជើងជញ្ជាំងណាផ្សេងទៀតក្រៅពីជើងដែលបានដាំរួចហើយនោះបានទេ គឺជាព្រះយេស៊ូគ្រិស្ត»*។ *«ដ្បិតគ្មាននរណាអាចចាក់គ្រឹះមួយផ្សេងទៀត ក្រៅពីគ្រឹះដែលបានចាក់រួចមកហើយនោះទេ ពោលគឺព្រះយេស៊ូគ្រិស្ត»*។

ក្រុមជំនុំ គឺជារូបកាយនៃអ្នកជឿដែលបានទទួលការជ្រមុជទឹក ហើយដែលជួបគ្នាក្នុងគោលបំណងដើម្បី៖

១. ថ្វាយបង្គំ: អនុវត្តនូវការ២យ៉ាងដែលព្រះយេស៊ូបានធ្វើ គឺជាពិធីលៀងព្រះអម្ចាស់ និងពិធីជ្រមុជទឹក
២. ការផ្សាយដំណឹងល្អ
៣. បង្កើតសិស្ស
៤. ព័ន្ធកិច្ចសម្រាប់សេចក្តីត្រូវរបស់មនុស្ស
៥. ការប្រកបស្និទស្នាល

## ហេតុអ្វីបានជាលោកអ្នកត្រូវការក្លាយជារបស់ផងក្រុមជំនុំ?

១. ដើម្បីសរសើរដំកើងព្រះជាមួយនឹងលោកអ្នកក្នុងព្រះគ្រិស្តដទៃទៀត។
២. ដើម្បីរៀនព្រះបន្ទូលរបស់ព្រះ។
៣. ដើម្បីឱ្យមានការប្រកបស្និទ្ធស្នាលជាមួយនឹងអ្នកជឿផ្សេងដទៃទៀត (ក្រុមជំនុំជាក្រុមគ្រួសាររបស់លោកអ្នកខាងឯសាច់ឈាម)
៤. ដើម្បីបម្រើអ្នកដទៃ។
៥. ដើម្បីចែកចាយជាមួយនឹងអ្នកដទៃដែលមិនទាន់បានទទួលជឿព្រះយេស៊ូគ្រិស្តនៅឡើយ។

# ៦. ការធ្វើបន្ទាល់

## សេចក្តីពិតទី៦

នៅ ក្នុង ម៉ាថាយ ២៨:១៩ ព្រះយេស៊ូ មាន បន្ទូល ថា « *ចេញ ទៅ និងបង្កើតសិស្ស* »។ នេះមានន័យថា អ្នកដើរតាមព្រះយេស៊ូទាំងអស់គួរតែចែកចាយជាមួយនឹងអ្នកដែលបាត់បង់អំពីអ្វីដែលបានកើតឡើងនៅក្នុងជីវិតរបស់គេ។ ទីបន្ទាល់នេះគួរតែចាប់ផ្តើមជាមួយនឹងក្រុមគ្រួសាររបស់គេផ្ទាល់។

លោកអ្នកគួរតែពន្យល់អំពីជីវិតរបស់លោកអ្នកនៅមុនពេលលោកអ្នកមិនទាន់ទទួលជឿព្រះគ្រិស្តជាព្រះសង្គ្រោះរបស់លោកអ្នកនៅឡើយ។ ពន្យល់ប្រាប់ពីរបៀបដែលលោកអ្នកដឹងថា លោកអ្នកត្រូវការព្រះយេស៊ូពន្យល់ប្រាប់ពីរបៀប និងនៅពេលណា លោកអ្នកបានទទួលជឿព្រះយេស៊ូ ហើយតើជីវិតរបស់លោកអ្នកមានសភាពយ៉ាងណា ឥឡូវនេះការដែលលោកអ្នកបានទទួលជឿព្រះយេស៊ូហើយ។ ក្រោយពីធ្វើការទាំងនេះហើយ ចូរសួរមនុស្សម្នាក់នៅទីនោះ ប្រសិនជាពួកគេចង់ទទួលជឿព្រះគ្រិស្ត និងមានការធានាអះអាងសម្រាប់ជីវិតដ៏នៅអស់កល្បជានិច្ចផងដែរ។

ប្រសិនជាគេនិយាយថា «*បាទ!*» ចូរបង្ហាញនូវខដូចខាងក្រោម និងពន្យល់នូវខនីមួយៗដូចគំរូខាងក្រោម៖

១- ១ យ៉ូហាន ៥:១៣: លោកអ្នកមានការធានាអះអាងចំពោះជីវិតដ៏នៅអស់កល្ប។ ជីវិតអស់កល្ប គឺព្រះយេស៊ូគង់នៅក្នុងចិត្តរបស់លោកអ្នក(យ៉ូហាន ១៧:៣) ជីវិតអស់កល្បជាលទ្ធផលធ្វើឱ្យមានសន្តិភាព ឥឡូវនេះ (យ៉ូហាន១០:១០ និង យ៉ូហាន ១០:១៧ ) និង ក្រោយ ពេល ដែល លោកអ្នក ស្លាប់ ទៅ លោកអ្នក នឹងប្រាកដជាបានទៅឯស្ថានសួគ៌ជាពិត (យ៉ូហាន១៤:១-៣)។

២-រ៉ូម ៣:២៣: បញ្ហាចម្បងបំផុតរបស់មនុស្ស គឺអំពើបាប។ យើងទាំងអស់គ្នាជាមនុស្សមានបាប ដោយសារតែអំពើបាបយើងមានរនាំងដ៏ធំដែលញែកយើងចេញពីព្រះជាម្ចាស់។

៣-រ៉ូម ៦:២៣: «ឈ្នួលនៃអំពើគឺសេចក្តីស្លាប់» នេះមានន័យថា លទ្ធផលចុងក្រោយនៃអំពើបាបរបស់យើងគឺសេចក្តីស្លាប់។ សេចក្តីស្លាប់ គឺជាការបែកចេញពីព្រះ នេះមានន័យថា ជីវិតរបស់យើងឥឡូវនឹងរស់នៅដោយគ្មានសន្តិភាព អំណរ

និងការប្រាកដនៃជីវិតអស់កល្ប។ វានឹងជាជីវិតប្រកបដោយការអន្ទះអន្ទែង ខ្វះខាត ភ័យខ្លាចដោយមានការខុសឆ្គងសតិសម្បជញ្ញៈរបស់ខ្លួនឯង។ វានឹងជាជីវិតដែលបែកចេញពីស្ថានសួគ៌ និងពីព្រះវត្តមានរបស់ព្រះដ៏នៅអស់កល្បជានិច្ច។

៤-រ៉ូម ៥:៨: ព្រះគ្រិស្តសោយទិវង្គតសម្រាប់អំពើបាបរបស់យើង។ ព្រះគ្រិស្តចំណាយសម្រាប់ថ្លៃលោះបាបរបស់យើង និងដោយសារសេចក្ដីស្លាប់របស់លោកអ្នកព្រះអង្គបានសោយទិវង្គតជំនួសកន្លែងរបស់លោកអ្នកផងដែរ។

៥-រ៉ូម ៨:៩-១០ និង១០:៩-១០: ទទួលជឿព្រះគ្រិស្ត លោកអ្នកត្រូវទទួលព្រះអង្គជាព្រះអម្ចាស់ និងព្រះសង្គ្រោះរបស់លោកអ្នក។ មានន័យថា លោកអ្នកគួរតែអនុញ្ញាតព្រះគ្រិស្តដឹកនាំជីវិតរបស់លោកអ្នក។ វាមានន័យផងដែរពីការទទួលព្រះគ្រិស្តមានន័យថា ជឿលើព្រះអង្គ។ ជឿមានន័យថា ឈប់ជឿលើរបស់ទាំងអស់ និងដាក់នូវសេចក្ដីជំនឿរបស់បងប្អូននៅក្នុងព្រះយេស៊ូគ្រិស្ត។

៦-រ៉ូម ១០:១៣: សួរមនុស្សម្នាក់នោះ ប្រសិនជាគាត់ចង់ប្រគល់ជីវិតរបស់គាត់ទៅដល់ព្រះគ្រិស្ត ប្រសិនជាគាត់និយាយថា «បាទ!» សុំគាត់ដើម្បីអធិស្ឋាន និងទូលសូមដល់ព្រះ នោះ ព្រះអង្គនឹងយាងមកគង់នៅក្នុងជីវិតរបស់គាត់នៅពេលនោះ *«ហើយគ្រប់គ្នាគឺអស់អ្នកណាដែលអំពាវនាវដល់ព្រះនាមព្រះអម្ចាស់នោះនឹងបានសង្គ្រោះ ដ្បិតអ្នកណាអង្វររកព្រះនាមព្រះអម្ចាស់ អ្នកនោះនឹងបានទទួលការសង្គ្រោះ»* (រ៉ូម១០:១៣)។

# ផ្នែកទី៥

## ការសិក្សាគម្ពីរដំណឹងល្អយ៉ូហាន

## Study the Gospel of John

## គម្រោងការដ៏អស្ចារ្យរបស់ព្រះជាម្ចាស់សម្រាប់លោកអ្នក

# មេរៀនទី១

## គម្រោងការដ៏អស្ចារ្យសម្រាប់ជីវិតរបស់អ្នក

### ការសិក្សាគម្ពីរដំណឹងល្អយ៉ូហាន

លោកអ្នកនៅលើផែនដីនេះមានគោលបំណងៈ ដើម្បីឱ្យស្គាល់ស្រឡាញ់និងថ្វាយ សិរី រុង រឿង ដល់ ព្រះ ។ លោកអ្នក អាច នឹង ចូល មក ឯ ព្រះ ដោយ ខ្លួន របស់ លោកអ្នក ផ្ទាល់ នៅ ពេល លោកអ្នក ជួប និង ស្គាល់ ព្រះ រាជ បុត្រា របស់ ព្រះជាម្ចាស់ ព្រះយេស៊ូគ្រិស្តព្រះអង្គសង្គ្រោះ។ ព្រះគម្ពីរបានបើកបង្ហាញនូវព្រះអំណោយទានដ៏អស្ចារ្យទាំងអស់ដែលព្រះអង្គប្រទានឱ្យអស់អ្នកស្គាល់នឹងដើរតាមព្រះយេស៊ូគ្រិស្ត។

ក្នុងចំណោមអំណោយ និងប្រយោជន៍ដ៏អស្ចារ្យខ្លះៗទាំងនេះត្រូវរកបាននៅខាង ក្រោម ការ សិក្សា នេះ ត្រូវ បាន ត ភ្ជាប់ គ្នា ទៅ នឹង ដំណឹង ល្អ យ៉ូហាន ។ អនុញ្ញាតឱ្យព្រះជាម្ចាស់មានព្រះបន្ទូលទៅកាន់លោកអ្នកទៅតាមរយៈព្រះគម្ពីរចុះ។ សូមគិតអំពីអ្វីដែលខនីមួយៗ និយាយឥឡូវ ចូរបើកព្រះគម្ពីរយ៉ូហានជំពូក១០ហើយអាននូវខទី១០។

១. ហេតុអ្វីបានជាព្រះយេស៊ូ (អ្នកគង្វាលដ៏ល្អ) ព្រះអង្គយាងមក? យ៉ូហាន១០:១០

_______________________________________________

២. តើអ្នកគិតយ៉ាងដូចម្តេចចំពោះព្រះយេស៊ូមានបន្ទូលថា «ជីវិត__________អស់កល្ប»?_______________________________________________

_______________________________________________

៣. តើជីវិតប្រភេទណាទៅដែលព្រះយេស៊ូប្រទានឱ្យអស់អ្នកដែលជឿព្រះអង្គជាពិតនោះ? ១០:២៨_

_______________________________________________

៤. តើព្រះវរបិតាធ្វើយ៉ាងដូចម្តេចនៅពេលយើងអធិស្ឋានដោយនូវព្រះនាមព្រះយេស៊ូគ្រិស្ត? ១៦:២៣

៥. តើអ្នកគិតថាវាមានន័យយ៉ាងដូចម្ដេច ក្នុងការទូលសូមដោយនូវព្រះនាមព្រះយេស៊ូគ្រិស្ត______________________________________________

______________________________________________

៦. ហេតុអ្វីបានជាព្រះយេស៊ូចង់ឆ្លើយនូវសំណូមអធិស្ឋានរបស់យើង? ១:២៤___

______________________________________________

៧. តើយើងក្លាយទៅជាយ៉ាងណា «មានសេរីភាព» នៅក្នុងជីវិតរបស់យើង?
៨:៣១, ៣២:______________________________________

______________________________________________

៨. តើអ្នកគិតយ៉ាងដូចម្ដេចចំពោះព្រះយេស៊ូមានបន្ទូលពីពាក្យថា «សេចក្ដីពិត» ដែលធ្វើឱ្យយើងមានសេរីភាព? ១៧:១៧________________________

______________________________________________

៩. តើម្នាក់ៗនឹងទៅដោយរបៀបណាអំពីការបន្តនៅក្នុងព្រះបន្ទូលរបស់ព្រះយេស៊ូ? ៨:៣១:__________________________________________

______________________________________________

១០. នៅក្នុងយ៉ូហាន១៤:១ព្រះយេស៊ូមានបន្ទូលមិនអនុញ្ញាតឱ្យ__________
______________________________របស់យើង ព្រះអង្គចង់ឱ្យអស់អ្នកដែលជឿដល់ព្រះជាម្ចាស់នឹងជឿដល់______________________ផងដែរ។

១១. តើមានអ្វីនៅក្នុងស្ថានសួគ៌នៅក្នុងដំណាក់ដ៏ធំមហិមារបស់ព្រះ? ១៤:២___

______________________________________________

១២. តើព្រះយេស៊ូយាងទៅធ្វើអ្វីនៅពេលព្រះអង្គបានលើកឡើងទៅស្ថានសួគ៌វិញ?

១៤:៣:________________________

**១៣.** តើព្រះយេស៊ូនឹងធ្វើអ្វីមុន ក្រោយពេលដែល ព្រះអង្គរៀបកន្លែងសម្រាប់ប្រជារាស្ត្ររបស់ព្រះអង្គនៅឯស្ថានសួគ៌រួចរាល់ហើយ? ១៤:________________________

**១៤.** តើព្រះយេស៊ូមានបន្ទូលសន្យាថាយ៉ាងដូចម្តេចបន្ទាប់មក?

________________________

**១៥.** តើអ្វីដែលមិនអាចកើតឡើងក្នុងការទិញនូវអ្វីដែលព្រះយេស៊ូប្រទានឱ្យយើងដោយមិនបាច់បង់ថ្លៃ? ១៤:២៦:________________________

**១៦.** ប្រសិនជាយើងស្រឡាញ់ព្រះយេស៊ូ តើព្រះហឫទ័យរបស់ព្រះចំពោះយើងមានអ្វីខ្លះ? ១៦:២៧:________________________

សូមអ្នកអោនក្បាលរបស់អ្នកដោយស្ងាត់ស្ងៀមក្នុងការអធិស្ឋានឥឡូវនេះ។ អរព្រះគុណដល់ព្រះនូវការដែលព្រះអង្គស្រឡាញ់អ្នក។

**ព្រះគម្ពីរប្រាប់យើងអំពីសេចក្តីស្លាប់២យ៉ាង**

ដំបូងគឺនៅពេលរូបកាយរបស់យើងស្លាប់ការស្លាប់ទីពីរ គឺការស្លាប់ខាងឯព្រលឹងវិញ្ញាណការស្លាប់ដោយមិនទទួលយកព្រះយេស៊ូមកគង់នៅក្នុងជីវិតរបស់យើង។ សេចក្តីស្លាប់នេះគឺជាការបែកចេញពីព្រះជាម្ចាស់នៅក្នុងបឹងភ្លើងដែលហៅថា «ស្ថាននរក»។

**១៧.** ប៉ុន្តែ តើព្រះយេស៊ូសន្យាថាយ៉ាងដូចម្តេចដល់អស់អ្នកដែលរស់នៅដោយជឿលើព្រះជាម្ចាស់ជាពិត? ១១:២៦:________________________

កត់សំគាល់ពីពាក្យដ៏សំខាន់ដែល *ម៉ាថា* ប្រើក្នុងការឆ្លើយតបទៅកាន់ព្រះយេស៊ូ នៅក្នុងយ៉ូហាន១១:២៧ ឃ្លារបស់នាងមាននៅក្នុងនោះ តើនាងជឿលើព្រះយេស៊ូ និងអំណាចឈ្នះលើសេចក្តីស្លាប់របស់ព្រះអង្គយ៉ាងដូចម្តេច? *«ព្រះពរព្រះអម្ចាស់ខ្ញុំម្ចាស់ជឿហើយថា ទ្រង់ជាព្រះគ្រិស្ត គឺជាព្រះរាជបុត្រានៃព្រះដែលត្រូវយាងមកក្នុងលោកិយមែន»* ។

១៨. នៅពេលយើងយល់ពីព្រះបន្ទូលរបស់ព្រះយេស៊ូ តើនឹងមានអ្វីកើតឡើងនៅក្នុងយើង?

១៩. ដូចដែលព្រះយេស៊ូបំពេញអស់អ្នកដែលជឿយើងទទួលបាននូវ__________ __________________________________________ដែលធ្វើឱ្យយើងមានអំណាចរស់នៅក្នុងព្រះគ្រិស្ត។ ១:១៦ ព្រះគុណជាអំណោយទានរបស់ព្រះដែលយើងមិនអាចនឹងខិតខំធ្វើល្អឬក៏ទិញបានឡើយ។ វាទទួលនូវព្រះវិញ្ញាណដ៏ថ្លៃវិសេសរបស់ព្រះទៅតាមព្រះយេស៊ូនៅក្នុងការផ្លាស់ប្តូរនូវអំពើបាបដ៏ខ្មៅកខ្វក់របស់យើង។ យើងត្រូវបានសង្គ្រោះឱ្យរួចពីអំពើបាបរបស់យើងដោយសារព្រះគុណ មិនមែនទៅតាមការដែលយើងខំប្រឹងនោះឡើយ។ *« ដ្បិតគឺដោយព្រះគុណដែលអ្នករាល់គ្នាបានសង្គ្រោះដោយសារសេចក្តីជំនឿ ហើយដោយសេចក្តីនោះក៏មិនមែនកើតពីអ្នករាល់គ្នាដែរ គឺជាអំណោយទានរបស់ព្រះវិញ» «ព្រះអង្គសង្គ្រោះបងប្អូនមកពីព្រះអង្គ មានព្រះហឫទ័យប្រណីសន្តោស ដោយសារលោកអ្នកមានជំនឿ ការសង្គ្រោះមិនមែនមកពីលោកអ្នកទេ គឺជាព្រះអំណោយទានរបស់ព្រះជាម្ចាស់វិញ» (អេភេសូរ ២:៨-៩)* ។

២០. យ៉ូហានឱ្យរូបភាពនៃព្រះយេស៊ូមកយើងជាកូនចៀមនៃព្រះ។ តើព្រះយេស៊ូបានធ្វើចំពោះអំពើបាបរបស់យើងនៅលើឈើឆ្កាង?

______________________________________________

______________________________________________

២១. មានពាក្យតែមួយគត់នៅក្នុងយ៉ូហាន១:១២ ដែលប្រាប់ថា តើអត្ថន័យនៃពាក្យថា «ជឿ» លើព្រះយេស៊ូមានន័យយ៉ាងដូចម្តេចទៅ។ ជឿលើព្រះយេស៊ូមានន័យថា ព្រះអង្គទុកនៅក្នុង__________របស់យើងដូចព្រះអម្ចាស់យេស៊ូគ្រិស្ត។

នៅក្នុងការសិក្សានេះ បានប្រាប់លោកអ្នកពីគោលបំណងនៃសេចក្ដីស្រឡាញ់របស់ព្រះចំពោះជីវិតរបស់លោកអ្នក និងផលប្រយោជន៍ដ៏អស្ចារ្យខ្លះៗនៃការទទួលស្គាល់ ព្រះអង្គរួចមកហើយ ។ អស់អ្នកដែលដាក់សេចក្ដីជំនឿរបស់គេនៅក្នុងព្រះយេស៊ូគ្រិស្ដនឹងត្រូវបានឱ្យនូវជីវិតដ៏អស់កល្បជានិច្ច។ ឆ្លើយតបទៅនឹងសេចក្ដីអធិស្ឋានសើរីភាពផ្ទះនៅឯស្ថានសួគ៌ អំណារអរ មេត្រីភាព និងព្រះគុណ។ ព្រះជាម្ចាស់នឹងលើកលែងទោស និងយកនូវអំពើបាបរបស់ពួកគេចេញផងដែរ។

នៅពេលអ្នកលន់តួនូវអំពើបាបរបស់អ្នក ហើយទទួលព្រះយេស៊ូគ្រិស្ដនឹងយាងចូលទៅក្នុងចិត្តរបស់អ្នកនោះជាព្រះអម្ចាស់ជារៀងរហូត។ លន់តួគឺជាការបែរចេញពីអំពើរបស់យើងដើម្បីដើរតាមព្រះយេស៊ូ។ ព្រះអង្គសោយទិវង្គតសម្រាប់អំពើបាបទាំងអស់របស់អ្នក ហើយព្រះអង្គរស់ពីការសោយទិវង្គតឡើងវិញ។ នៅក្នុងមេរៀន បន្ទាប់ លោកអ្នក នឹង រៀន ច្រើន ពី អំណោយ ទាន មួយ នៅ ក្នុង ចំណោម អំណោយទានរបស់ព្រះជាច្រើន គឺជីវិតអស់កល្បជានិច្ច។

## មេរៀនទី២

# អំណាចនៃការរស់នៅដ៏អស់កល្បជានិច្ច

### ការសិក្សាព្រះគម្ពីរដំណឹងល្អយ៉ូហាន

មនុស្សជាច្រើនគិតថា ជីវិតដ៏នៅអស់កល្ប គឺជាអ្វីដែលយើងបានទទួល និងមានបទពិសោធក្រោយពេលយើងស្លាប់។ អ្នកផ្សេងទៀតគិតថា ជីវិតដ៏នៅអស់កល្បគឺជាផលនៃការធ្វើល្អដើម្បីយកនូវរាល់អំពើបាបទាំងអស់ដែលយើងបានប្រព្រឹត្ត។ នេះមិនពិតនោះទេ។ មនុស្សខ្លះដឹងនូវអ្វីដែលព្រះយេស៊ូមានបន្ទូលមក ហើយម្តងទៀតយើងអាចដឹងយ៉ាងច្បាស់លាស់ថា ឥឡូវនេះ យើងមានជីវិតដ៏នៅអស់កល្បជានិច្ច។

ចូរយើងក្រឡេកមើលនូវដំណឹងល្អយ៉ូហាននៅក្នុងព្រះគម្ពីរ។ សូមបើកនូវជំពូក១៧:៣ សូមអានខនេះ ហើយឆ្លើយសំនួរដោយខ្លួនឯងសរសេរចម្លើយដាក់នៅក្នុងប្រឡោះទំនេរ។

១. តើជីវិតដ៏អស់កល្បជាអ្វី? ១៧:៣:____________________

____________________

២. តើយើងគិតយ៉ាងដូចម្តេចថាយើងអាចស្គាល់ព្រះ និងព្រះយេស៊ូគ្រិស្ត? ៧:១៧:____________________

____________________

ជីវិតដ៏អស់កល្បគឺមិនមែនគ្រាន់តែជាសេចក្តីសន្យាអំពីថ្ងៃអនាគតកាលប៉ុណ្ណោះទេ។ ជីវិតដ៏នៅអស់កល្ប គឺស្ថិតនៅក្នុងបុរសម្នាក់ឈ្មោះព្រះយេស៊ូគ្រិស្ត។ មានព្រះយេស៊ូជាព្រះអម្ចាស់ និងជាព្រះសង្គ្រោះដោយផ្ទាល់ខ្លួនរបស់អ្នក គឺមានជីវិតដ៏នៅអស់កល្ប។

៣. តើមានផ្លូវអ្វីដើម្បីស្វែងរកព្រះយេស៊ូគ្រិស្ត? ៥:៣៩:____________________

____________________

៤. នរណាជាអ្នកមានពាក្យដ៏នៅអស់កល្បជានិច្ចសម្រាប់យើងទាំងអស់គ្នា? ៦:៦៧-៦៩:________________________________________

________________________________________________

៥. ប្រសិនជាអ្នកគ្មានជីវិតដ៏នៅអស់កល្បជានិច្ច តើនឹងមានអ្វីកើតឡើង? ៣:១៥

________________________________________________

៦. តើកូនចៀមរបស់ព្រះយេស៊ូគ្រិស្តបានជីវិតដ៏នៅអស់កល្បជានិច្ចដោយរបៀបណា?____________________________________________

៧. តើនឹងមានអ្វីកើតឡើងនៅពេលយើងជ្រើសរើសយកនូវគំនិតរបស់នៅលើបំណងព្រះហឫទ័យរបស់ព្រះជាម្ចាស់? ១២:២៥:____________________

________________________________________________

តើយើងរក្សាជីវិតដ៏នៅអស់កល្បជានិច្ចបានដោយរបៀបណា?

________________________________________________

៨. ព្រះយេស៊ូមានបន្ទូលថា «បើគ្មានខ្ញុំ______________________» ១៥:៥:

________________________________________________

៩. តើនរណាដែលមានអំណាចគ្រប់ទាំងអស់ និងអាចឱ្យនូវជីវិតដ៏នៅអស់កល្ប?

________________________________________________

សូមអានគម្ពីរយ៉ូហាន ៣:១៦ ពីរដង ហើយបន្ទាប់មកឆ្លើយនូវសំនួរខាងក្រោមៈ

១០. តើអ្នកណាស្រឡាញ់ប្រជាជននៅលើពិភពលោក?__________________

១១. តើព្រះជាម្ចាស់ធ្វើយ៉ាងដូចម្តេច ចំពោះសេចក្តីស្រឡាញ់របស់ព្រះអង្គសម្រាប់យើង?____________________________________________

១២. តើនរណាជា «ព្រះរាជបុត្រាតែមួយ» របស់ព្រះជាម្ចាស់?______________

១៣. តើនរណានឹងអាចមានជីវិតដ៏នៅអស់កល្បជានិច្ច? ______________________

១៤. អស់អ្នកដែលមិនជឿលើព្រះរាជបុត្រាតែមួយព្រះយេស៊ូគ្រិស្តនឹងត្រូវ ________

______________________________________________________

១៥. តើមនុស្សប៉ុន្មាននាក់នឹងអាចមានជីវិតដ៏នៅអស់កល្បជានិច្ច?

______________________________________________________

១៦. តើអ្នកគិតថារយៈពេលប៉ុន្មានឆ្នាំសម្រាប់ជីវិតដ៏នៅអស់ជានិច្ចនោះ?

______________________________________________________

១៧. ហេតុអ្វីបានជាព្រះទ្រង់ប្រទានដល់យើងនូវជីវិតដ៏នៅអស់កល្បជានិច្ច?

______________________________________________________

១៨. តើអាចគេចផុតពីការស្លាប់ដោយរបៀបណា?

១៩. នៅក្នុង យ៉ូហាន ៥:២៤ ព្រះយេស៊ូ មាន បន្ទូល នូវ ការ មួយ មាន សារៈ សំខាន់ បំផុត សូមឱ្យបំពេញនៅក្នុងចន្លោះនោះ។ ដើម្បីឱ្យមានជីវិតដ៏នៅអស់កល្បជានិច្ចពីព្រះយេស៊ូ មនុស្សម្នាក់នោះដំបូងត្រូវ ______________________ ព្រះបន្ទូលរបស់ព្រះអង្គនិងទៅលើព្រះអង្គ។

២០. បន្ទាប់មកព្រះយេស៊ូមានព្រះបន្ទូលសន្យានូវការសំខាន់បីៈ

អ្នកនោះមាន ____________________________________________

អ្នកមិនដែលត្រូវ _________________________________________

អ្នកបាន ______________________________________________

មនុស្សម្នាក់អាចដឹងនៅពេលគេបានកន្លងហួសពីស្លាប់ទៅដល់ជីវិតដូចដែលមនុស្សម្នាក់ដឹងពីថ្ងៃដែលគេនឹងរៀបការឬក៏ថ្ងៃខួបកំណើតរបស់គេដែរ។តើអ្នកបានកន្លងហួសពីស្លាប់ទៅដល់ជីវិតហើយឬនៅ? អ្នកអាចដឹង។

២១. ព្រះយេស៊ូគ្រិស្តមានបន្ទូលពីជីវិតដ៏នៅអស់កល្បដូចជា ______________

__________________________________________________ ៤:១៣-១៤។

២២. បន្ទាប់មក តើមនុស្សអាចទទួលយកនូវជីវិតដ៏នៅអស់កល្បជានិច្ចដោយរបៀបណា? ខ.១៤:________________

២៣. តើមានន័យយ៉ាងដូចម្ដេចទៅចំពោះពាក្យថា «ផឹក» នៅក្នុងយ៉ូហាន៤:១៤?

**គូសរង្វង់នូវចម្លើយដ៏ត្រឹមត្រូវ:**

ក- ផឹកទឹកពិតប្រាកដ
ខ- ជឿដល់ព្រះយេស៊ូ
គ- ផឹកអណ្ដូង
ឃ-ទទួលការជ្រមុជទឹក

២៤. ព្រះយេស៊ូ ពាក្យនៃរូបភាពមួយទៀតដើម្បីមានបន្ទូលពីរូបអង្គទ្រង់នៅក្នុងយ៉ូហាន៦:៤៧, ៤៨, និង៥១ ព្រះយេស៊ូគឺ________________

________________

សូមឱ្យលើកយកនូវការ២យ៉ាង ដែលមកពីគំនិតនៅពេលអ្នកឃើញប៉ះញ៉ាំនំប៉័ង________________

២៥. តើការនីមួយៗទាំងពីរយ៉ាងនេះទាក់ទងទៅនឹងព្រះយេស៊ូដោយរបៀបណា?

________________

២៦. ប្រសិនជាយើងជឿលើព្រះគ្រិស្តដ៏មានព្រះជន្មរស់ តើយើងនឹងមានអ្វី? ៦:៤៧

________________

អ្នកបានរៀនដោយដឹងថា ជីវិតដ៏នៅអស់កល្បជានិច្ច និងជីវិតដ៏នៅស្ថិតស្ថេរមានន័យដូចគ្នា។ ការទទួលបាននូវជីវិតដ៏នៅអស់កល្បជានិច្ច ជាលទ្ធផលមកពីការស្គាល់ព្រះយេស៊ូគ្រិស្តដោយខ្លួនយើងផ្ទាល់។ ព្រះអង្គជាជីវិតអស់កល្ប។ អ្នកបានរកឃើញថា ជីវិតអស់កល្ប គឺនៅជារៀងរហូត គ្មាននរណាម្នាក់នឹងស្លាប់ឡើយប្រសិនជាគេមានជីវិតអស់កល្បជានិច្ច។ ព្រះយេស៊ូជាទឹករស់ និងជានំប៉័ងជីវិតរបស់លោកអ្នកទាំងអស់គ្នា។

នៅក្នុងការសិក្សាបន្ទាប់ លោកអ្នកនឹងរៀនពីការគេចឱ្យរួចពីស្លាប់ចំពោះជំងឺដ៏កាចសាហាវរបស់លោកិយ។

# មេរៀនទី៣

## សោកនាដកម្មនៃអំពើបាប

### ការសិក្សាព្រះគម្ពីរដំណឹងល្អយ៉ូហាន

មនុស្សម្នាក់ៗ គឺមានជំងឺដែលធ្វើឱ្យស្លាប់ប្រចាំកាយរៀងៗខ្លួន គឺអំពើបាបដែលវាមានឥទ្ធិពលដល់អស់អ្នកដែលលោកអ្នកស្រឡាញ់ហើយវាឆ្លងពីឪពុកម្ដាយទៅកូន អ្នកខ្លះគិតថា គេអាចគេចផុតពីវា។ តែទោះយ៉ាងណាក៏ដោយព្រះជាម្ចាស់នឹងជំនុំជម្រះអំពើបាបរបស់បងប្អូន។ ជាការអរព្រះគុណណាស់ដែលព្រះជាម្ចាស់បានប្រទាននូវថ្នាំសម្រាប់អំពើបាប។

ចូរឱ្យយើងក្រឡេកមើលម្តងទៀតនៅព្រះគម្ពីរដំណឹងល្អយ៉ូហាន ហើយនឹងខគន្លឹះខ្លះពីកន្លែងផ្សេងទៀតនៅក្នុងព្រះគម្ពីរ។ សូមចាំថា ត្រូវអានខមួយៗដោយប្រុងប្រយ័ត្នមុនពេលបំពេញចម្លើយទៅក្នុងចន្លោះ។

១. លោកយ៉ូហានបាទីស្ទហៅព្រះយេស៊ូថា «កូនចៀមនៃព្រះ» តើព្រះយេស៊ូធ្វើអ្វីជាមួយនឹងអំពើបាបរបស់យើង? យ៉ូហាន១:២៩:____________________

____________________________________________

២. តើព្រះយេស៊ូជានរណា? តើព្រះយេស៊ូអះអាងថាព្រះអង្គជាអ្វីនៅពេលព្រះអង្គហៅព្រះជាម្ចាស់ជាព្រះវរបិតា? ៥:១៧-១៨:____________________

____________________________________________

៣. ព្រះយេស៊ូអះអាងគឺពិត! តើអ្នកដឹកនាំសាសនាបញ្ចេញសកម្មភាពយ៉ាងដូចម្តេចនៅពេលព្រះយេស៊ូហៅព្រះជាម្ចាស់ជាព្រះវរបិតា? ១០:៣១-៣៣__________

____________________________________________

ព្រះយេស៊ូអត់ទោសអំពើបាប។ ទទួលការថ្វាយបង្គំថាព្រះអង្គដូចជាព្រះគ្មាន

អំពើបាប ហើយព្រះអង្គមានអំណាច ព្រះអង្គក៏បានប្រកាសថាព្រះអង្គដូចជាព្រះ (ព្រះអង្គជាព្រះផង និងជាមនុស្សផង)។

៤. តើនរណានឹងជំនុំជំរះមនុស្សមានបាបនៅថ្ងៃចុងបំផុត? ៥:២២, ២៦-២៧___

___

៥. តើ ឱសថ អ្វី សម្រាប់ ព្យាបាល អំពើ បាប ដែល ព្រះយេស៊ូ បាន ស្នើ ដល់ អ្នក កាន់ សាសនា? ៣:៣___

___

ការកើតខាងឯសាច់ឈាមវាមិនគ្រប់គ្រាន់នោះទេ។ ដោយព្រោះតែអំពើបាបអ្នកទាំងអស់គ្នាត្រូវមានការកើតជាថ្មីនៅក្នុងខ្លួន។

៦. យើងត្រូវការកើតជាថ្មី ពីព្រោះបើគ្មានព្រះគ្រិស្តទេ យើងជាទាសករនៃ___ ___៨:៣៤។

៧. តើនរណាជាឪពុកនៃអស់អ្នកដែលមានចំណង់តណ្ហា និងអំពើបាប?
៨:៤៤___

យើងមានឪពុកនៅលើផែនដី គឺអារក្សសាតាំងដែលចង់ឱ្យយើងទៅស្ថាននរកជាមួយនឹងវាអស់កល្បជានិច្ច យើងត្រូវការឪពុកនៅឯស្ថានសួគ៌ដែលពោរពេញដោយសេចក្ដីស្រលាញ់។

៨. ដោយព្រោះយើងមិនដាក់ជីវិតយើងទាំងស្រុងទៅលើព្រះយេស៊ូគ្រិស្តយើងឈរ___ ___។

៩. អានយ៉ូហាន ៨:១-១១ តើព្រះយេស៊ូមានបន្ទូលទៅកាន់អ្នកដឹកនាំសាសនាមានអំនួតថាយ៉ាងម្ដេច? ៨:៧:___

___

ព្រះយេស៊ូអត់ទោសដល់ស្ត្រីមានអំពើបាប។ ព្រះអង្គទតឃើញនូវការលន់តួដ៏ពិតនៅក្នុងចិត្តរបស់នាង។ នេះជារបៀបដែលព្រះអង្គមានទំនាក់ទំនងជាមួយនឹងអស់

អ្នកដែលស្មោះត្រង់ទៅនឹងអំពើបាបដែលគេមានហើយចង់បានកើតជាថ្មី។ «ពីព្រោះគ្រប់គ្នាបានធ្វើបាប ហើយខ្វះមិនដល់សិរីល្អនៃព្រះ» (រ៉ូម៣:២៣)។

១០. ដោយយោងទៅតាមខនេះ តើមាននមនុស្សប៉ុន្មាននាក់បានធ្វើបាប?

---

១១. តើអំពើបាបជាអ្វី? អំពើបាបគឺ (ជ្រើសរើសចម្លើយដែលត្រឹមត្រូវទាំងអស់)

ក- ការមិនគោរពតាមក្រិត្យវិន័យរបស់ព្រះ
ខ- អ្វីទាំងអស់ដែលមិនសុចរិត
គ- ខ្វះមិនដល់សិរីល្អនៃព្រះ
ឃ-ប្រឆាំងនឹងព្រះ
ង- មិនជឿ ធ្វើឱ្យព្រះក្លាយជាអ្នកកុហស
ច- រស់ទៅតាមគំនិតខ្លួនឯង ធ្វើនូវអ្វីដែលខ្លួនចង់ធ្វើប្រឆាំងនឹងបំណងព្រះហឫទ័យរបស់ព្រះ។

អំពើ បាប ជា ការ ប្រឆាំង នឹង បំណង ព្រះហឫទ័យ របស់ ព្រះជាម្ចាស់ ដោយអាកប្បកិរិយាខុសឆ្គងមួយ។ ចម្លើយទាំងអស់នៅក្នុងសំនួរទី១១គឺជានិយមន័យនៃអំពើបាបនៅក្នុងព្រះគម្ពីរ។ អស់អ្នកដែលកាន់សាសនានឹងទៅស្ថាននរក អស់អ្នកដែលធ្វើល្អក៏នឹងទៅស្ថាននរក អស់អ្នកដែលធ្វើអាក្រក់ក៏នឹងទៅស្ថាននរក។ មានតែអស់អ្នកដែលត្រូវបានអត់ទោសតែប៉ុណ្ណោះទេ ដែលអាចទៅស្ថានសួគ៌បាន។ ទទួលការអត់ទោសបាបទាក់ទងទៅនឹងការប្រែចិត្ត ត្រលប់មកវិញចេញពីអំពើបាបដោយក្នុងការប្រែចិត្ត លន់តួ ហើយចុះចូលជាមួយនឹងព្រះយេស៊ូគ្រិស្តជាព្រះអម្ចាស់។

*«ដ្បិតលទ្ធផលនៃបាប គឺសេចក្ដីស្លាប់ រីឯព្រះអំណោយទានរបស់ព្រះជាម្ចាស់វិញ គឺជីវិតអស់កល្បជានិច្ចរួមជាមួយព្រះគ្រិស្តយេស៊ូ ជាព្រះអម្ចាស់នៃយើង»។*

*« ដ្បិតឈ្នួលរបស់អំពើបាប នោះជាសេចក្តីស្លាប់ តែអំណោយទាននៃព្រះវិញ គឺជាជីវិតដ៏នៅអស់កល្បជានិច្ចដោយព្រះគ្រិស្តយេស៊ូជាព្រះអម្ចាស់នៃយើងរាល់គ្នា»។*

១២. តើឈ្នួលនៃអំពើបាបដែលចំណាយសម្រាប់យើងទាំងអស់គ្នាគឺជាអ្វី?

---

---

១៣. តើយើងត្រូវធ្វើការដើម្បីទទួលនូវសេចក្តីសង្គ្រោះពីព្រះឬ?

១៤. អញ្ចឹងតើយើងត្រូវទទួលជីវិតដ៏នៅអស់កល្បយ៉ាងមេចទៅ?

*«ព្រះអង្គសង្គ្រោះលោកអ្នក មកពីព្រះអង្គមានព្រះហឫទ័យប្រណីសន្តោស ដោយសារលោកអ្នកមានជំនឿ ។ ការសង្គ្រោះមិនមែនមកពីលោកអ្នកទេ គឺជាព្រះអំណោយទានរបស់ព្រះជាម្ចាស់ ហើយក៏មិនមែនមកពីមនុស្សប្រព្រឹត្តអំពើល្អដែរ ដើម្បីកុំឱ្យនរណាម្នាក់អួតខ្លួន» «ដ្បិតគឺដោយព្រះគុណដែលអ្នករាល់គ្នាបានសង្គ្រោះដោយសារសេចក្តីជំនឿ ហើយដោយសេចក្តីនោះក៏មិនមែនកើតពីអ្នករាល់គ្នារាល់គ្នាដែរគឺជាអំណោយទានរបស់ព្រះវិញក្រែងអ្នកណាអួតខ្លួន»* (អេភេសូរ ២:៨-៩) ឆ្លើយពីខនេះ៖

១៥. តើយើងត្រូវបានសង្គ្រោះឱ្យរួចពីស្ថាននរកដោយរបៀបណា?

១៦. តើយើងទទួលជីវិតដ៏អស់កល្បនេះដោយរបៀបណា?

ព្រះគុណ គឺជាអំណោយទានដូចជាសេចក្តីជំនឿដែរ យើងមិនអាចធ្វើការដើម្បីឱ្យបានព្រះគុណនោះឡើយ។

១៧. តើព្រះយេស៊ូសន្យាចំពោះអស់អ្នកដែលបដិសេធមិនដើរតាមព្រះអង្គជាព្រះអម្ចាស់ និងជាព្រះអង្គសង្គ្រោះដោយរបៀបណា?

១៨. យ៉ូហាន ៨:២៤ ________________________

១៩. តើនរណាអាចនឹងរំដោះឱ្យយើងមានសេរីភាពពីអំណាចនៃអំពើបាបបាន?

៨:៣៦_______________________________________________

២០. តើព្រះយេស៊ូសួរដល់អ្នកដែលស្គាល់ព្រះអង្គនៅផែនដីថាយ៉ាងដូចម្ដេច? ៨:៤៦

_______________________________________________

_______________________________________________

ព្រះយេស៊ូមិនដែលធ្វើបាបទាល់តែសោះ ។ ព្រះអង្គត្រូវសេចក្ដីល្បួងដូចជាលោកអ្នកផងដែរ ។ ព្រះយេស៊ូស្រឡាញ់លោកអ្នកទាំងអស់គ្នា ។ សេចក្ដីស្រឡាញ់របស់ព្រះអង្គបណ្ដាលឱ្យព្រះអង្គយកនូវអំពើរបស់លោកអ្នកមកដាក់លើព្រះអង្គដោយសោយទិវង្គតនៅលើឈើឆ្កាង ។

« *មនុស្សលោកទាំងអស់ត្រូវស្លាប់តែមួយដង រួចត្រូវព្រះជាម្ចាស់វិនិច្ឆ័យទោស* «*ហើយដោយព្រោះបានដំរូវត្រូវឱ្យ មនុស្សទាំងអស់ស្លាប់១ដងរួចសឹមជាប់សេចក្ដីជំនុំជំរះ*» (ហេព្រើរ៩:២៧) ។

២១. តើការសន្យាពីរយ៉ាងអ្វីខ្លះដែលយើងនឹងត្រូវថែរក្សា?

ក):______________________________

ខ):______________________________

អស់អ្នកដែលជ្រើសរើសអំណោយរបស់ព្រះយេស៊ូគ្រិស្តនៃជីវិតអស់កល្បនឹងឈ្នះនូវហេតុការណ៍ដ៏គួរឱ្យរន្ធត់ទាំងពីរយ៉ាងនេះ ។ នៅក្នុងមេរៀនបន្ទាប់អ្នកនឹងរកឃើញពីរបៀបដែលព្រះយេស៊ូគ្រិស្តទទួលយកនូវអំពើបាបរបស់អ្នក និងលទ្ធផលរបស់វាមកដាក់លើរូបអង្គទ្រង់ ។

## មេរៀនទី៤

# សកម្មភាព និង លទ្ធផល

### ការសិក្សាព្រះគម្ពីរដំណឹងល្អយ៉ូហាន

វាមិនអាចកើតឡើងបាននោះទេ បើសិនជាធ្វើបាបហើយគ្មានការដាក់ទោសនោះ អ្នកមិនអាចគេចផុតពីព្រះនេត្ររបស់ព្រះជាម្ចាស់នោះទេ។ «អ្វីៗដែលមនុស្សលោកប្រព្រឹត្ត ព្រះអម្ចាស់ជ្រាបទាំងអស់ ព្រះអង្គទតឃើញកិរិយាមារយាទរបស់គេ *ពីព្រោះអស់ទាំងផ្លូវរបស់មនុស្សសុទ្ធតែច្បាស់នៅចំពោះព្រះនេត្រព្រះយេហូវ៉ា ទ្រង់ក៏ស្ទង់មើលអស់ទាំងផ្លូវច្រករបស់គេដែរ»* (សុភាសិត ៥:២១)។អានខនីមួយៗ សរសេរចម្លើយដោយគំនិតផ្ទាល់របស់លោកអ្នក។

១. តើព្រះវរបិតាដែលគង់នៅស្ថានសួគ៌បានធ្វើអ្វីចំពោះការជំនុំជំរះយើង? ៥:២២

______________________________

២. ហេតុអ្វីបានជាព្រះរាជបុត្រានៃព្រះព្រះយេស៊ូគ្រិស្តជាអ្នកជំនុំជំរះយើង? ៥:២៣

______________________________

៣. តើការពីរយ៉ាងអ្វីខ្លះដែលព្រះវរបិតា ព្រះអង្គប្រទានឱ្យព្រះរាជបុត្រា? ៥:២៦-២៧

______________________________

៤. តើការជំនុំជំរះប្រភេទណាទៅដែលព្រះយេស៊ូធ្វើ? ៨:១៦:______________

______________________________

៥. នៅពេលសេចក្ដីជំនុំជំរះមក តើនឹងមានអ្វីកើតឡើងចំពោះអារក្ស? ១២:៣១

៦. តើអ្វីដែលបណ្ដាលឱ្យមានការបាត់បង់អំណាច និងតំណែងរបស់អារក្សនៅលើផែនដី? ១២:៣២________________________________

________________________________

៧. នៅពេលណាទើបព្រះយេស៊ូត្រូវបានលើកឡើង? ១២:៣៣

________________________________

*«ដូច្នេះ យើងទាំងអស់គ្នានឹងត្រូវរាប់រៀបទូលថ្វាយព្រះពីដំណើររបស់ខ្លួនយើងជាមិនខាន ដូច្នេះយើងត្រូវរៀបរាប់ទូលព្រះជាម្ចាស់ នូវអំពើដែលខ្លួនយើងម្នាក់ៗបានប្រព្រឹត្ត»* (រ៉ូម១៤:១២)។

៨. តើមានមនុស្សប៉ុន្មាននាក់នឹងត្រូវផ្ដល់ចម្លើយដល់ព្រះនៅថ្ងៃជំនុំជំរះ?

________________________________

៩. តើសកម្មភាពរបស់អ្នកណានឹងត្រូវបានរាប់បញ្ចូលនៅថ្ងៃជំនុំជំរះ?

________________________________

ព្រះជាម្ចាស់មានបញ្ជីកត់ត្រា ព្រះអង្គមានរបស់សម្រាប់ថែរក្សានូវប្រវត្តិរបស់មនុស្ស ដូចជាម៉ាស៊ីនថតរូបដែលមើលមិនឃើញនៅតាមខ្លួនអ្នក២៤ម៉ោងក្នុងមួយថ្ងៃ។ ព្រះអង្គជ្រាបពីអត្តចរិកគំនិត ពាក្យសម្ដី និងសកម្មភាពរបស់អ្នក។ មានថ្ងៃជំនុំជំរះជាពិត។

*«អ្នករាល់គ្នាបានឮសេចក្ដីថ្លែងទុកមកដែលសម្ដែងពីដើមថា «កុំប្រព្រឹត្តអំពើផិតក្បត់ ផិតឱ្យសោះ» រីឯខ្ញុំវិញ ខ្ញុំសុំបញ្ជាក់ប្រាប់អ្នករាល់គ្នាថា អ្នកណាមើលស្រីម្នាក់ ហើយមានចិត្តស្រើបស្រាល ចង់រួមបវេណីជាមួយនាង អ្នកដូចជាបានប្រព្រិត្តអំពើផិតក្បត់ជាមួយនាងនៅក្នុងចិត្តរបស់ខ្លួន រួចស្រេចទៅហើយ ប៉ុន្តែខ្ញុំប្រាប់អ្នករាល់គ្នាថា សូម្បីតែអ្នកណាដែលគ្រាន់តែក្រឡេកឃើញស្រី ហើយមានជំរេកសំរើបចង់បាននោះឈ្មោះថាបានប្រព្រឹត្តសេចក្ដីកំផិតនឹងនាងនោះនៅក្នុងចិត្តខ្លួនហើយ»*

ម៉ាថាយ ៥:២៧។

១០. នៅពេលណាដែលការកំផិតចាប់ផ្ដើមកើតឡើងនៅក្នុងមនុស្ស?

(គូសរង្វង់នៅលើចម្លើយ)

ក) នៅពេលមនុស្សម្នាក់មើល និងមានចំណង់?

ខ) នៅពេលអ្នកណាម្នាក់ប្រព្រឹត្តសកម្មភាពនៃអំពើបាប?

អានពាក្យទាំងនេះពីព្រះយេស៊ូ៖ *«ដ្បិតគឺពីក្នុងចិត្តនោះឯង ដែលចេញអស់ទាំង»។*

*១)គំនិតអាក្រក់ ២)ការកាប់សម្លាប់គេ ៣)ផិតក្បត់, ៤)សហាយស្មន់, ៥)លួចប្លន់ ៦)ធ្វើបន្ទាល់ក្លែងក្លាយ ៧)ជេរប្រមាថ។ សេចក្ដីទាំងនេះទើបធ្វើឱ្យមនុស្សស្មោកគ្រោកមែន»* (ម៉ាថាយ ១៥:១៩-២០)។

១១. ដាក់នូវអំពើបាបខាងឯសេចក្ដីនីមួយៗដោយពាក្យរបស់លោកអ្នកផ្ទាល់:

ក)________________ ខ)________________

គ)________________ ឃ)________________

ង)________________ ច)________________

ឆ)________________

១២. តើអំពើបាបទាំងនេះមកពីណា?________________

________________

១៣. តើអំពើបាបមួយណាដែលមានការល្បួងជាងគេបំផុតសម្រាប់បងប្អូន?

________________

អំពើបាបដ៏គួរភ័យខ្លាចទាំងអស់នេះ អាចនឹងបំផ្លាញអាពាហ៍ពិពាហ៍ កូនមង្គលការកូន ឬការងាររបស់យើងបាន។ ប៉ុន្តែ អំពើបាបទាំងអស់នោះមិនមែនជាអំពើអាក្រក់ជាងគេបំផុតនោះទេ។ មានតែអំពើបាបមួយទេ ដែលមិនអាចនឹងលើកលែងទោសឱ្យបាន ដែលនឹងបញ្ជូនយើងទៅឯស្ថាននរក។

១៤. តើអំពើបាបដ៏ធំ និងមិនអាចនឹងលើកលែងទោសបានទាំងនោះជាអ្វី?

យ៉ូហាន៨:២៤:______________________________

ព្រះយេស៊ូជាព្រះមួយរយភាគរយ និងមនុស្សមួយរយភាគរយ។ សូមឱ្យយើងក្រឡេកមើលដោយយកចិត្តទុកដាក់នូវអ្វីដែលព្រះអង្គបានធ្វើសម្រាប់យើងនៅលើឈើឆ្កាង។ សូមអាននូវខបន្ទាប់ពីព្រះគម្ពីរហេព្រើរ១០:១០-១៨« *គឺដោយសារចំណង់ព្រះហឫទ័យនោះដែលយើងរាល់គ្នាបានញែកជាបរិសុទ្ធដោយសារដង្វាយថ្វាយរូបអង្គព្រះយេស៊ូគ្រិស្ត១ដងជាសម្រេច។ឯអស់ទាំងសង្ឃក៏ឈរធ្វើការងាររាល់តែថ្ងៃទាំងថ្វាយយញ្ញបូជាដែលជាញឹកញាយដែលពុំអាចនឹងដោះបាបបានឡើយ តែទ្រង់វិញក្រោយដែលទ្រង់បានថ្វាយយញ្ញបូជាតែ១ដោយព្រោះបាបនោះទ្រង់បានគង់ខាងស្តាំព្រះ... ដ្បិតទ្រង់ធ្វើឱ្យពួកអ្នកដែលបានញែកជាបរិសុទ្ធហើយបានគ្រប់លក្ខណ៍អស់កល្បជានិច្ច... ដូច្នេះ ដែលបានប្រោសឱ្យរួចពីសេចក្តីទាំងនោះរួចហើយ នោះមិនចាំបាច់ថ្វាយដង្វាយដោយព្រោះបាបទៀតទេ*»។

១៥. មើលទៅខ.១០: តើព្រះយេស៊ូត្រូវសោយទិវង្គតប៉ុន្មានដងដើម្បីលាងនូវអំពើរបស់យើង? «ញែកជាបរិសុទ្ធ» មានន័យថា ធ្វើឱ្យបានបរិសុទ្ធដោយចែកជាផ្នែកៗ។ តើព្រះយេស៊ូបានធ្វើអ្វីដ៏គួរឱ្យអស្ចារ្យដល់ម្លេះបានជាមិនចាំបាច់ធ្វើទៅដល់ពីរដង?

គ្មានយញ្ញបូជាណានៅសព្វថ្ងៃនេះដែលត្រូវបន្ថែមនូវអ្វីដែលព្រះយេស៊ូបានបំពេញរួចហើយនោះទេ។ អំពើបាបរបស់យើងទាំងអស់ត្រូវបានដាក់នៅលើព្រះយេស៊ូ និងនៅលើការដែលព្រះអង្គបានសោយទិវង្គតជំនួសកន្លែងយើងហើយ។ ពាក្យថា «ព្រះអម្ចាស់» ត្រូវបានប្រើ៤០ដងនៅក្នុងព្រះគម្ពីរដំណឹងល្អយ៉ូហាន។ ព្រះយេស៊ូបានទិញដោយសេចក្តីស្រលាញ់របស់ទ្រង់នូវសិទ្ធិជាព្រះអម្ចាស់ និង «ម្ចាស់» របស់យើង។

១៦. តើអ្វីដែលមិនអាចដោះនូវអំពើបាបរបស់យើងបានសព្វថ្ងៃនេះ? ខ.១១____

______________________________

១៧. តើព្រះយេស៊ូគ្រិស្តបានធ្វើអ្វីនៅលើឈើឆ្កាង? ខ.១២______________

______________________________

១៨. តើយញ្ញបូជានេះនឹងស្ថិតនៅរយៈពេលយូរប៉ុន្មាន?_______________

១៩. នៅពេលមនុស្សម្នាក់អង្គុយចុះ ប្រហែលជាម្នាក់នោះគាត់អស់កម្លាំង ឬដោយព្រោះគាត់បានបញ្ចប់កិច្ចការរបស់គាត់។ ហេតុអ្វីបានជាព្រះយេស៊ូអង្គុយនៅជិតព្រះជាម្ចាស់ «ព្រះវរបិតា»?______________________________

២០. តើព្រះយេស៊ូសោយទិវង្គតប៉ុន្មានដងដើម្បីធ្វើឱ្យយើងពេញខ្នាត និងបរិសុទ្ធនៅចំពោះព្រះជាម្ចាស់? ខ.១៤:______________________________

២១. ដោយព្រោះឈាមដែលព្រះយេស៊ូបានបង្ហូរសម្រាប់អំពើបាបរបស់យើង តើមានអំពើបាបប៉ុន្មានដែលព្រះជាម្ចាស់នឹងចងចាំនោះ? ខ.១៧:__________

ព្រះយេស៊ូសោយទិវង្គតសម្រាប់ទាំងអស់ ប៉ុន្តែ សម្រាប់តែអ្នកដែលទទួលព្រះយេស៊ូជាព្រះសង្គ្រោះ និងជាព្រះអម្ចាស់របស់ពួកគេតែប៉ុណ្ណោះដែលបានទទួលប្រយោជន៍ពីការសោយទិវង្គតរបស់ព្រះអង្គនៅលើឈើឆ្កាង។

២២. តាំងពីព្រះទទួលនូវយញ្ញបូជារបស់ព្រះយេស៊ូជាការអត់ទោសសម្រាប់អំពើបាបរបស់យើង តើព្រះយេស៊ូត្រូវការធ្វើយញ្ញបូជាសារជាថ្មីម្តងទៀតដែរឬទេនៅសព្វថ្ងៃនេះនៅក្នុងហ្វូងមនុស្ស? ហេតុអ្វី?

## មេរៀនទី៥

# ដំណោះស្រាយរបស់ព្រះជាម្ចាស់ចំពោះអំពើបាបរបស់យើង

### ការសិក្សាព្រះគម្ពីរដំណឹងល្អយ៉ូហាន

មានការមួយបានកើតឡើងនៅពេលព្រះយេស៊ូសោយទិវង្គតនៅលើឈើឆ្កាង ដែលមិនធ្លាប់កើតមានពីមុនមក។ ចូរឱ្យយើងយល់ឱ្យច្បាស់ពីសារៈសំខាន់នៃឈើឆ្កាងដូចដែលយើងមើលទៅព្រឹត្តិការណ៍នៅក្នុងដំណឹងល្អយ៉ូហានជំពូក ១៩-២០។

**ការសោយទិវង្គតរបស់ព្រះយេស៊ូ:** អានយ៉ូហាន ១៩:១៥-៣៧

១. លោកពីឡាត់ប្រគល់ព្រះយេស៊ូទៅឱ្យពួកទាហានដើម្បី__________១៩:១៦

២. តើអ្នកគិតថាពួកទាហានគិតយ៉ាងដូចម្ដេច?__________

៣. តើព្រះយេស៊ូកំពុងមានអារម្មណ៍យ៉ាងដូចម្ដេច?__________

៤. តើព្រះយេស៊ូកំពុងនៅលីអ្វី?__________

៥. តើពួកទាហានធ្វើអ្វីចំពោះព្រះយេស៊ូ? ខ.១៨, ២៣__________

__________

៦. តើព្រះពស្ដុរបស់ព្រះយេស៊ូទៅជាយ៉ាងណាកាលព្រះអង្គកំពុងត្រូវឆ្កាង? ១៩:២៣

__________

៧. តើព្រះយេស៊ូឃើញ និងមានព្រះបន្ទូលយ៉ាងដូចម្ដេចកាលកំពុងជាប់ឆ្កាង? ១៩:២៦, ២៧__________

ឯព្រះយេស៊ូមានបន្ទូលថា *«ឱព្រះវរបិតាអើយ សូមអត់ទោសដល់អ្នកទាំងនេះផង ដ្បិតគេមិនដឹងជាគេធ្វើអ្វីទេ «ឱព្រះបិតាអើយ! សូមព្រះអង្គអត់ទោសឱ្យអ្នក*

*ទាំងនេះផង ដ្បិតគេមិនដឹងថាគេកំពុងធ្វើអ្វីឡើយ»* (លូកា ២៣:៣៤)។

៨. យោងទៅតាមខនេះ តើព្រះយេស៊ូឆ្លើយតបទៅកាន់អស់អ្នកដែលសម្លាប់ព្រះអង្គទាំងខុសដោយរបៀបណា? ______________________

______________________________________________

៩. អានខ៣០: តើពាក្យចុងក្រោយរបស់ព្រះយេស៊ូនៅឈើឆ្កាងថាយ៉ាងណា?

______________________________________________

១០. តើព្រះអង្គមានន័យយ៉ាងដូចម្តេច?

*«ដ្បិតឯព្រះអង្គដែលមិនបានស្គាល់បាបសោះ នោះព្រះទ្រង់បានធ្វើឱ្យត្រលប់ជាតួបាបជំនួសយើងរាល់គ្នាវិញ ដើម្បីឱ្យយើងរាល់គ្នាបានត្រលប់ទៅជាសេចក្តីសុចរិតរបស់ព្រះដោយនូវព្រះអង្គនោះឯង ព្រះគ្រិស្តគ្មានបាបទាល់តែសោះ តែព្រះជាម្ចាស់បានធ្វើឱ្យព្រះអង្គទៅជាតួបាបសម្រាប់យើង ដើម្បីប្រោសយើងឱ្យបានសុចរិតរួមជាមួយព្រះគ្រិស្តដែរ»* (២ កូរិនថូស ៥:២១)។

១១. តើការ២យ៉ាងអ្វីខ្លះដែលខនេះនិយាយពីព្រះយេស៊ូគ្រិស្ត? ____________

______________________________________________

សាវកពេត្រុសបានសរសេរថា *«សូម្បីតែព្រះគ្រិស្តក៏ព្រះអង្គបានសោយទិវង្គតម្តងជាសម្រេច ព្រោះតែបាបដែរ គឺព្រះដ៏សុចរិតបានសោយទិវង្គតជាប្រយោជន៍ដល់មនុស្សទុច្ចរិត ដើម្បីនាំលោកអ្នកទៅថ្វាយព្រះជាម្ចាស់ «ព្រោះព្រះគ្រិស្តទ្រង់បានរងទុក្ខម្តងដោយព្រោះបាបដែរ គឺជាព្រះដ៏សុចរិតទ្រង់រងទុក្ខជំនួសមនុស្សទុច្ចរិតដើម្បីនឹងនាំយើងរាល់គ្នាទៅដល់ព្រះ ដោយទ្រង់ត្រូវគេធ្វើគតខាងសាច់ឈាម តែបានព្រះវិញ្ញាណប្រោសឱ្យរស់វិញ»* (១ពេត្រុស ៣:១៨)។

១២. ព្រះគ្រិស្តសោយទិវង្គតជំនួស ______________________

១៣. តើព្រះយេស៊ូត្រូវសោយទិវង្គតប៉ុន្មានដង? ______________

១៤. តើការសោយទិវង្គតរបស់ព្រះអង្គផ្តល់អ្វីដល់យើង? ____________

______________________________________________

(១ ពេត្រុស ៣:២៤)?

**១៥.** តើព្រះយេស៊ូបានដាក់អ្វីលើអង្គទ្រង់ កាលកំពុងត្រូវឆ្កាង?____________

____________

**១៦.** យើងបានជាសះស្បើយ និងអត់ទោសទៅតាម____________

____________

បើកទៅយ៉ូហាន ១៥:៩, ១៣

**១៧.** ហេតុអ្វីបានជាព្រះអង្គជ្រើសរើសនឹងផ្តល់ជីវិតរបស់ផងព្រះអង្គសម្រាប់យើង?

____________

**ការបញ្ចុះសពព្រះយេស៊ូ:** អានយ៉ូហាន១៩:៣៨-៤២

**១.** តើអ្នកណាជាមិត្តរបស់ព្រះយេស៊ូដែលយកចិត្តទុកដាក់នឹងសពរបស់ព្រះអង្គ?
ខ.៣៨, ៣៩____________

**២.** សូមសរសេរនូវការ៣យ៉ាងដែលពួកគេធ្វើជាមួយនឹងសពរបស់ព្រះយេស៊ូ?

____________

____________

____________

**ការមានព្រះជន្មរស់ឡើងវិញរបស់ព្រះយេស៊ូគ្រិស្ត:** អានយ៉ូហាន ២០:១-៣១

**១.** តើស្ត្រីឈ្មោះម៉ារាម៉ាដាឡាធ្វើអ្វី?____________

**២.** តើសាវកពេត្រុសបានធ្វើអ្វី?____________

**៣.** តើព្រះយេស៊ូបានបង្ហាញខ្លួនដល់នរណាខ្លះឱ្យឃើញ? ខ១១-២៩

____________

៤. តើសាវកចូម៉ាស់បានធ្វើអ្វី? ៥២៤-២៥____________________

២៦-២៩____________________

៥. តើលោកអ្នកធ្វើអ្វីជាមួយនឹងព្រះយេស៊ូគ្រិស្ត?____________________

៦. ហេតុអ្វីបានជាព្រះគម្ពីរដំណឹងល្អយ៉ូហានត្រូវបានសរសេរឡើង? ៥៣១_____

____________________

សាវកប៉ូលបានសង្ខេបថា *«ដ្បិតមុនដំបូង ខ្ញុំបានប្រាប់មកអ្នករាល់គ្នាតាមសេចក្ដីដែលខ្ញុំបានទទួលដែរ គឺថាព្រះគ្រិស្តបានសុគតដោយព្រោះបាបរបស់យើងរាល់គ្នាតាមបទគម្ពីរ ហើយថាទ្រង់ត្រូវគេបញ្ចុះក្នុងផ្នូរ រួចដល់ថ្ងៃទី៣នោះទ្រង់មានព្រះជន្មរស់ឡើងវិញក៏តាមបទគម្ពីរ» «មុនដំបូងបង្អស់ ខ្ញុំជំរាបជូនលោកអ្នកនូវសេចក្ដីដែលខ្ញុំបានទទួល គឺថាព្រះគ្រិស្តបានសោយទិវង្គត តាមដើម្បីរំដោះបាបយើងស្របតាមព្រះគម្ពីរ។ គេបានបញ្ចុះព្រះសពព្រះអង្គនៅក្នុងផ្នូរ ហើយព្រះអង្គមានព្រះជន្មរស់ឡើងវិញនៅថ្ងៃទីបី ស្របតាមគម្ពីរ»* (១ កូរិនថូស ១៥:៣-៤)។

ព្រះយេស៊ូជាព្រះតាំងតែពីពេលព្រះវរបិតារបស់ព្រះអង្គបញ្ជូនព្រះអង្គមកលើផែនដីឱ្យកើតជាមនុស្ស។ កូនរបស់ព្រះមានគ្រប់ទាំងបទពិសោធដែលមានន័យថាព្រះអង្គជាមនុស្ស ព្រះអង្គមិនដែលធ្វើបាបសោះ។ ព្រះយេស៊ូសោយទិវង្គតនៅលើឈើឆ្កាងដូចជាអ្នកជំនួសអំពើរបស់លោកអ្នក ដោយសារតែសេចក្ដីដ៏អស្ចារ្យរបស់ព្រះអង្គសម្រាប់អ្នក។ព្រះអង្គត្រូវបានបែកពីព្រះវរបិតាដោយសារតែអំពើបាបរបស់លោកអ្នកទាំងអស់គ្នា។ទ្រង់ក្លាយជាយញ្ញបូជាដ៏ឥតខ្ចោះដែលមិនអាចនឹងចម្លង ឬគ្មានពីរឡើយសព្វថ្ងៃនេះ។

ព្រះយេស៊ូត្រូវបានបញ្ចុះក្នុងផ្នូរ ព្រះជាម្ចាស់ទទួលយកនូវការសោយទិវង្គតរបស់ព្រះយេស៊ូជាសំណងពេញថ្លៃសម្រាប់អំពើបាបរបស់យើង ដោយប្រោសព្រះអង្គឱ្យមានព្រះជន្មរស់ឡើងវិញ។ ព្រះយេស៊ូគ្រិស្តនៅមានព្រះជន្មរស់ ហើយតាមរយៈព្រះវិញ្ញាណបរិសុទ្ធរបស់ព្រះអង្គ ព្រះអង្គនឹងមកគង់ក្នុងចិត្តរបស់អស់អ្នកដែលលន់តួនូវអំពើបាបរបស់ខ្លួន និង ចុះចូលជីវិតរបស់ខ្លួនដោយទទួលព្រះអង្គ ជាព្រះអង្គសង្គ្រោះនិងព្រះអម្ចាស់គង់នៅជាមួយនឹងអ្នកនោះជារៀងរហូត។

# មេរៀនទី៦

# អំណោយដ៏អស្ចារ្យបំផុត

ការសិក្សាព្រះគម្ពីរដំណឹងល្អយ៉ូហាន

# មេរៀនទី៦

វាមិនដែលគ្រប់គ្រាន់នោះទេដើម្បីដឹងពីការអ្វីផ្សេងនោះ ដូច្នេះយើងត្រូវប្រើនូវចំណេះដឹងនោះ។ វាអស្ចារ្យណាស់ក្នុងការចែកចាយ និងទទួលយកនូវអំណោយទាននោះ។ ប៉ុន្តែ អ្នកនឹងមិនមានអំណរ ប្រសិនជាលោកអ្នកមិនទទួលវាពីអ្នកដែលឱ្យ និងប្រើវានោះទេ។ ព្រះជាម្ចាស់ប្រទាននូវអំណោយដ៏អស្ចារ្យនៃជីវិតដ៏អស់កល្បជានិច្ច។ ប៉ុន្តែ អ្នកត្រូវទទួលនូវអំណោយនេះដោយការទទួលព្រះរាជបុត្រារបស់ព្រះអង្គ គឺព្រះយេស៊ូគ្រិស្ត។

សូមអាននូវខបន្ទាប់ ហើយឆ្លើយសំនួរទៅតាមគំនិតរបស់លោកអ្នកផ្ទាល់។ យើងប្រើពាក្យថា «ជឿ» ជារៀងរាល់ថ្ងៃ។ «ខ្ញុំជឿទុកចិត្តលើក្រុមគ្រួសាររបស់ខ្ញុំ» ឬ «ខ្ញុំជឿទុកចិត្តលើបេក្ខជនតំណាងរាស្ត្រនេះ»។ នេះមិនមែនជាពាក្យថា «ជឿ»ដូចដែលនៅក្នុងព្រះគម្ពីរបានប្រើនោះទេ។ ព្រះជាម្ចាស់សព្វព្រះហឫទ័យឱ្យយើងជឿលើព្រះអង្គ ប៉ុន្តែ តើមានន័យថាយ៉ាងដូចម្តេចដែលថាជឿនោះ?

១. តើ«កិច្ចការ» តែមួយគត់គឺជាអ្វីដែលព្រះជាម្ចាស់ទទួលយកសម្រាប់សេចក្តីសង្គ្រោះ? ៦:២៨-២៩:________________________________________

ទាំងនេះគឺជាខដែលបង្ហាញថា អ្វីទៅជាអត្ថន័យដ៏ពិតចំពោះពាក្យ *ជឿលើព្រះយេស៊ូគ្រិស្ត* នោះ។

ព្រះយេស៊ូមានព្រះបន្ទូលថា « *មើលអញឈរនៅមាត់ទ្វារទាំងគោះបើអ្នកណាឮសម្លេងអញ ហើយបើកទ្វារឱ្យនោះអញនឹងចូលទៅឯអ្នកនោះអញនឹងបរិភោគជា*

*មួយនឹងអ្នកនោះហើយអ្នកនោះជាមួយនឹងអញដែរ»។ «មើល៍យើងនៅមាត់ទ្វារទាំង គោះទ្វារទៀតផង ប្រសិនបើមានអ្នកណាម្នាក់ឮសម្លេងយើង ហើយបើកទ្វារឱ្យ យើងនឹងចូលទៅក្នុងផ្ទះអ្នកនោះ យើងនឹងបរិភោគជាមួយនឹងអ្នកនោះហើយអ្នក នោះក៏នឹងបរិភោគជាមួយនឹងយើងដែរ»* (វិវរណៈ ៣:២០)។

២. តើព្រះយេស៊ូកំពុងឈរនៅកន្លែងណា? ____________________

____________________

៣. តើពាក្យថា «ទ្វារ» មានន័យយ៉ាងដូចម្តេចចំពោះទិដ្ឋភាពនៃខនេះ? ________

____________________

៤. ហេតុអ្វីបានជាព្រះយេស៊ូ «គោះ» ទ្វារ? ____________________

____________________

៥. តើការ២យ៉ាងអ្វីខ្លះត្រូវកើតឡើងមុនពេលព្រះយេស៊ូយាងចូលទៅគង់នៅក្នុង ចិត្ត?

ក) ____________________

ខ) ____________________

៦. តើព្រះយេស៊ូមានព្រះបន្ទូលសន្យានឹងធ្វើអ្វីចំពោះអស់អ្នកដែលបើកចិត្ត?

ការទទួលទានអាហារជាមួយគ្នាអាចជាពេលវេលានៃការបង្ហាញពីចំណងមិត្ត ភាពដ៏ជ្រៅលជ្រៅ។ ព្រះគម្ពីរបំពេញដោយចំណីរអាហារខាងឯព្រលឹងវិញ្ញាណរបស់ លោកអ្នក។ ព្រះយេស៊ូចង់មានពេលនៃការស្គាល់ និងការសប្បាយក្នុងការជួបជុំគ្នាពី មួយថ្ងៃទៅមួយថ្ងៃ។ លោកអ្នកត្រូវការញុំាជាមួយនឹងព្រះដូចដែលលោកអ្នករៀន ព្រះបន្ទូលរបស់ព្រះអង្គហើយបន្ទាប់មកលោកអ្នកនិយាយជាមួយនឹងព្រះអង្គនៅ ក្នុងសេចក្តីអធិស្ឋាន។

*(ប្រសិនបើមាត់អ្នកប្រកាសថា ព្រះយេស៊ូពិតជាព្រះអម្ចាស់ ហើយបើចិត្តអ្នក ជឿថា ព្រះជាម្ចាស់ពិតជាបានប្រោសព្រះយេស៊ូឱ្យមានព្រះជន្មរស់ឡើងវិញមែននោះ អ្នកនឹងទទួលការសង្គ្រោះជាមិនខាន» (រ៉ូម ១០:៩)*។

*« បើមាត់អ្នកនឹងទទួលថ្លែងប្រាប់ពីព្រះអម្ចាស់យេស៊ូ ហើយអ្នកជឿក្នុងចិត្តថាព្រះបានប្រោសឱ្យទ្រង់រស់ពីស្លាប់ឡើងវិញនោះអ្នកនឹងបានសង្គ្រោះពិត»* (រ៉ូម១០:៩)

៧. តើពាក្យអ្វីដែលបង្ហាញនៅក្នុងខនេះអំពីអត្ថន័យ នៃការទទួលជឿព្រះគ្រិស្ត? អ្នក____________________ហើយ__________________ក្នុងចិត្ត

________________________________________________

៨. ចូរពន្យល់ពីភាពខុសគ្នារវាងការជឿនៅក្នុងខួរក្បាលរបស់អ្នក និងការជឿនៅក្នុងចិត្តរបស់អ្នកៈ________________________________________

________________________________________________

*«ដ្បិតអ្នកណាអង្វររកព្រះនាមព្រះអម្ចាស់ អ្នកនោះនឹងបានទទួលការសង្គ្រោះ» (រ៉ូម ១០:១៣)។*

*« ហើយគ្រប់គ្នា គឺអស់អ្នកណាដែលអំពាវនាវដល់ព្រះនាមព្រះអម្ចាស់នោះនឹងបានសង្គ្រោះ»* (រ៉ូម១០:១៣)

៩. តើគំនិតអ្វីនៅក្នុងខនេះមានន័យពីការជឿលើព្រះគ្រិស្ត និងត្រូវបានសង្គ្រោះ?

________________________________________________

១០. ប្រសិនជាលោកអ្នកមិនទាន់ជឿព្រះយេស៊ូនៅឡើយ តើលក្ខខណរបស់អ្នកជាអ្វីនៅចំពោះមុខព្រះ? ៣:១៨:________________________________

________________________________________________

១១. ហេតុអ្វីបានជាមនុស្សមិនទទួលព្រះរាជបុត្រារបស់ព្រះជាព្រះសង្គ្រោះ និងជាព្រះអម្ចាស់? ៣:១៩, ២០__________________________________

________________________________________________

________________________________________________

________________________________________________

ចូរក្រឡេកមើលទៅជីវិតរបស់មនុស្ស៤នាក់ដែលជឿលើព្រះយេស៊ូ អានយ៉ូហាន៤

១២. តើព្រះយេស៊ូអះអាងពីអ្នកណា? ខ.២៥, ២៦:________________________

____________________________________________________________

១៣. នៅពេលដែលស្ត្រីពេស្យាបានទទួលជឿព្រះយេស៊ូ តើសេចក្តីជំនឿរបស់នាង ដឹកនាំនាងឱ្យធ្វើអ្វី?____________________________________________

____________________________________________________________

____________________________________________________________

១៤.រឿងរបស់នាម៉ឺនម្នាក់បង្ហាញពីអំណាចនៃការជឿលើព្រះយេស៊ូ ៤:៤៩-៥៣ តើ ហេតុអ្វីបានជាយើងដឹងថា នាម៉ឺនម្នាក់នោះបានជឿព្រះយេស៊ូអំពីកូនរបស់លោក?

____________________________________________________________

ការសាកល្បងសេចក្តីជំនឿដ៏ពិត គឺការគោរពកោតខ្លាចដល់ព្រះអម្ចាស់យេស៊ូ។

១៥. តើអ្វីដែលព្រះយេស៊ូប្រាប់ទៅនារីដែលព្រះអង្គជួយសង្គ្រោះឱ្យរួចពីស្លាប់ក្នុងការ ប្រព្រឹត្តអំពើដែលផិតក្បត់? ៨:១១___________________________________

____________________________________________________________

១៦. ជឿលើព្រះយេស៊ូជាពន្លឺលោកិយមិនដែលដើរក្នុងងងឹតឡើយ គឺនឹង______

____________________________________________________________

១៧. តើព្រះយេស៊ូសន្យានឹងអស់អ្នកដែលដើរតាមព្រះអង្គថាយ៉ាងដូចម្តេច? ៨:១២

____________________________________________________________

១៨. ក្រោយពេលព្រះយេស៊ូព្យាបាលភ្នែករបស់បុរសខ្វាក់ហើយ តើយើងថាគាត់ បានជឿដោយរបៀបណា? ៩:៧-៨:_________________________________

____________________________________________________________

១៩. ក្រោយពីអ្នកកាន់សាសនាបានបណ្តេញបុរសដែលព្រះយេស៊ូទើបនឹងព្យាបាល ព្រះយេស៊ូបានរកឃើញគាត់។ នៅពេលព្រះយេស៊ូបានបង្ហាញរូបអង្គទ្រង់ តើសកម្ម

ភាពអ្វីដែលបង្ហាញពីសេចក្ដីជំនឿរបស់បុរសខ្វាក់ម្នាក់នោះ? ៩:៣៥-៣៨

«ប្រែចិត្ត» មានន័យថា «ផ្លាស់ប្ដូរនៃអត្តចរិតដែលមានលទ្ធផលនៅក្នុងការផ្លាស់ប្ដូរទិសដៅ...នៃការផ្លាស់ប្ដូរការផ្លាស់ប្ដូរនៃជីវិត»។ «លន់តួ» គឺជាការបែរចេញពីអំពើនៃសេចក្ដីស្លាប់ដែលនៅជាប់នឹងជីវិតរបស់យើងហើយស្វែងរកព្រះគ្រិស្តសម្រាប់ការអត់ទោស និងជ័យជំនះលើអំពើបាប។ «ប្រែចិត្ត» គឺជាការផ្លាស់ប្ដូរនូវអាកប្បកិរិយាដូចជាព្រះយេស៊ូអញ្ចឹងដែរ។ ព្រះអង្គមិននៅជាទារកនៅក្នុងស្នូកទៀតនោះទេ ប៉ុន្តែ ជាព្រះអម្ចាស់លើទាំងអស់។

តើអ្នកមិនចង់អធិស្ឋាន និងអញ្ជើញព្រះយេស៊ូមកគង់នៅក្នុងជីវិតរបស់លោកអ្នកជាព្រះអង្គសង្គ្រោះ និងព្រះអម្ចាស់ទេឬអី? នេះជាសេចក្ដីអធិស្ឋានដែលមនុស្សជាច្រើនបានអធិស្ឋានៈ «អរព្រះគុណព្រះអម្ចាស់យេស៊ូសម្រាប់ការសោយទិវង្គតជួសខ្ញុំនៅលើឈើឆ្កាង។ អរព្រះគុណសម្រាប់ការយកអំពើបាបរបស់ខ្ញុំដាក់លើរូបអង្គទ្រង់។ ការប្រសើរបំផុតដែលខ្ញុំដឹងពីរការប្រគល់នូវអំពើបាប និងជីវិតរបស់ខ្ញុំទាំងអស់ដាច់ដល់ព្រះអង្គ។ ព្រះអម្ចាស់យេស៊ូអើយ! សូមចូលមកគង់ក្នុងជីវិតរបស់ខ្ញុំជាម្ចាស់ជីវិតរបស់ខ្ញុំ ខ្ញុំនឹងដើរតាមព្រះអង្គនៅគ្រប់ទីកន្លែងដែលទ្រង់ដឹកនាំខ្ញុំឱ្យទៅ»។

ក្រោយពីអធិស្ឋាននូវសេចក្ដីអធិស្ឋាននេះអស់ពីចិត្តរបស់លោកអ្នកហើយលោកអ្នកអាចសរសេរឈ្មោះរបស់លោកអ្នកនៅទីនេះៈ

ឬប្រសិនជាលោកអ្នកពិតជាព្រះយេស៊ូបានយកនូវអំពើបាបពីលោកអ្នកមែននោះលោកអ្នកនឹងទៅរស់នៅស្ថានសួគ៌នៅពេលលោកអ្នកលាចាកពីផែនដីនេះទៅ។

សូមគូសកន្លែងនេះ។

## មេរៀនទី៧

# អំណោយរបស់ព្រះជាម្ចាស់ដែលព្រះអង្គនៅតែប្រទានឱ្យ

ការសិក្សាព្រះគម្ពីរដំណឹងល្អយ៉ូហាន

នៅពេលលោកអ្នកបានទទួលព្រះយេស៊ូជាព្រះអង្គសង្គ្រោះ និងជាព្រះអម្ចាស់ពិតជាមកគង់នៅក្នុងរូបកាយរបស់លោកអ្នកតាមរយៈព្រះវិញ្ញាណបរិសុទ្ធមែន។«ព្រះគ្រិស្តសណ្ឋិតនៅក្នុងអ្នករាល់គ្នាដែលជាទីសង្ឃឹមយ៉ាងឧត្តម... ព្រះគ្រិស្តគង់នៅក្នុងខ្ញុំ» កូល៉ុស ១:២៧) (កាឡាទី២:២០)។ ប្រសិនជាលោកអ្នកទទួលជឿព្រះយេស៊ូអរព្រះគុណដល់ព្រះអង្គនៅក្នុងសេចក្តីអធិស្ឋានសម្រាប់ការដែល ព្រះអង្គគង់នៅជាមួយ ព្រះយេស៊ូជាអំណោយដ៏នៅអស់កល្បដែលមិនឈប់ប្រទាននោះឡើយ។

*«ប្រសិនបើអ្នកណាម្នាក់នៅរួមជាមួយព្រះគ្រិស្ត អ្នកនោះបានកើតជាថ្មី អ្វីៗពីអតីតកាលបានកន្លងផុតទៅ ហើយអ្វីៗទាំងអស់បានប្រែមកជាថ្មីវិញ» ២ កូរិនថូស ៥:១៧*

***«បានជាបើអ្នកណានៅក្នុងព្រះគ្រិស្ត នោះឈ្មោះថាបានកើតជាថ្មី ហើយអស់ទាំងសេចក្ដីចាស់បានកន្លងបាត់ទៅមើលគ្រប់ទាំងអស់បានត្រលប់ជាថ្មីវិញ»***
**(២ កូរិនថូស ៥:១៧)**

១. ដោយយោងទៅតាមខនេះ តើព្រះជាម្ចាស់ដាក់យើងនៅកន្លែងណា? នៅពេលណាដែលយើងទទួលព្រះយេស៊ូ? ______________________________

______________________________________________

២. តើយើងត្រូវបានហៅថាជាអ្វីឥឡូវនេះ? ______________________________

______________________________________________

៣. តើព្រះជាម្ចាស់មានបន្ទូលនឹងជីវិតចាស់របស់យើងថាយ៉ាងដូចម្ដេច?______

____________________________________________

៤. តើព្រះជាម្ចាស់មើលឃើញយើងនៅក្នុងព្រះគ្រិស្តដោយរបៀបណាឥឡូវ?____

____________________________________________

សាវកប៉ូលប្រើពាក្យ «នៅក្នុងព្រះគ្រិស្ត» ១៦៣ដងនៅក្នុងព្រះគម្ពីរសញ្ញាថ្មី។ នៅពេលដែលលោកអ្នកប្រគល់ជីវិតរបស់លោកអ្នកទៅព្រះគ្រិស្ត ពេលនោះព្រះអង្គយាងមកគង់នៅក្នុងលោកអ្នក ហើយលោកអ្នកត្រូវបាននៅក្នុងព្រះអង្គនេះហៅថា «ការរួមជាមួយនឹងព្រះគ្រិស្ត»។

**ព្រះយេស៊ូ «ខ្ញុំ» ជាព្រះនាមដ៏ថ្លៃវិសេសដែលស្គាល់នូវសេចក្ដីត្រូវការ ហើយផ្ដល់នូវគ្រប់ទាំងសេចក្ដីត្រូវការរបស់អ្នក**

នៅពេលព្រះយេស៊ូគង់នៅក្នុងលោកអ្នក ព្រះអង្គប្រទាននូវគ្រប់សេចក្ដីត្រូវការដែលជារូបអង្គទ្រង់ផ្ទាល់។ អត្តចរិតរបស់ព្រះអង្គផ្ដល់នូវសេចក្ដីតូវការដ៏សំខាន់របស់អ្នក។ នៅក្នុងព្រះគម្ពីរយ៉ូហានដំណឹងល្អ ព្រះយេស៊ូណែនាំរូបអង្គទ្រង់ទៅតាមព្រះនាមរបស់ព្រះក្នុងព្រះគម្ពីរសញ្ញាចាស់ «**អញជាព្រះដ៏ជាព្រះ**» ចូរយើងរៀននូវពាក្យ «**ខ្ញុំគឺជា**» ព្រះនាមទាំង៦របស់ព្រះយេស៊ូ។

៥. តើព្រះបានបញ្ជូននរណាឱ្យមកដើម្បីបំពេញតម្រូវការជាប្រចាំថ្ងៃសម្រាប់ជីវិតរបស់យើង? ៦:៣២-៣៥, ៥១____________________

____________________________________________

៦. តើ «នំប៉័ងនៃព្រះ» បានផ្ដល់អ្វីដោយមិនបាច់បង់ថ្លៃទៅដល់ពិភពលោកទាំងមូល? ៦:៣៣____________________________

____________________________________________

៧. ប្រសិនជាលោកអ្នកចូលទៅកាន់ឯព្រះយេស៊ូគ្រិស្តលោកអ្នកនឹងមិនដែល____

________________________________________ ៦:៣៥

៨. ប្រសិនជាលោកអ្នកជឿដល់ព្រះអង្គលោកអ្នកនឹងមិនដែល________________

________________________________________________________________ ៦:៣៥

៩. តើពាក្យសម្តីពីរមាត់អ្វីខ្លះដែលបង្ហាញពីរបៀបទទួលកម្លាំង និងការផ្គត់ផ្គង់នៃព្រះយេស៊ូ? ៦:៣៥________________________________________

________________________________________________________________

១០. ព្រះយេស៊ូមានបន្ទូលថា «ខ្ញុំជា____________________________________

______________________________________________________________» ៨:១២

១១. សូមសរសេរចូលនូវមូលហេតុបីយ៉ាងដែលអ្នកត្រូវការពន្លឺជារៀងរាល់ថ្ងៃ____

________________________________________________________________

________________________________________________________________

________________________________________________________________

លោកអ្នកត្រូវការពន្លឺសម្រាប់ភ្នែកទាំងពីរ និងគំនិតរបស់លោកអ្នកដើម្បីញែកនូវអ្វីដែលល្អពីអ្វីដែលអាក្រក់។ «*ការបើកសម្តែងព្រះបន្ទូលទ្រង់នោះផ្សាយពន្លឺចេញ ការស្វែងយល់ព្រះបន្ទូលរបស់ព្រះអង្គធ្វើឱ្យមនុស្សភ្លឺស្វាង ហើយធ្វើឱ្យអ្នកទន់ទាបមានប្រាជ្ញា ក៏ធ្វើឱ្យមនុស្សឆោតល្ងង់មានយោបល់*» (ទំនុកដំកើង១១៩:១៣០)។ ព្រះយេស៊ូចង់ឱ្យលោកអ្នករៀននូវបំណងព្រះហឫទ័យរបស់ព្រះអង្គទៅតាមការសិក្សាព្រះគម្ពីរជារៀងរាល់ថ្ងៃ។

១២. សូមគិតនូវការបីយ៉ាងដែលអ្នកគង្វាលចៀមប្រើទ្វារសម្រាប់ចូលទៅរកចៀមរបស់គាត់ យ៉ូហាន១០:៨-១០:______________________________

________________________________________________________________

ចូរស្រមៃមើលថា តើកិច្ចការរបស់អ្នកគង្វាលចៀមពិបាកយ៉ាងណាទៅ បើគ្មានទ្វារសម្រាប់ក្រោលរបស់គាត់នោះ?

១៣. តើលោកអ្នកត្រូវការទទួលព្រះយេស៊ូជាទ្វារនៅក្នុងជីវិតរបស់លោកអ្នកដោយរបៀបណាក្នុងអាទិត្យនេះ?

*«ព្រះយេហូវ៉ាទ្រង់ជាអ្នកគង្វាលខ្ញុំ ខ្ញុំនឹងមិនខ្វះអ្វីសោះ ព្រះអម្ចាស់ជាអ្នកគង្វាលខ្ញុំ ខ្ញុំនឹងមិនខ្វះអ្វីសោះឡើយ»* (ទំនុកដំកើង ២៣:១)។ ស្តេចដាវិឌស្រែកហៅព្រះជាម្ចាស់ថា*«អ្នកគង្វាលខ្ញុំ»*។ យើងទាំងអស់គ្នាជាចៀមរបស់ព្រះអង្គ។ ព្រះយេស៊ូអះអាងថាព្រះអង្គជាព្រះ ដោយប្រើឈ្មោះដូចគ្នាដែរ គឺ*«អ្នកគង្វាល»*។

១៤. អានយ៉ូហាន១០:១១-១៧ សូមគិត និងសរសេរនូវការបីចំណុចដែលអ្នកគង្វាលដ៏ល្អនឹងធ្វើសម្រាប់ចៀម:______________________________

______________________________________________________

______________________________________________________

១៥. តើព្រះយេស៊ូ ជាអ្នកគង្វាលដ៏ល្អអាចផ្តល់នូវសេចក្តីត្រូវការសម្រាប់ជីវិតរបស់អ្នកដោយរបៀបណានៅក្នុងអាទិត្យនេះ?______________________

______________________________________________________

ចូររកនូវឈ្មោះបីទៀតរបស់ព្រះយេស៊ូពីយ៉ូហាន១៤:៦

១៦. ព្រះយេស៊ូគឺ_______________លោកអ្នកដើរតាមព្រះអង្គជារៀងរាល់ថ្ងៃ

១៧. ព្រះយេស៊ូគឺ________________លោកអ្នក វាស់ ស្ទង់ នូវ កិច្ចការ ការសម្រេចចិត្ត និងចំណងទាក់ទងរបស់លោកអ្នក ដោយបំណងព្រះហឫទ័យ និងព្រះបន្ទូលរបស់ព្រះអង្គ។

១៨. ព្រះយេស៊ូគឺ_____________________ព្រះអង្គរស់នៅក្នុងលោកអ្នកទៅតាម ព្រះវិញ្ញាណរបស់ព្រះអង្គ។ ព្រះអង្គផ្តល់អំណាចដល់លោកអ្នកឱ្យរស់នៅដោយសុចរិត និងប្រទាននូវជីវិតដ៏នៅអស់កល្បជានិច្ច។ ទៅតាមរូបកាយរបស់យើងដែលនឹងត្រូវស្លាប់ យើងនឹងមិនស្លាប់បាត់ទៅដូចដោយព្រោះជាមនុស្សនោះទេ ព្រះយេស៊ូនឹងប្រោសរូបកាយរបស់យើងឡើងនៅពេលព្រះអង្គយាងមកវិញ (យ៉ូហាន១៤:២-៣)។

១៩. តើព្រះយេស៊ូហៅខ្លួនឯងថាជាអ្វី? ១៥:៥______________________

______________________________________________________

២០. ដើម្បីឱ្យបង្កើតផលផ្លែ តើការសំខាន់អ្វីសម្រាប់ឱ្យយើងធ្វើដែលជាខ្មែងនោះ? ១៥:៥____________________

២១. តើអ្វីដែលយើងត្រូវធ្វើតែម្នាក់ឯងដោយគ្មានព្រះយេស៊ូនោះ?

**និយាយសារឡើងវិញឱ្យខ្លាំងៗៈ** *«ព្រះយេស៊ូ ទូលបង្គំសូមថ្លែងអំណរគុណព្រះអង្គសម្រាប់ជានំប៉័ង ពន្លឺ ទ្វារ អ្នកគង្វាល ផ្លូវ សេចក្ដីពិត ជាដើមទំពាំងបាយជូរ និងជាគល់របស់ទូលបង្គំ»*។ នៅក្នុងអាទិត្យនេះ សូមលោកអ្នកចងចាំឈ្មោះនៅក្នុងព្រះគម្ពីររបស់ព្រះយេស៊ូដែលលោកអ្នកចូលចិត្ត។

**<u>អ្នកជំនួយថ្មីរបស់យើង</u>**

ព្រះយេស៊ូគង់នៅក្នុងអ្នកជឿតាមរយៈព្រះវិញ្ញាណបរិសុទ្ធ *«ព្រះអង្គទ្រង់បានចាត់ព្រះវិញ្ញាណនៃព្រះរាជបុត្រារបស់ព្រះអង្គទ្រង់ឱ្យមកសណ្ឋិតក្នុងចិត្តយើងអ្នករាល់គ្នា»* (កាឡាទី៤:៦)។ ព្រះវិញ្ញាណរបស់ព្រះអង្គប្រទាននូវអ្វីៗទាំងអស់ដែលយើងត្រូវការដើម្បីដើរតាមបំណងព្រះហឫទ័យរបស់ព្រះ។ ព្រះអង្គប្រទានដល់យើងនូវអំណាចដើម្បីដោះស្រាយបញ្ហារបស់យើង និងយកឈ្នះលើអារក្សទៀតផង។

២២. តើការអញ្ជើញអ្វីដែលព្រះយេស៊ូប្រទានឱ្យអស់អ្នកដែលស្រេកឃ្លានខាងឯព្រលឹងវិញ្ញាណនោះ? ៧:៣៧____________________

____________________

២៣. តើមានអ្វីកើតឡើងនៅក្នុងយើងនៅពេលយើងជឿ និងផឹក?____________________

____________________

____________________

២៤. តើ «ទន្លេទឹករស់» នេះសំដៅទៅលើអ្វី? ៧:៣៩____________________

____________________

២៥. តើ យើង យាង ព្រះវិញ្ញាណ បរិសុទ្ធ ចូល មក គង់ ក្នុង ជីវិត របស់ យើង ដោយ របៀបណា? ៧:៣៨____________________

____________________

២៦. តើការពីរយ៉ាងអ្វីខ្លះដែលព្រះវិញ្ញាណបរិសុទ្ធ ជាព្រះដ៏កំសាន្តចិត្តធ្វើនៅក្នុងយើង? ១៤:២៦ ____________________

ហើយ ____________________

២៧. មានឈ្មោះពីររបស់ព្រះវិញ្ញាណបរិសុទ្ធនៅក្នុងយ៉ូហាន១៥:២៦ តើឈ្មោះមួយណាតំណាងឱ្យចរិតលក្ខណៈនៃព្រះវិញ្ញាណរបស់ព្រះដែលលោកអ្នកត្រូវការជាប្រចាំថ្ងៃ? ____________________

____________________

____________________

២៨. តើអ្នកណាទទួលខុសត្រូវក្នុងការផ្សាយដំណឹងល្អអំពីព្រះយេស៊ូទៅដល់អស់អ្នកដែលមិនទាន់ស្គាល់ព្រះអង្គនៅឡើយ? ១៥:២៦, ២៧: ____________________

____________________ ១៥:២៦, ២៧

២៩. ក្រោយពេលព្រះវិញ្ញាណបរិសុទ្ធយាងចូលមកក្នុងអ្នកជឿម្នាក់ៗ តើការបួនយ៉ាងអ្វីខ្លះដែលទ្រង់នឹងធ្វើ? ១៦:១៣, ១៤

____________________

____________________

____________________

____________________

៣០. ព្រះវិញ្ញាណបរិសុទ្ធបង្ហាញយើងថាតើព្រះយេស៊ូជានរណា ហើយតើព្រះអង្គអាចធ្វើអ្វីនៅក្នុងយើង? ព្រះយេស៊ូសន្យាថា ព្រះអង្គនឹងបង្ហាញរូបអង្គទ្រង់មកដល់យើងផងដែរ។ តើក្នុងលក្ខខណ្ឌអ្វី សម្រាប់ការបង្ហាញរូបអង្គ? ១៤:២១, ២៤

____________________

____________________

____________________

# កំណត់ចំណាំ

# <u>កំណត់ចំណាំ</u>

# <u>កំណត់ចំណាំ</u>

# <u>កំណត់ចំណាំ</u>